


មគ្គុទ្ទេសក៍អនុវត្តន៍ជាក់ស្តែងសម្រាប់សង្គមស៊ីវិល

# វិធីតាមដានអនុសាសន៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ស៊ុយអែត
Sverige

ឧបត្ថម្ភថវិកាដោយប្រទេសស៊ុយអែត

*000000000149*

ចែកជូនដោយឥតគិតថ្លៃ

# តារាងមាតិកា


1. **របៀបប្រើមគ្គុទ្ទេសក៍នេះ ........ 1**
2. **តើការតាមដានគឺជាអ្វី ហើយហេតុអ្វីបានជាវាសំខាន់? ........ 3**
3. **តើតាមដានអ្វី? ........ 5**
4. **វិធីសាស្ត្រ និងសកម្មភាពតាមដាន ........ 7**
   - 4.1. ការកំណត់យកយន្តការដើម្បីចូលរួមជាមួយ ........ 7
   - 4.2. ការចូលរួមជាមួយយន្តការសិទ្ធិមនុស្សនៅទូទាំងវដ្តនៃយន្តការដើម្បីបង្កើនប្រសិទ្ធភាពជាអតិបរមា ........ 8
   - 4.3. ការរៀបចំអនុសាសន៍ និងការរកឃើញបញ្ហាសិទ្ធិមនុស្ស ........ 9
   - 4.4. ការកំណត់បញ្ហាអាទិភាព និងការធ្វើផែនការ ........ 10
   - 4.5. ការឃ្លាំមើលការអនុវត្ត ........ 16
   - 4.6. ការចាប់យកឱកាស ........ 19
   - 4.7. ការបង្កើត និងការធ្វើការជាសម្ព័ន្ធភាព ........ 19
   - 4.8. ការធ្វើជាដៃគូ ........ 22
   - 4.9. ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង ........ 25
   - 4.10. ការតស៊ូមតិ ........ 28
   - 4.11. ការកសាង និងការពង្រឹងសមត្ថភាព ........ 30
   - 4.12. ការបញ្ចូលទស្សនទានយេនឌ័រទៅក្នុងសកម្មភាពតាមដាន ........ 32
   - 4.13. ការឆ្លុះបញ្ចាំងពីការរួមបញ្ចូល ភាពចម្រុះ និងលទ្ធភាពទទួលបាន ........ 33
   - 4.14. ការប្រើប្រាស់អនុសាសន៍នៅក្នុងចំណាត់ការរបស់តុលាការ និង បណ្តឹងវិវាទ ........ 33
   - 4.15. ការចែករំលែកលទ្ធផលនៃសកម្មភាពតាមដាន និងការអនុវត្តល្អ ........ 34
   - 4.16. ការចូលរួមជាមួយនីតិវិធីតាមដាន និងការអនុវត្ត ដែលមានស្រាប់នៃយន្តការសិទ្ធិមនុស្ស ........ 35
5. **នីតិវិធីតាមដាន និងការអនុវត្តរបស់យន្តការសិទ្ធិមនុស្ស ........ 36**
   - 5.1. ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ........ 36
   - 5.2. ក្រុមប្រឹក្សាសិទ្ធិមនុស្ស ........ 41
   - 5.3. នីតិវិធីពិសេស ........ 43
   - 5.4. ការពិនិត្យជាសកលតាមកាលកំណត់ ........ 51
   - 5.5. វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ ........ 54
   - 5.6. ការសងសឹក ........ 54
6. **ព័ត៌មានបន្ថែម ........ 56**
7. **ទំនាក់ទំនងមកយើង ........ 58**

ឯកសារនេះ បោះពុម្ពផ្សាយក្រោយជំនួយថវិការបស់ប្រទេសស៊ុយអែត។ មាតិកា ឬខ្លឹមសារនៅក្នុងឯកសារនេះ គឺជាទំនួលខុសត្រូវទាំងស្រុងរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬការយល់ឃើញណាមួយរបស់ប្រទេសស៊ុយអែតឡើយ។




# ១. របៀបប្រើមគ្គុទ្ទេសក៍នេះ

មគ្គុទ្ទេសក៍នេះ ដែលបានចេញដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្ដោតលើរបៀបដែលសង្គមស៊ីវិលអាចតាមដានការអនុវត្តអនុសាសន៍របស់យន្តការអាណត្តិ ឬស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (អ.ស.ប)។ មិត្តអ្នកអានទាំងឡាយណាដែលមិនទាន់យល់ដឹងអំពីលក្ខណៈពិសេសនៃយន្តការទាំងនេះ សូមអានកូនសៀវភៅព័ត៌មានរបស់ OHCHR សម្រាប់សង្គមស៊ីវិលដែលមានចំណងជើងថា - *ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ* និង មគ្គុទ្ទេសក៍អនុវត្តន៍សម្រាប់សង្គមស៊ីវិលនេះ[1]

ផ្នែកទី១ - ៣ នៃមគ្គុទ្ទេសក៍នេះ ពន្យល់អំពី "ការតាមដាន" (follow-up) និង "ការអនុវត្ត" (implementation) រីឯផ្នែកទី៤ ពិពណ៌នាអំពីវិធីសាស្ត្រ និង សកម្មភាពដែលតួអង្គស៊ីវិល (CSAs) អាចប្រើប្រាស់។ ផ្នែកទី ៥ ពិនិត្យឡើងវិញនូវនីតិវិធី និងការអនុវត្តការតាមដានដែលមានស្រាប់របស់យន្តការសិទ្ធិមនុស្សអ.ស.ប និងរបៀបដែល CSAs អាចចូលរួម។

[1] មាននៅលើវេបសាយ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

មគ្គុទ្ទេសក៍នេះ ដែលបានចេញដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តោតលើរបៀបដែលសង្គមស៊ីវិលអាចតាមដានការអនុវត្តអនុសាសន៍របស់យន្តការអាណត្តិឬស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (អ.ស.ប)។មិត្តអ្នកអានទាំងឡាយណាដែលមិនទាន់យល់ដឹងអំពីលក្ខណៈពិសេសនៃយន្តការទាំងនេះ សូមអានកូនសៀវភៅព័ត៌មានរបស់ OHCHR សម្រាប់សង្គមស៊ីវិលដែលមានចំណងជើងថា - *ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ* និង មគ្គុទ្ទេសក៍អនុវត្តន៍សម្រាប់សង្គមស៊ីវិលនេះ[1]

ផ្នែកទី១ - ៣ នៃមគ្គុទ្ទេសក៍នេះ ពន្យល់អំពី "ការតាមដាន" (follow-up) និង "ការអនុវត្ត" (implementation) រីឯផ្នែកទី៤ ពិពណ៌នាអំពីវិធីសាស្ត្រ និង សកម្មភាពដែលតួអង្គស៊ីវិល (CSAs) អាចប្រើប្រាស់។ ផ្នែកទី ៥ ពិនិត្យឡើង វិញនូវនីតិវិធី និងការអនុវត្តការតាមដានដែលមានស្រាប់របស់យន្តការសិទ្ធិមនុស្សអ.ស.ប និងរបៀបដែល CSAs អាចចូលរួម។

[1] មាននៅលើវេបសាយ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

មគ្គុទ្ទេសក៍នេះ យោងផងដែរដល់ឧបករណ៍មួយចំនួន ដែលសម្រួលដល់សកម្មភាពតាមដានរបស់សង្គមស៊ីវិល។ ឧបករណ៍ទាំងនេះ មានរាយឈ្មោះក្នុងផ្នែកទី៦។

តាមរយៈការពិនិត្យឡើងវិញអំពីលក្ខណៈផ្សេងៗគ្នានៃវិធីសាស្ត្រ និងសកម្មភាពតាមដានការអនុវត្តបំពេញបន្ថែមដោយបទពិសោធន៍ជាក់ស្តែងដែល CSAs[2] និងOHCHR នៅតាមប្រទេសផ្សេងៗបានផ្តល់ជាវិភាគទាន មគ្គុទ្ទេសក៍នេះ ផ្តល់ជាបញ្ជីរាយឈ្មោះជម្រើសមួយចំនួន ដែល CSAs អាចជ្រើសរើសយកពីបញ្ជីនេះដោយឈរលើបញ្ហាអាទិភាព និងសមត្ថភាពរបស់ខ្លួនផ្ទាល់។

មគ្គុទ្ទេសក៍នេះ មានគោលដៅសំខាន់គឺសម្រាប់ CSAs ដែលធ្វើការនៅថ្នាក់ជាតិ។ ឯកសារនេះមានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ។

[2] ការបញ្ចូលករណីសិក្សា មិនសំដៅលើការអនុម័តរបស់ OHCHR ឡើយ។

## ២. តើការតាមដានគឺជាអ្វី ហើយហេតុអ្វីបានជាវាសំខាន់ ?

សកម្មភាពតាមដាន មានគោលបំណងធ្វើឲ្យប្រាកដថា អនុសាសន៍ និងការសម្រេចដោយយន្តការ និងស្ថានប័នសិទ្ធិមនុស្ស ត្រូវបានអនុវត្ត សំដៅលើកកម្ពស់ការគោរព ការការពារ និងការបំពេញសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា។

យន្តការ និងស្ថាប័នសិទ្ធិមនុស្ស អ.ស.ប សំដៅពង្រឹងការធ្វើឲ្យសម្រេចបានសិទ្ធិមនុស្សនៅប្រទេសទាំងអស់លើពិភពលោក។ សេចក្ដីសម្រេចចិត្តដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័ត ការរកឃើញរបស់គណៈកម្មការស៊ើបសួរ អនុសាសន៍របស់ស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេស និងការពិនិត្យជាសកលតាមកាលកំណត់ និងសេចក្ដីសម្រេចផ្សេងៗរបស់ស្ថាប័នសន្ធិសញ្ញាលើបណ្ដឹងលក្ខណៈជាបុគ្គលទាំងអស់នេះ សុទ្ធសឹងតែមានគោលដៅបិទផ្ចិតភាពចន្លោះប្រហោងនៃការការពារ និងបង្ហាញផ្លូវឲ្យរដ្ឋទាំងឡាយ និងភាគីពាក់ព័ន្ធដទៃទៀត ជំរុញឆ្ពោះទៅរកការសម្រេចបានពេញលេញនូវសិទ្ធិមនុស្ស។ ការរកឃើញអនុសាសន៍ និងសេចក្ដីសម្រេចទាំងអស់នេះ សំដៅបង្កើតឲ្យមានការផ្លាស់ប្ដូរជាវិជ្ជមានដល់ជីវិតរស់នៅរបស់ម្ចាស់សិទ្ធិ។ កាតព្វកិច្ចចម្បងក្នុងការធ្វើឲ្យសម្រេចបាននូវការផ្លាស់ប្ដូរទាំងនេះ គឺអាស្រ័យលើរដ្ឋទាំងឡាយ ដែលជាអ្នកមានករណីយកិច្ចគោរពការពារ និងបំពេញសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយគ្រប់ផ្នែកទាំងអស់នៃសង្គម រាប់ពីឯកក្កបុគ្គលរហូតដល់វិស័យឯកជន សហគមន៍អន្តរជាតិ និងតួអង្គសង្គមស៊ីវិល មានតួនាទីបំពេញដើម្បីធ្វើឲ្យសម្រេចបានសិទ្ធិមនុស្ស។ សង្គមស៊ីវិលជាពិសេសអាចដើរតួនាទីដ៏សំខាន់បំផុតនៅក្នុងការតាមដានការអនុវត្តអនុសាសន៍សិទ្ធិមនុស្ស។

# សង្ខេបដំណាក់កាលសម្រាប់ការតាមដាន



## ៣. តើតាមដានអ្វី ?

ការរកឃើញ និងអនុសាសន៍របស់យន្តការ និងស្ថាប័នសិទ្ធិមនុស្សអ.ស.ប មានច្រើន។ អង្គការសង្គមស៊ីវិល តាមដានការអនុវត្តអនុសាសន៍ទាំងឡាយណាដែលពាក់ព័ន្ធនឹងគោលដៅ និងវិសាលភាពនៃសកម្មភាពរបស់ខ្លួន។ អនុសាសន៍ទាំងនេះអាចជា ៖

▶ អនុសាសន៍ដែលអនុម័តដោយស្ថាប័នសន្ធិសញ្ញា (treaty bodies) នៅក្នុងសេចក្តីសង្កេតចុងក្រោយរបស់ពួកគេ បន្ទាប់ពីបានពិនិត្យមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សណាមួយរបស់រដ្ឋភាគីមួយ។

▶ អនុសាសន៍ដែលចេញដោយនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដូច មាននៅក្នុងរបាយការណ៍ស្តីពីទស្សនកិច្ចតាមប្រទេស របាយការណ៍តាមវិស័យ និងលិខិតឆ្លើយឆ្លងទាក់ទងនឹងបណ្តឹងលក្ខណៈជាបុគ្គល។

▶ អនុសាសន៍ដែលបានមកពីការពិនិត្យជាសកលតាមកាលកំណត់ (UPR) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស;

▶ សេចក្តីសម្រេចចិត្ត និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមហាសន្និបាត

▶ ការងាររបស់ស្ថាប័ននានាក្រោមឱវាទរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដូចជា គណៈកម្មាធិការប្រឹក្សាយោបល់ នីតិវិធីបណ្តឹង យន្តការអ្នកជំនាញស្តីពីសិទ្ធិជនជាតិដើមភាគតិច វេទិកាស្តីពីបញ្ហាជនជាតិភាគតិច វេទិកាសង្គម និងវេទិកាធុរកិច្ចនិងសិទ្ធិមនុស្ស

▶ អនុសាសន៍របស់គណៈកម្មការស៊ើបសួរនានា បេសកកម្មស្វែងរកការពិត និងយន្តការស៊ើបអង្កេតសិទ្ធិមនុស្សចំពោះកិច្ចដទៃទៀត ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ឬអគ្គលេខាធិការអ.ស.ប

▶ អនុសាសន៍ដែលមាននៅក្នុងរបាយការណ៍ និងការសិក្សារបស់ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស (ឧទា. របាយការណ៍ស្តីពីសកម្មភាពនៃវត្តមានតាមតំបន់របាយការណ៍ និងការសិក្សាស្តីពីស្ថានភាពប្រទេស និងតាមវិស័យ ដែលកំណត់ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស)

▶ ការអំពាវនាវដល់រដ្ឋទាំងឡាយ ឬសហគមន៍អន្តរជាតិដោយឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ឬដោយអ្នកជំនាញឯករាជ្យខាងសិទ្ធិមនុស្សនៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ។

នេះគឺជាបញ្ជីអនុសាសន៍ខ្លះៗសម្រាប់រដ្ឋ និងសង្គមស៊ីវិល ដើម្បីធ្វើការតាមដាន។ បន្ថែមពីលើយន្តការអ.ស.ប យន្តការសិទ្ធិមនុស្សថ្នាក់តំបន់ និងថ្នាក់ជាតិ ចេញរបាយការណ៍ និងអនុសាសន៍ផងដែរសំដៅពង្រឹងការសម្រេចបាននូវសិទ្ធិមនុស្ស។

ក្នុងការសម្រេចអំពីអ្វីដែលត្រូវផ្តោតការយកចិត្តទុកដាក់ ការសំខាន់ត្រូវជៀសវាងការតាមដានលក្ខណៈជាផ្នែកៗឬជាដុំៗ។ យន្តការសិទ្ធិមនុស្សផ្សេងៗមាននីតិវិធី និងរបៀបអនុវត្តរបស់ខ្លួនរៀងៗខ្លួនដូចមានចែងក្នុងផ្នែកទី៥ នៃមគ្គុទ្ទេសក៍នេះក៏ដោយ ក៏តម្លៃបន្ថែមមួយក្នុងចំណោមតម្លៃបន្ថែមទាំងឡាយ ដែលសង្គមស៊ីវិលអាចនាំយកមកនោះគឺការប្រកាន់យកវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដើម្បីធ្វើការតាមដាន។

វិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយ គឺដោយប្រើប្រាស់ពហុភាពនៃយន្តការសិទ្ធិមនុស្ស ជាជាងការផ្តោតតែទៅលើអនុសាសន៍របស់យន្តការតែមួយគត់។ វិធីសាស្ត្រនេះ ពាក់ព័ន្ធនឹងការចូលរួមជាមួយយន្តការសិទ្ធិមនុស្សនៅគ្រប់ដំណាក់កាលនៃការងាររបស់ពួកគេ។ យន្តការសិទ្ធិមនុស្សធ្វើការក្នុងរូបភាពជាវដ្តដែលចែកចេញជាដំណាក់កាលផ្សេងៗ មានដូចជា៖ ការប្រមូលព័ត៌មានការធ្វើរបាយការណ៍ ការសន្ទនាជាមួយរដ្ឋសាមី អនុសាសន៍ និងការតាមដាន។

ដូច្នេះ ការងារតាមដានរបស់សង្គមស៊ីវិល កាន់តែមានប្រសិទ្ធភាពថែមទៀត នៅពេលពួកគេចូលរួមនៅក្នុងដំណើរការទាំងមូល។ ទន្ទឹមនឹងការចូលរួមជាប់ជាប្រចាំនៅទូទាំងគ្រប់ដំណាក់កាលនៃវដ្តសកម្មភាពរបស់យន្តការសិទ្ធិមនុស្ស អាចផ្តល់លទ្ធផលច្រើននោះ តួអង្គសង្គមស៊ីវិលក៏អាចទទួលបានអត្ថប្រយោជន៍ពីលទ្ធផលនិងអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស ទោះជាពួកគេមិនបានចូលរួមនៅពេលកន្លងមកក្តី។

## វដ្តនៃយន្តការសិទ្ធិមនុស្ស



# ៤. វិធីសាស្រ្ត និងសកម្មភាពតាមដាន

ផ្នែកនេះបង្ហាញអំពីវិធី និងសកម្មភាពខ្លះៗសម្រាប់ការងារតាមដានរបស់សង្គមស៊ីវិល រួមជាមួយឧទាហរណ៍មួយចំនួននៃការអនុវត្តកន្លងមក។

## ៤.១. ការកំណត់យកយន្តការដើម្បីចូលរួមជាមួយ

ការធ្វើឲ្យសម្រេចបានសិទ្ធិមនុស្សទាំងអស់សម្រាប់គ្រប់គ្នា គឺជាគោលដៅសំខាន់បំផុតសម្រាប់ស្ថាប័នសិទ្ធិមនុស្សទាំងអស់របស់អ.ស.ប។ នៅប្រទេសភាគច្រើនវឌ្ឍនភាពកើតឡើងតាមរយៈកត្តាជាច្រើនគួបផ្សំគ្នា ដែលមានចាប់ពីឆន្ទៈនយោបាយរបស់អ្នកកាន់ករណីយកិច្ច រហូតដល់ឥរិយាបទរបស់ភ្នាក់ងារអនុវត្តច្បាប់ សកម្មភាពរបស់សង្គមស៊ីវិល សេចក្តីសម្រេច និងកម្រិតនៃឯករាជ្យភាពរបស់តុលាការ ឥទ្ធិពលរបស់អង្គការថ្នាក់តំបន់ ការផ្លាស់ប្តូរក្នុងរដ្ឋាភិបាល ។ល។ ការិយាល័យ OHCHR និងយន្តការសិទ្ធិមនុស្ស អ.ស.ប អាចដើរតួនាទីមួយដ៏សំខាន់ក្នុងការត្រួសត្រាយផ្លូវឆ្ពោះទៅរកការអនុវត្ត។



តើយន្តការមួយណាដែលមានឥទ្ធិពលធំបំផុត? ទស្សនកិច្ចនៅតាមប្រទេសរបស់អ្នកកាន់អាណត្តិនីតិវិធីពិសេស? អនុសាសន៍ដែលដោះស្រាយដោយរដ្ឋនានា នៅក្នុងការពិនិត្យជាសកលតាមកាលកំណត់ (UPR) និងដំណើរការនយោបាយពាក់ព័ន្ធ? ឬថាតើវាជាសេចក្តីសម្រេចរបស់ស្ថាប័នសន្ធិសញ្ញាណាមួយ អំពីបណ្តឹងជាលក្ខណៈបុគ្គល ឬ ទេ? ប្រហែលជាវាគឺជាការគួបផ្សំគ្នានៃកត្តាទាំងអស់នេះ ហើយនិងកត្តាច្រើនទៀត? តើតម្លៃបន្ថែមអ្វីខ្លះដែលយន្តការសិទ្ធិមនុស្ស អាចផ្តល់ដល់ការងាររបស់សង្គមស៊ីវិល លើបញ្ហាសិទ្ធិមនុស្សជាក់លាក់តាមប្រធានបទ និង/ឬនៅក្នុងប្រទេស ក្នុងតំបន់ ឬក្នុងទឹកដីមួយ? តើការចូលរួមរបៀបណាជាមួយយន្តការសិទ្ធិមនុស្សដែលត្រូវគ្នានឹងបញ្ហាអាទិភាព ផែនការ និងសមត្ថភាពរបស់តួអង្គសង្គមស៊ីវិល?

ធ្វើការវិភាគថាតើយន្តការមួយអាចផ្តល់អ្វីខ្លះ ហើយការយល់ដឹងអំពីការរកឃើញ និងអនុសាសន៍ គឺជាជំហានដ៏សំខាន់ឈានទៅ៖ ១) ធ្វើការសម្រេចអំពីការចូលរួមរបស់សង្គមស៊ីវិលជាមួយយន្តការបែបនេះ ២) តម្រែតម្រង់ការចូលរួមបែបនេះ និង ៣) ដាក់បញ្ចូលការចូលរួមបែបនេះទៅក្នុងយុទ្ធសាស្ត្រនិងផែនការការងាររបស់តួអង្គសង្គមស៊ីវិល។

## ៤.២. ការចូលរួមជាមួយយន្តការសិទ្ធិមនុស្សនៅទូទាំងវដ្តនៃយន្តការ ដើម្បីបង្កើនប្រសិទ្ធភាពជាអតិបរមា

បទពិសោធន៍បង្ហាញថា ទំនាក់ទំនងអន្តរកម្មរបស់សង្គមស៊ីវិលជាមួយយន្តការសិទ្ធិមនុស្សផ្តល់ផលកាន់តែច្រើនឡើងថែមទៀត នៅពេលដែលពួកគេធ្វើការនៅគ្រប់ដំណាក់កាលនៃវដ្តការងាររបស់យន្តការសិទ្ធិមនុស្ស។ ជាអាទិ៍ នៅពេលដាក់បញ្ជូនព័ត៌មានសម្រាប់ការពិនិត្យជាសកលតាមកាលកំណត់របស់រដ្ឋដែលស្ថិតក្រោមការពិនិត្យរបាយការណ៍ សង្គមស៊ីវិលអាចផ្តោតលើបញ្ហាមួយចំនួនដែលពួកគេមានកង្វល់បំផុត កង្វល់នោះអាចជាការធ្វើទណ្ឌកម្មលើរូបកាយកុមារ ឬជាការរើសអើងចំពោះជនភាគតិចជាតិពន្ធុជាដើម។ សង្គមស៊ីវិលអាចបង្កើតការសន្ទនាដំបូងជាមួយរដ្ឋាភិបាលរបស់ខ្លួនផ្ទាល់ ហើយបន្ទាប់មកជាមួយគណៈប្រតិភូនៃរដ្ឋជាសមាជិក ដែលនឹងត្រូវចូលរួមក្នុងកិច្ចសន្ទនាអន្តរកម្មអំពីការពិនិត្យជាសកលតាមកាលកំណត់ និងជំរុញលើកទឹកចិត្តពួកគេឲ្យដាក់ចេញជាអនុសាសន៍សម្រាប់បញ្ហាទាំងនេះ។ ឯកសារលទ្ធផលនៃការពិនិត្យជាសកល តាមកាលកំណត់នឹងឆ្លុះបញ្ចាំងពីអនុសាសន៍ទាំងនេះ ហើយដែលក្រោយមក អាចត្រូវបានប្រើប្រាស់នៅថ្នាក់ជាតិ ដើម្បីពង្រឹងការតស៊ូមតិ ឬសកម្មភាពដទៃទៀតរបស់សង្គមស៊ីវិល។

ដំណើរការស្រដៀងគ្នានេះ ធ្វើឡើងជាមួយយន្តការដទៃផ្សេងទៀត។ ការចូលរួមនេះ គឺធ្វើឡើងតាមរយៈការផ្តល់ព័ត៌មានដែលចងក្រងបានល្អនិងដែលអាចជឿទុកចិត្តបានអំពីបញ្ហាជាកង្វល់ដែលសង្គមស៊ីវិលអាចធ្វើឲ្យប្រសើរដល់ការរកឃើញ និងអនុសាសន៍ដែលពាក់ព័ន្ធ និងដែលត្រូវផ្តោតទៅលើ។ អនុសាសន៍ដែលបានតាក់តែងយ៉ាងល្អ ដែលអាចអនុវត្តបាន និងដែលឆ្លើយតបទៅ

នឹងចន្លោះប្រហោង ដែលបានសំគាល់ឃើញអំពីការការពារសិទ្ធិមនុស្សដែលចេញដោយស្ថាប័នសិទ្ធិមនុស្ស អ.ស.ប គឺមានសារៈសំខាន់ខ្លាំងក្នុងការទ្រទ្រង់ដល់សកម្មភាពផ្សព្វផ្សាយរបស់សង្គមស៊ីវិលនៅថ្នាក់ជាតិ។

## ៤.៣. ការរៀបចំអនុសាសន៍ និងការរកឃើញបញ្ហាសិទ្ធិមនុស្ស

អនុសាសន៍និងការរកឃើញរបស់យន្តការសិទ្ធិមនុស្ស ទាំងតាមប្រធានបទ និងតាមប្រទេសនីមួយៗគឺមានច្រើន។ ការរៀបចំចងក្រង និងការរៀបចំដាក់ជាផ្នែក ជាក្រុម ទៅតាមប្រធានបទ ឬភូមិសាស្ត្រដែលត្រូវផ្តោត អាចជាការរៀបចំមួយមានប្រយោជន៍សម្រាប់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយដើម្បីតាមដាន។ ការរៀបចំអនុសាសន៍ និងការរកឃើញអាចៈ

- ▶ ជួយសម្រួលដល់លទ្ធភាពទទួលបានអនុសាសន៍
- ▶ លើកកម្ពស់ការយល់ដឹង និងជួយផ្សព្វផ្សាយអនុសាសន៍
- ▶ ជួយក្នុងការកសាងទិដ្ឋភាពរួមមួយនៃអនុសាសន៍ដែលមានស្រាប់ និងផ្តល់ជាមូលដ្ឋានមួយសម្រាប់យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយសម្រាប់ការតាមដាន
- ▶ ជួយសម្រួលដល់ការកំណត់បញ្ហាអាទិភាព និងការតាមដាន
- ▶ ប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំបង្កើតផែនការឃ្លាំមើល។

ឧបករណ៍ខាងក្រោមនេះ អាចជួយក្នុងដំណើរការនេះៈ



### សន្ទស្សន៍សិទ្ធិមនុស្សសកល

សន្ទស្សន៍សិទ្ធិមនុស្សសកល[3] គឺជាមូលដ្ឋានទិន្នន័យអនឡាញដែលចងក្រងអនុសាសន៍ ពីស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេស និង UPR។ សន្ទស្សន៍នេះអាចឲ្យអ្នកប្រើប្រាស់ចូលមើល និងស្វែងរកព័ត៌មានទាក់ទងនឹងស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេស និងអនុសាសន៍ UPR តាមរយៈប្រភេទផ្សេងៗជាច្រើនៈ រដ្ឋ សិទ្ធិ ស្ថាប័ន បុគ្គលដែលរងផលប៉ះពាល់ ក្របខ័ណ្ឌពេលវេលា និងសម្រាប់ UPR រដ្ឋដែលបានផ្តល់អនុសាសន៍ តួនាទីរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យរបាយការណ៍ និង សម័យប្រជុំ។ ដោយគ្រាន់តែចុចពីរបីដងប៉ុណ្ណោះ អ្នកស្វែងរកអាចមើលឃើញការវាយតម្លៃរបស់ស្ថាប័ននិងយន្តការ អ.ស.ប អំពីស្ថានភាពនៃការអនុវត្តសិទ្ធិមនុស្សនៅក្នុងបរិបទជាក់លាក់ណាមួយបាន។ ការរៀបចំបែបនេះ គឺធ្វើឲ្យព័ត៌មានដែលមានស្រាប់យ៉ាងច្រើនសន្ធឹកសន្ធាប់អំពីសិទ្ធិ មនុស្ស អ.ស.ប រិតតែមានតម្លាភាព និងអាចយកមកប្រើប្រាស់បាន។

[3] មាននៅលើវេបសាយ http://uhri.ohchr.org/

### ការរៀបចំអនុសាសន៍ជាក្រុម ក្នុងទ្វីបអាស៊ីកណ្តាល

នៅក្នុងប្រទេស គីជីស្ថាន (Kyrgyzstan), ការិយាល័យថ្នាក់តំបន់របស់ OHCHR ប្រចាំអាស៊ីកណ្តាល បានគាំទ្រស្ថាប័នអប់រំមួយដើម្បីបង្កើតអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស អ.ស.ប ជាក្រុមឲ្យបានច្បាស់លាស់ទៅតាមសិទ្ធិ រាប់ទាំងអនុសាសន៍ដែលបានមកពីស្ថាប័នសន្ធិសញ្ញា នីតិវិធីពិសេសផ្សេងៗ និងយន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (UPR)។ ការរៀបចំបែបនេះ គឺជាមូលដ្ឋានសម្រាប់រៀបចំផែនការការងារស្តីពីការអនុវត្តអនុ-សាសន៍។[4]

## ៤.៤. ការកំណត់បញ្ហាអាទិភាព និងការធ្វើផែនការ

តួអង្គសង្គមស៊ីវិល (CSAs) អាចយល់ឃើញថា អនុសាសន៍ខ្លះមានភាពពាក់ព័ន្ធ ច្រើនជាងអនុសាសន៍ដទៃទៀត។ អនុសាសន៍ខ្លះអាចទាក់ទងនឹងអាទិភាពប្រធានបទ ឬភូមិសាស្ត្ររបស់ CSAs ហើយអនុសាសន៍ខ្លះទៀត មិនពាក់ព័ន្ធនោះទេ។ ស្រដៀងគ្នានេះដែរ អនុសាសន៍ខ្លះអាចងាយតាមដាន រីឯអនុសាសន៍ដទៃទៀតទាមទារឲ្យមានធនធានដែលមិនអាចរកបាន។ អនុ-សាសន៍ខ្លះ អាចជាលទ្ធផលនៃការងាររៀបចំដែលសង្គមស៊ីវិលបានធ្វើជាមួយយន្តការសិទ្ធិមនុស្ស។ ការតាមដានអនុសាសន៍ទាំងនេះ ទំនងជានឹងត្រូវបានកំណត់អាទិភាព និងបានធ្វើ សមាហរណកម្មទៅក្នុងយុទ្ធសាស្ត្រ និងផែនការការងាររបស់CSAs។

### ទារុណកម្ម និងការប្រព្រឹត្តិមិនគប្បី ដែលតួអង្គឯកជនជាអ្នកប្រព្រឹត្តនៅប្រទេសកាណាដា

នៅឆ្នាំ២០១១ ក្លឹបចំនួន ១១០ ក្លឹបនៃសហព័ន្ធស្ត្រីសកលវិទ្យាល័យកាណាដា (CFUW) បានជំរុញឲ្យរដ្ឋាភិបាលកាណាដា ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើទារុណកម្ម ដែលតួអង្គឯកជនជាអ្នកប្រព្រឹត្ត។ ក្រមព្រហ្មទណ្ឌកាណាដា ដាក់ទោសអ្នកប្រព្រឹត្តអំពើទារុណកម្ម ដែលជាតួអង្គរដ្ឋ។ នៅពេលដែលឯកតបុគ្គលទទួលរងអំពើទារុណកម្មដូចគ្នានេះ ដែលប្រព្រឹត្តឡើងដោយបុគ្គលឯកជន ដូចជាករណីអំពើហិង្សាក្នុងគ្រួសារបុគ្គលទាំងនេះ មិនត្រូវបានគេដាក់ឲ្យទទួលខុសត្រូវចំពោះអំពីទារុណកម្មឡើយ។

នៅក្នុងខែមេសា ឆ្នាំ២០១២ CFUW បានបញ្ជូនរបាយការណ៍ស្រមោលមួយទៅគណៈ

[4] កម្រងនេះមាននៅលើវេបសាយ www.auca.kg

កម្មាធិការប្រឆាំងទារុណកម្ម (CAT)។ សមាជិក CFUW បានចូលរួមក្នុងសម័យប្រជុំក្នុងខែ ឧសភា របស់គណៈកម្មាធិការនេះក្នុងទីក្រុងហ្សឺណែវ។ សមាជិក CFUW ពីររូបបានអធិប្បាយថា " យើងបានឮថាគណៈកម្មាធិការនេះ បញ្ជាក់យ៉ាងច្បាស់ប្រាប់គណៈប្រតិភូនៃរដ្ឋាភិបាលកាណាដាថាទម្រង់ខ្លះនៃអំពើហិង្សាផ្អែកលើយេនឌ័រ គឺជាសក្ខីកម្មបង្ហាញពីអំពើទារុណកម្ម នៅពេលដែលតួអង្គមិនមែនរដ្ឋជាអ្នកប្រព្រឹត្ត ហើយថាអំពើទាំងនេះស្ថិតក្រោមអានុភាពនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក។ វាជាការខំពុះពារមួយដើម្បីសមភាពយេនឌ័រ និងសិទ្ធិមនុស្សដែលមិនអាចបដិប្បញ្ញត្តិបានរបស់ស្ត្រីនិងកុមារី ដែលមិនមែនជាកម្មវត្ថុនៃការធ្វើទារុណកម្មដែលតួអង្គមិនមែនរដ្ឋជាអ្នកប្រព្រឹត្ត។ សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការប្រឆាំងទារុណកម្ម (CAT) គឺជាការខំពុះពារដ៏ធំមួយសម្រាប់យើង ហើយយើងអាចប្រើប្រាស់វានៅក្នុងការងាររបស់យើង"។ ដោយធ្វើការតាមដានសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការនេះCFUWបានបញ្ជូនសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរមួយទៅគណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី និងបានគាំទ្រការដាក់បញ្ជូនរបាយការណ៍មួយសម្រាប់ការពិនិត្យជាសកលតាមកាលកំណត់ (UPR) របស់ប្រទេសកាណាដា ដោយកសាងបន្ថែមពីលើសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការប្រឆាំងទារុណកម្ម (CAT) ស្តីពីទារុណកម្ម និងការប្រព្រឹត្តមិនគប្បីដែលតួអង្គឯកជនជាអ្នកប្រព្រឹត្ត។

ដោយមាន ឬដោយគ្មានការចូលរួមក្នុងដំណាក់កាលកន្លងមកនៃវដ្តការងាររបស់យន្តការសិទ្ធិមនុស្ស CSAs បានរកឃើញថា ការកំណត់អាទិភាពដល់អនុសាសន៍ និង ការរកឃើញដែលមានស្រាប់ ដោយកំណត់យកអនុសាសន៍ និងការរកឃើញទាំងឡាយណាដែលទាក់ទងនឹងគោលដៅសិទ្ធិមនុស្សផ្ទាល់របស់ពួកគេ គឺជាជំហានដ៏សំខាន់មួយនៅក្នុងការរៀបចំបង្កើតផែនការតាមដានដែលមានលក្ខណៈប្រាកដនិយម។ CSAs អាចប្រើសំណុំផ្សេងៗនៃលក្ខណៈវិនិច្ឆ័យដើម្បីកំណត់បញ្ហាអាទិភាពនៃអនុសាសន៍ ដូចជា៖

- អនុសាសន៍ដែលយន្តការឬស្ថាប័នសិទ្ធិមនុស្សបានដាក់ចេញ ដែលពង្រឹងបន្ថែមលើអនុសាសន៍របស់ CSAs
- អនុសាសន៍ដែលស្របនឹងគោលដៅ និងសកម្មភាពរបស់ CSAs ដែលការតាមដានរបស់ខ្លួន អាចត្រូវបានធ្វើសមាហរណកម្មយ៉ាងពិតប្រាកដ ទៅក្នុងផែនការការងាររបស់ពួកគេ
- អនុសាសន៍ និងការរកឃើញ ដែលបង្ហាញពីភាពជឿនលឿនថ្មីមួយ ក្នុងការបកស្រាយនិងអនុវត្តច្បាប់សិទ្ធិមនុស្ស
- អនុសាសន៍ដែលការអនុវត្តរបស់វា អាចកើតមានដោយសារតែកត្តាមួយចំនួន (ឧទា. រដ្ឋបានកំណត់អាទិភាពសម្រាប់ការអនុវត្ត សម្ភាធ និង/ឬជំនួយរបស់សហគមន៍អន្តរជាតិ ធនធាន

ដែលមាន )

▶ អនុសាសន៍ដែលសង្គមស៊ីវិលដែលអាចតាមដាន តាមរយៈការធ្វើការជាមួយភាគីដទៃទៀតនៅក្នុងសម្ព័ន្ធភាព

▶ អនុសាសន៍ដែលការអនុវត្តរបស់វា CSAs អាចធ្វើការវាស់វែងបាន

▶ អនុសាសន៍ដែលអាចនឹងទុកចោលមិនរវល់ ប្រសិនបើគ្មានសកម្មភាពរបស់ CSA និង

▶ អនុសាសន៍ដែលផ្ញើដោយចំពោះទៅសង្គមស៊ីវិល (ឧទា. អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ផ្ញើជូនសហគមន៍អ្នកការពារសិទ្ធិមនុស្ស )។

## ការកំណត់អាទិភាពអនុសាសន៍ UPR ទាក់ទងទៅនឹងប្រធានបទនៃការមិនរើសអើងផ្អែកលើយេនឌ័រ និងអត្តសញ្ញាណយេនឌ័រ

លំហាត់ក្នុងការកំណត់អាទិភាព UPR និងការបង្កើតផែនការការងារបឋមមួយ អាចសង្ខេបដូចខាងក្រោម៖

| អនុសាសន៍ UPR | អាទិភាព | ប្រភេទនៃការតាមដាន និងសកម្មភាពចម្បង | ស្ថាប័នទទួលខុសត្រូវ និងធនធាន | គម្រោងពេល | សូចនាករ |
|---|---|---|---|---|---|
| ពង្រឹងកិច្ចការពារផ្អែកច្បាប់ប្រឆាំងការរើសអើងដើម្បីដាក់បញ្ចូលទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រជាមូលដ្ឋាននៃការហាមឃាត់ការរើសអើង | អាទិភាព។ ចំណុចសំខាន់ដែលរដ្ឋាភិបាលអាចមើលរំលងប្រសិនបើមិនមានការលើកទឹកចិត្តដោយ CSAs និងសហគមន៍អន្តរជាតិ | ស្វែងរកការគាំទ្រ។ ស្វែងរកការគាំទ្រពីសមាជិកសភា។ ចូលរួមក្នុងការធ្វើសេចក្តីព្រាងច្បាប់។ យុទ្ធនាការ។ | អង្គការ LGBT ក្នុងភាពជាដៃគូជាមួយ CSAs ដទៃទៀត។ ជាផ្នែកមួយនៃសកម្មភាពកំពុងបន្ត | ៤ឆ្នាំបន្ទាប់ | ទំនោរផ្លូវភេទ និងអត្តសញ្ញាណជាមូលហេតុនៃការឃាត់ការរើសអើងនៅក្នុងច្បាប់គ្មានការរើសអើង |
| ផ្តួចផ្តើម ឬចូលរួមយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈដើម្បីលើកទឹកចិត្តឲ្យមានការខន្តីចំពោះមនុស្សដែលស្រឡាញ់ភេទដូចគ្នាមនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សបំលែងភេទ | អាទិភាព។ សូមមើលខាងលើ | ចូលរួមក្នុងយុទ្ធនាការ។ស្នើឲ្យផ្តោតគោលដៅលើសាធារណជនទូទៅ និងភ្នាក់ងារអនុវត្តច្បាប់។ បរិស្ថានដែលត្រូវផ្តោតគោលដៅលើៈសាលាមធ្យមសិក្សា; សកលវិទ្យាល័យ;ក្លឹបកីឡា; មជ្ឈមណ្ឌលបណ្តុះបណ្តាលនគរបាល | អង្គការ LGBT ក្នុងភាពជាដៃគូជាមួយ CSAs ដទៃទៀត។ ធនធានបន្ថែម នឹងត្រូវស្វែងរកក្នុងពេលខាងមុខ។ | ៤ឆ្នាំបន្ទាប់ | យុទ្ធនាការត្រូវបានអនុវត្តប្រភេទនៃក្រុមគោលដៅដែលគ្របដណ្តប់។ |
| បន្តដោះស្រាយបញ្ហាវិសមភាពយេនឌ័រ | ចំនួន កំណត់ស្រពិចស្រពិលពេក | | | | |

| អនុសាសន៍ UPR | អាទិភាព | ប្រភេទនៃការតាមដាន និងសកម្មភាពចម្បង | ស្ថាប័នទទួលខុសត្រូវ និងធនធាន | គម្រោងពេល | សូចនាករ |
|---|---|---|---|---|---|
| បន្តពង្រឹងស្ថាប័ន និងគោលនយោបាយបង្ការទាក់ទងនឹងបញ្ហាយេនឌ័រ និងការរើសអើងប្រឆាំងស្ត្រី | អាទិភាព។ រដ្ឋាភិបាលគួរត្រូវបានលើកទឹកចិត្តឲ្យពង្រឹងសមភាព ផ្តល់ដល់ស្ថាប័ននូវធនធានបន្ថែមទៀត | ការត្រួតពិនិត្យតាមដាន និងតស៊ូមតិ។ត្រួតពិនិត្យតាមដានធនធានថវិកាដែលវិភាជទៅឲ្យក្រសួង សម្រាប់ឱកាសស្មើភាព។ ត្រួតពិនិត្យតាមដានគំនិតផ្តួចផ្តើមដែលបានស្នើឡើងដោយក្រសួងត្រូវបានពិចារណា និងអនុវត្តដោយរដ្ឋាភិបាល | អង្គការស្ត្រីក្នុងភាពជាដៃគូជាមួយ CSAs ដទៃទៀត។ ជាផ្នែកមួយនៃសកម្មកំពុងបន្ត។ ត្រូវការស្វែងរកជំនាញបន្ថែមទៅការត្រួតពិនិត្យតាមដានថវិកា | ៤ឆ្នាំបន្ទាប់ | ធនធានដែលបានវិភាជដល់ក្រសួងសម្រាប់ឱកាសស្មើភាព។សំណើគោលនយោបាយដោយក្រសួងត្រូវបានអនុម័ត និងអនុវត្តដោយរដ្ឋាភិបាល។ |
| ផ្តល់អាទិភាពដល់ការអនុវត្តកំណែទម្រង់ច្បាប់នាពេលថ្មីៗដើម្បីលុបបំបាត់បទប្បញ្ញត្តិដែលរើសអើងប្រឆាំងស្ត្រីដោយអនុលោមតាម CEDAW. | អាទិភាព។ ដល់ពេលដែលត្រូវមានក្របខ័ណ្ឌច្បាប់មួយដែលមិនរើសអើង | ត្រួតពិនិត្យតាមដានមើលច្បាប់។ ផ្នែកមួយនៃការតាមដានមើលសេចក្តីសង្កេតចុងក្រោយរបស់ CEDAW. | អង្គការស្ត្រី ក្នុងភាព ជាដៃគូជាមួយ CSAs ដទៃទៀត។ ផ្នែកមួយនៃសកម្មភាពកំពុងបន្ត | របាយការណ៍បន្ទាប់ក្រោម CEDAW | បទប្បញ្ញត្តិរើសអើងដូចដែលបានកំណត់ដោយ CEDAW ត្រូវបានលុបចោល។ |
| ចាត់វិធានការជាក់លាក់ដើម្បីភ្ជិតគម្លាតប្រាក់ឈ្នួលរវាងស្ត្រីនិងបុរស | មិនមែនជាអាទិភាពប៉ុន្តែគាំទ្រដោយ CSAs។ ហួសពីសមត្ថភាពរបស់ CSAs ក្នុងការតាមដាន។ | | | | |

| អនុសាសន៍ UPR | អាទិភាព | ប្រភេទនៃការតាមដាន និង សកម្មភាពចម្បង | ស្ថាប័នទទួលខុសត្រូវ និងធនធាន | គម្រោងពេល | សូចនាករ |
|---|---|---|---|---|---|
| ដោយសហការជាមួយសង្គមស៊ីវិល បង្កើតយុទ្ធសាស្ត្រលម្អិតមួយសំដៅលុបបំបាត់ទម្លាប់វប្បធម៌ប្រកបដោយគ្រោះថ្នាក់ និងផ្តត់គំនិតរើសអើងប្រឆាំងស្ត្រី។ | អាទិភាព។ សកម្មភាពនេះត្រូវបានផ្តល់អាទិភាពដោយសម្ព័ន្ធភាព និងអនុសាសន៍ដែលរំពឹងទុកនៅក្នុងតួនាទីច្បាស់លាស់សម្រាប់សង្គមស៊ីវិល | ចូលរួមក្នុងការបង្កើតយុទ្ធសាស្ត្រ។ | អង្គការស្ត្រី ក្នុងភាពជាដៃគូជាមួយអង្គការស្ត្រីសហប្រជាជាតិ (UN Women) | មួយឆ្នាំ | យុទ្ធសាស្ត្រត្រូវបានអនុម័ត។ |
| ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបាត់ពលកម្មកុមារ តែលម្អការសម្របសម្រួលក្នុងចំណោមស្ថាប័នជាតិនានាដែលធ្វើការជាមួយសិទ្ធិកុមារ។ | ទេ។ ស្ថិតនៅក្រៅវិសាលភាពនៃសកម្មភាពរបស់ CSAs ដែលពាក់ព័ន្ធ។ | | | | |

## ៤.៥. ការឃ្លាំមើលការអនុវត្ត

ការឃ្លាំមើលការអនុវត្តអនុសាសន៍របស់រដ្ឋ គឺជាសកម្មភាពដ៏សំខាន់មួយសម្រាប់សង្គមស៊ីវិល ដើម្បីធានាគណនេយ្យភាពរបស់រដ្ឋាភិបាល។ វាអាចជាការដែល CSAs ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីថាតើរដ្ឋបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សជាក់លាក់មួយឬទេ ថាតើរដ្ឋបានអញ្ជើញនីតិវិធីពិសេស មកធ្វើទស្សនកិច្ចក្នុងប្រទេស ឬទេថាតើរដ្ឋបានអនុម័តច្បាប់ស្តីពីការមិនរើសអើង ឬថាតើបានអនុវត្តដំណើរការឃ្លាំមើលដ៏ស្មុគស្មាញពាក់ព័ន្ធនឹងការប្រមូល និងការបន្ថែមទិន្នន័យដែលមានទំហំធំពីប្រភពផ្សេងៗ និងនៅទីកន្លែងផ្សេងៗ ជាច្រើន ឬការវិភាគព័ត៌មានទាក់ទងទៅនឹងសូចនាករ និងគោលរង្វាស់រយៈពេលមួយដែលបានកំណត់។ ការឃ្លាំមើលប្រភេទអ្វីក៏ដោយដែលបានធ្វើ ទោះជាមានលក្ខណៈសាមញ្ញ ឬស្មុគស្មាញក្តី អ្វីដែលសំខាន់នោះគឺការរកឃើញត្រូវតែពិត និងអាចជឿទុកចិត្តបាន។ ការរកឃើញទាំងនេះ អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់តស៊ូមតិជាមួយរដ្ឋាភិបាលជាតិ និងរៀបចំជារបាយការណ៍ដាក់ជូនយន្តការសិទ្ធិមនុស្ស ឧទា. វដ្តទីពីរ ឬទីបីនៃ UPR សម្រាប់ការពិនិត្យលើកក្រោយរបស់ស្ថាប័នសន្ធិសញ្ញា ជាការរាយការណ៍ផ្ទាល់មាត់ដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ សៀវភៅណែនាំស្តីពីការឃ្លាំមើលសិទ្ធិមនុស្សរបស់ការិយាល័យ OHCHR[5] ផ្តល់ការណែនាំលម្អិតអំពីវិធីសាស្ត្រឃ្លាំមើល ជាការប្រមូលផ្ទៀងផ្ទាត់ វិភាគ និងប្រើប្រាស់សកម្មនូវព័ត៌មាន ដើម្បីវាយតម្លៃ និងដោះស្រាយកង្វល់សិទ្ធិមនុស្ស។ យោងតាមនិយមន័យនេះការឃ្លាំមើលកើតមានសម្រាប់រយៈពេលវែងមួយ។ ដំណើរការឃ្លាំមើលទាំងមូលត្រូវបាននិយាយសំដៅផងដែរថាជាវដ្តនៃការឃ្លាំមើលសិទ្ធិមនុស្ស (សូមមើលខាងក្រោម)។

### វដ្តនៃការឃ្លាំមើល




[5] សៀវភៅណែនាំស្តីពីការឃ្លាំមើលសិទ្ធិមនុស្ស (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ HR/P/PT/7/Rev.1).

## ការឃ្លាំមើលការទទួលបានព័ត៌មាន និងសម្ភារៈផ្សេងៗ នៅស្ថានីយបោះឆ្នោត នៅទីក្រុងហុងកុង

ចិន រួមទាំងហុងកុងផងដែរ ត្រូវបានពិនិត្យឡើងវិញដោយគណៈកម្មាធិការសិទ្ធិជនពិការ (CRPD) ក្នុងខែកញ្ញា ឆ្នាំ២០១២។ អ្នកស្វ័យតស៊ូមតិ (self-advocates) មួយក្រុមមកពីអង្គការអំណាចបានដោយជ្រើសរើស (ឬហៅកាត់ថា អង្គការ Chosen Power) បានចូលរួមក្នុងសម័យប្រជុំរបស់គណៈកម្មាធិការ CRPD លើកទី៧ និងទី៨ ដើម្បីផ្តល់ព័ត៌មានអំពីរបៀបដែលរដ្ឋាភិបាលរបស់ពួកគេលើកកម្ពស់សិទ្ធិរបស់ពួកគេ និងបានប្រើប្រាស់បទពិសោធន៍នេះ ក្នុងការងារតស៊ូនៅទីក្រុងហុងកុង។ អង្គការ Chosen Power គឺជាអង្គការស្វ័យតស៊ូមតិនិង ជួយខ្លួនឯងដំបូងគេបំផុត គ្រប់គ្រងដោយបុគ្គលមួយចំនួនដែលមានសមត្ថភាពចំណេះដឹងផ្សេងៗគ្នានៅអាស៊ី ហើយការចូលរួមរបស់ពួកគេទៀតសោធ នៅទីក្រុងហ្ស៊ឺណែវ គឺជាលើកដំបូងផងដែរតំណាងឲ្យបុគ្គលដែលមានពិការភាពខាងសតិបញ្ញា បានថ្លែងការណ៍ទៅកាន់គណៈកម្មាធិការនេះ។

បន្ទាប់ពីសម័យប្រជុំលើកទី៧ ដែលក្នុងនោះមានការអនុម័តបញ្ជីបញ្ហា ដែលអង្គការ Chosen Power បានព្យាយាមបញ្ចុះបញ្ចូល សម្រាប់ការទទួលបានព័ត៌មាននិងសម្ភារៈនៅស្ថានីយបោះឆ្នោតសម្រាប់ជនដែលមានពិការភាពខាងសតិបញ្ញា និងសម្រាប់សិទ្ធិទទួលបានការអមដំណើរទៅកាន់បន្ទប់បោះឆ្នោត ដោយមានការគាំទ្រពីបុគ្គលដែលពួកគេជ្រើសរើសដោយខ្លួនឯង។ ពួកគេបាន ជួបជាមួយមន្ត្រីការិយាល័យចុះឈ្មោះ និងបោះឆ្នោតនៅក្នុងខែកក្កដា ឆ្នាំ២០១២ ដើម្បីលើកបញ្ហាទាំងនេះ ក៏ដូចជា បញ្ហាមិនអាចទៅបោះឆ្នោតបាន សម្រាប់ជនដែលពិការភ្នែក ឬអន់ភ្នែក ភាពមិនអាចទៅបោះឆ្នោតបានរបស់ជនដែលរស់នៅក្នុងស្ថាប័ន និងការពិតដែលថា ជនដែលត្រូវបានគេចាត់ទុកថា “បាត់បង់សមត្ថភាពខាងសតិ” ត្រូវបានគេដកហូតសិទ្ធិបោះឆ្នោតរបស់ពួកគេ។

ការបោះឆ្នោតត្រូវបានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១២ ហើយអង្គការ Chosen Power បានឃ្លាំមើលទិដ្ឋភាពជាច្រើននៃការបោះឆ្នោត។ ពួកគេបានរកឃើញថា វេបសាយបោះឆ្នោត មិនអាចចូលមើលបាន ហើយថាពួកគេត្រូវរង់ចាំរយៈពេលដ៏យូរ ដើម្បីទទួលបានមគ្គុទ្ទេសក៍បោះឆ្នោត “ងាយស្រួលអាន” នៅតាមស្ថានីយបោះឆ្នោត ហើយពេលនោះ ពួកគេមានអារម្មណ៍ថា ការជួយឧបត្ថម្ភដែលបាន ផ្តល់នៅតាមស្ថានីយបោះឆ្នោត មិនបានគោរពពេញលេញនូវស្វយ័តភាព និង ការសម្ងាត់របស់ពួកគេឡើយ។

លទ្ធផលវិជ្ជមានមួយនៃការចូលរួមក្នុងដំណើរការពិនិត្យរបស់គណៈកម្មាធិការ CRPD គឺការកៀងគរអង្គការជនពិការ និង CSAs ឲ្យរួមកម្លាំងគ្នាជាសម្ព័ន្ធភាពមួយដែលបានជួយបញ្ច្រាប។

បញ្ហាពិការភាពទៅក្នុងសង្គមស៊ីវិលយ៉ាងទូលំទូលាយ។ នៅទីក្រុងហុងកុង អង្គការទាំងនេះបានធ្វើការរួមគ្នាផងដែរ ដើម្បីរួមចំណែកដល់ការដាក់របាយការណ៍ទៅគណៈកម្មាធិការសិទ្ធិមនុស្ស សម្រាប់បញ្ជីបញ្ហាស្តីពីហុងកុង ដែលក្នុងនោះពួកគេបានលើកផងដែរអំពីសិទ្ធិរបស់ពួកគេក្នុងការ ចូលរួមក្នុងជីវភាពនយោបាយ ដើម្បីបង្កើនការដាក់សម្ពាធទៅលើរដ្ឋាភិបាលឲ្យ ធ្វើការផ្លាស់ប្តូរដែលចាំបាច់សម្រាប់ការចូលរួមរបស់ពួកគេ ដោយស្មើភាពគ្នា។

## ការប្រើប្រាស់សូចនាករសិទ្ធិមនុស្ស ដើម្បីឃ្លាំមើលការអនុវត្ត

សូចនាករបរិមាណនិងគុណភាព ផ្អែកលើវិធីសាស្រ្តដ៏សមស្របនិងមានតម្លាភាព អាចត្រូវបានប្រើប្រាស់ដើម្បីត្រួតពិនិត្យតាមដានមើលការអនុវត្តអនុសាសន៍។ ឧទាហរណ៍ សូចនាករដើម្បីផ្ទៀងផ្ទាត់ការអនុវត្តអនុសាសន៍មួយ ដើម្បីអនុម័តច្បាប់មួយស្តីពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ អាចជាកាលបរិច្ឆេទនៃការចូលជាធរមាន និងវិសាលភាពរបស់ច្បាប់នេះ។

អនុសាសន៍មួយទៀតនៅក្នុងផ្នែកនេះអាចជា“បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនការទទួលបានសេវាការពារកំណើតប្រកបដោយសុវត្ថិភាព និងមានតម្លៃសមរម្យនៅទូទាំងប្រទេស”។ សូចនាករមួយស្តីពីសមាមាត្រស្រ្តី ឬដៃគូរបស់ពួកគេ ប្រើមធ្យោបាយការពារកំណើត អនុញ្ញាតឲ្យភាគីពាក់ព័ន្ធធ្វើការវាយតម្លៃកម្រិតនៃការអនុវត្ត។ ទិន្នន័យស្តីពីការប្រើមធ្យោបាយការពារកំណើត ត្រូវបានផលិតឡើងដោយនាយកដ្ឋានប្រជាជននៃអង្គការសហប្រជាជាតិដោយប្រើប្រាស់ការស្ទង់ភាពជាតំណាងនៅថ្នាក់ជាតិ។

នៅពេលប្រមូលទិន្នន័យសម្រាប់សូចនាករ សំខាន់ត្រូវមាន ទិន្នន័យបំបែកជា ក្រុមផ្នែកតូចៗ ដើម្បីក្តោបលើទិដ្ឋភាពរើសអើងនៃស្ថានភាពណាមួយ។នៅក្នុងបញ្ជីសង្ខេបនិងអាស្រ័យលើអ្វីដែលពាក់ព័ន្ធនិងអាចអនុវត្តបានក្នុងបរិបទនីមួយៗ សូចនាករអាចត្រូវបានបំបែកជាក្រុមជាផ្នែកតូចៗដោយផ្អែកលើជាតិ សាសន៍ ពណ៌សម្បុរ ភេទ អាយុ ភាសា សាសនា ទស្សនៈនយោបាយ ឬជំនឿទស្សនៈទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិ កំណើត ពិការភាពផ្លូវកាយ ឬផ្លូវចិត្ត ស្ថានភាពសុខភាព (រួមទាំងមេរោគអេដស៍/ជំងឺអេដស៍) ទំនោរផ្លូវភេទ និងស្ថានភាពពលរដ្ឋ នយោបាយ ឬស្ថានភាពដទៃទៀត។ នៅពេលបានកំណត់សូចនាករពាក់ព័ន្ធ ហើយសំខាន់ត្រូវកំណត់ពីគោលរង្វាស់ ដើម្បីជម្រុញឲ្យរដ្ឋសន្យា និងអនុវត្តអនុសាសន៍ទាំងនោះ។

ឃ្លាំមើលសង្គម[6] និងមជ្ឈមណ្ឌលសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច[7] គឺជាអង្គការដែលមានបទពិសោធន៍យ៉ាងច្រើន ក្នុងការប្រើប្រាស់សូចនាករដើម្បីតាមដានការអនុវត្តអនុសាសន៍។[8]

[6] មាននៅលើវេបសាយ www.socialwatch.org

[7] មាននៅលើវេបសាយ www.cesr.org

[8] សម្រាប់ការណែនាំបន្ថែមអំពីសូចនាករ សូមមើលសូចនាករសិទ្ធិមនុស្ស - មគ្គុទ្ទេសក៍សម្រាប់វាស់វែងនិងការអនុវត្ត (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ HR/PUB/12/5).

## ៤.៦. ការចាប់យកឱកាស

ការពិនិត្យស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយ ដោយយន្តការសិទ្ធិមនុស្ស អ.ស.អ ឬទស្សនកិច្ចរបស់អ្នកកាន់អាណត្តិនីតិវិធីពិសេស ជារឿយៗ អាចបង្កើតជាឱកាសសំខាន់ៗ ដូចជា៖

▶ ទាញការយកចិត្តទុកដាក់ដែលមិនធ្លាប់មានពីមុនមកពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ លើស្ថានភាពសិទ្ធិមនុស្ស;

▶ ភាពបើកចំហរបស់អាជ្ញាធររដ្ឋក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្សមួយចំនួន នៅថ្នាក់កណ្តាល ឬថ្នាក់មូលដ្ឋាន;

▶ ដៃគូរសន្ទនាថ្មីនៅក្នុងរដ្ឋាភិបាល ត្រៀមខ្លួនចូលរួមក្នុងកិច្ចសន្ទនាជាមួយសង្គមស៊ីវិល

▶ បន្តការជំរុញឲ្យចាត់វិធានការលើកកម្ពស់សិទ្ធិមនុស្ស

▶ ការបង្ហាញពីឆន្ទៈនយោបាយ ក្នុងការអនុម័តច្បាប់ស្របតាមបទដ្ឋានសិទ្ធិមនុស្ស

▶ ការមានធនធានថ្មី ដើម្បីធ្វើការក្នុងវិស័យមួយថ្មី ដែលបានបង្កើតឡើង និង

▶ ភាពជាដៃគូ ឬសម្ព័ន្ធភាពជាមួយដែលបានបង្កើតឡើង ឬបានពង្រឹងសម្រាប់ការពិនិត្យ ។

CSAs អាចដើរតួនាទីមួយដ៏សំខាន់ ក្នុងការបង្កើតឱកាសជុំវិញសកម្មភាពរបស់យន្តការសិទ្ធិមនុស្ស និងក្នុងការចាប់យកកាលានុវត្តភាពបែបនេះដើម្បីជំរុញយុទ្ធសាស្ត្រ សម្រាប់ការការពារសិទ្ធិមនុស្សឲ្យកាន់តែប្រសើរឡើងថែមទៀត។

## ៤.៧. ការបង្កើត និងការធ្វើការជាមួយសម្ព័ន្ធភាព

ការចូលរួមក្នុងការងាររបស់យន្តការសិទ្ធិមនុស្សតាមរយៈសម្ព័ន្ធភាព CSA ជារឿយៗ បានផ្តល់លទ្ធផលវិជ្ជមានជាច្រើន។ ឧទាហរណ៍ រួមមាន៖

▶ របាយការណ៍កាន់តែគ្រប់ជ្រុងជ្រោយថែមទៀត ទៅយន្តការសិទ្ធិមនុស្ស ដោយបានបង្កើនលទ្ធភាព អាចឲ្យអនុសាសន៍កាន់តែឆ្លុះបញ្ចាំងពីអាទិភាពដែលសម្ព័ន្ធភាពបានកំណត់។

▶ ការបែងចែកការងារក្នុងចំណោមអង្គការជាសមាជិកនៃសម្ព័ន្ធភាព ទៅតាមឯកទេស ធនធាន និងជំនាញ នាំឲ្យការចូលរួមនិងការតាមដានកាន់តែមានប្រសិទ្ធភាពថែមទៀត (ឧទា. អង្គការខ្លះនឹងផ្តោតលើការតស៊ូមតិ ឬការផ្សព្វផ្សាយ អង្គការខ្លះទៀតផ្តោតលើការឃ្លាំមើលការប្រមូល និងការវិភាគទិន្នន័យ រាប់ទាំងព័ត៌មាន និងទិន្នន័យបច្ចេកទេស អង្គការមួយចំនួនទៀតផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស និងជួយធ្វើឲ្យមតិយោបល់ និងសក្ខីកម្មរបស់ពួកគេ បានដឹងឮជាសាធារណៈ ។

▶ ពង្រឹងទំនាក់ទំនងការងារសហប្រតិបត្តិការនិងសាមគ្គីភាពក្នុងចំណោម CSAs ឲ្យកាន់

តែប្រសើរឡើង។ ការនេះរិតតែសំខាន់ថែមទៀត នៅពេល CSAs អាចស្ថិតក្នុង ការគំរាមកំហែង។

▶ ពង្រឹងឥទ្ធិពលនិងភាពជឿទុកចិត្តរបស់សម្ព័ន្ធភាពឲ្យកាន់តែច្រើនថែមទៀត ដោយមានសារ និងគោលបំណងតែមួយ ទាក់ទងទៅនឹងយុទ្ធការសិទ្ធិមនុស្ស អាជ្ញាធររដ្ឋ និងភាគីពាក់ព័ន្ធដទៃទៀត (ឧទា. បេសកកម្មការទូត ស្ថាប័នសិទ្ធិមនុស្សជាតិ)។

▶CSAsតូចៗទាក់ទាញការយកចិត្តទុកដាក់កាន់តែច្រើនថែមទៀតនៅពេលបញ្ហារបស់ពួកគេត្រូវបានលើកឡើងតាមរយៈសម្ព័ន្ធភាព។

## សម្ព័ន្ធភាព CSA ធ្វើឲ្យមានវឌ្ឍនភាព ក្នុងការបង្ការទារុណកម្ម តាមរយៈ UPR ក្នុងហ្វីលីពីន

ក្រុមសកម្មភាពវេជ្ជសាស្ត្រ (MAG) បានចូលរួមក្នុងការរៀបចំរបាយការណ៍រួមគ្នារបស់សង្គមស៊ីវិលសម្រាប់ UPR ស្តីពីហ្វីលីពីន។ មុនពេល UPR ប្រព្រឹត្តទៅក្នុងខែឧសភា ឆ្នាំ២០១២ សមាជិកសម្ព័ន្ធភាព CSA បានរៀបចំកិច្ចប្រជុំការទូតមួយនៅទីក្រុងម៉ានីល ដែលមានស្ថានទូតប្រមាណជា ២០ បានចូលរួម ។ នៅទីក្រុងហ្សឺណែវ ក្រុមនេះបានបើកកិច្ចប្រជុំជាមួយ បេសកកម្មការទូតចំនួន១៦ ដើម្បីផ្សព្វផ្សាយកង្វល់របស់ពួកគេ។ សមាជិកសម្ព័ន្ធភាពនេះបានបញ្ជាក់ថា "យើងអាចពាំនាំកង្វល់ជាអាទិភាពរបស់យើងក្នុងលក្ខណៈមួយដែលជាក់លាក់ និងច្បាស់លាស់ ដោយចងផ្តុំជាព័ត៌មាននៅលើទំព័រពិតមួយទំព័រអំពីបញ្ហានីមួយៗ"។ "តម្លៃធំធេងនៃ ការងារជាសម្ព័ន្ធភាពរបស់ CSAs ក្នុងការដាក់បញ្ជូនរបាយការណ៍ និងក្នុងការបញ្ចុះបញ្ចូលរដ្ឋាភិបាលនៅក្នុងដំណើរការ UPR បាននាំឲ្យ អនុសាសន៍កាន់តែពាក់ព័ន្ធខ្លាំងឡើងថែមទៀត។ការនេះបានជួយសម្រួលផងដែរដល់ការតាមដាននិងការចូលរួមយ៉ាងសកម្មរបស់យើងជាមួយរដ្ឋាភិបាល ស្តីពីការអនុវត្តអនុសាសន៍របស់ពួកគ" ។

បច្ចុប្បន្ននេះ MAG និងសម្ព័ន្ធភាពរួបរួមប្រឆាំងទារុណកម្ម (UATC)-ហ្វីលីពីន កំពុងតែប្រើប្រាស់អនុសាសន៍ UPR ដើម្បីគាំទ្រដល់ការងាររបស់ពួកគេក្នុងការបង្ការទារុណកម្ម។ "យើងប្រើអនុសាសន៍ UPR ក្នុងការងារឃ្លាំមើល របស់យើង និងក្នុងសកម្មភាពតស៊ូមតិរបស់យើង ដែលផ្តោតលើការបង្កើនការបង្ហាញឲ្យឃើញជាសាធារណៈ នូវទិដ្ឋភាពវេជ្ជសាស្ត្រនៃទារុណកម្ម រាប់ទាំងការចងក្រងជាឯកសារ ផ្អែកលើពិធីសារអ៊ីស្តាន់ប៊ុល និងការបង្កើនកម្មវិធីស្តារនីតិសម្បទាសម្រាប់អ្នកនៅមានជីវិតក្រោយពីការធ្វើទារុណកម្ម និងក្រុមគ្រួសាររបស់ពួកគេ។ អនុសាសន៍ UPR ផ្តល់ផលជាច្រើន ក្នុងការកសាងសមត្ថភាពនៃចលនាបង្ការទារុណកម្មនៅហ្វីលីពីន"តំណាងមួយរូបរបស់ MAG បានមានប្រសាសន៍ដូច្នេះ" ។

## ផែនទីបង្ហាញផ្លូវអនុវត្តអនុសាសន៍ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅប្រទេសស្វីស

សម្ព័ន្ធភាពស្វីសស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (Coalition Suisse Romande sur les droits "conomiques, sociaux et culturels) បានផ្តួចផ្តើមគំនិតតាមដានការអនុវត្តសេចក្តីសង្កេតចុងក្រោយស្តីពីប្រទេសស្វីសរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ សម្ព័ន្ធភាពនេះបានអញ្ជើញ CSAs ដែលមានជំនាញឯកទេស ក្នុងវិស័យផ្សេងៗដូចបានឆ្លុះបញ្ចាំងក្នុងសេចក្តីសង្កេតចុងក្រោយ ដើម្បីរួមចំណែកផ្តល់សេចក្តីពន្យល់អំពីអ្វីដែលតម្រូវឲ្យមាន ដើម្បីអនុវត្តអនុសាសន៍នីមួយៗ។ រាល់សេចក្តីផ្តល់មតិ ត្រូវបានចងក្រងជាគោលការណ៍ណែនាំជាក់ស្តែងដែលបានចែករំលែក និងបានពិភាក្សាក្នុងកិច្ចពិភាក្សាតុមូលជាមួយមន្ត្រីរដ្ឋាភិបាល។

ទន្ទឹមនឹងបទពិសោធន៍បង្ហាញថា ការធ្វើការជាមួយសម្ព័ន្ធភាពជាទូទៅ បាននាំមកនូវលទ្ធផលល្អ មេរៀនដែលបានទទួលពីការអនុវត្តកន្លងមកក៏បានសំគាល់ឃើញបញ្ហាប្រឈមមួយចំនួនរួមមាន៖

- ធនធាន និងពេលវេលាទាក់ទងនឹងការងារសម្របសម្រួល។
- ការឯកភាពគ្នាលើអាទិភាព និងតួនាទី។
- រក្សាកម្លាំងជម្រុញ និងវត្តុបំណងនៃសម្ព័ន្ធភាព។
- ការមូលមតិគ្នា អាចជួយដោះស្រាយបញ្ហាបានខ្លះ។

## ការប្រយុទ្ធប្រឆាំងនឹងការរើសអើងពូជសាសន៍នៅប្រទេសជប៉ុន

បណ្តាញអង្គការមិនមែនរដ្ឋាភិបាលជប៉ុនដើម្បីលុបបំបាត់ការរើសអើងជាតិសាសន៍ (ERD Net) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧ បន្ទាប់ពីទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេស អំពីទម្រង់បច្ចុប្បន្ននៃជាតិសាសន៍និយម ការរើសអើងជាតិសាសន៍ ការស្អប់ជនបរទេស និងភាពមិនអត់ឱនដែលពាក់ព័ន្ធ នៅក្នុងឆ្នាំ២០០៥។ ដោយមានការគាំទ្រពីចលនាអន្តរជាតិប្រឆាំងរាល់ទម្រង់នៃការរើសអើង និងជាតិសាសន៍និយម (IMADR), ERD Net បាននិងកំពុងធ្វើការដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ការរើសអើងពូជសាសន៍ (ICERD) នៅប្រទេសជប៉ុន។ ERD Net បានដាក់បញ្ជូនរបាយការណ៍ស្រមោលមួយស្តីពីជប៉ុនដល់គណៈកម្មាធិការបំបាត់ការរើសអើងពូជសាសន៍ (CERD)។ នៅក្នុងខែកុម្ភៈឆ្នាំ២០១០ គណៈប្រតិភូ ERD Net បានចូលរួមក្នុងសម័យប្រជុំ និងបានរៀបចំកិច្ចប្រជុំមួយផ្តល់ព័ត៌មានដល់ CERD។ ចាប់ពីខែសីហា ឆ្នាំ២០១០ និងខែមិថុនា

ឆ្នាំ២០១២ អង្គការនេះបានរៀបចំកិច្ចពិគ្រោះយោបល់មួយចំនួនជាមួយរដ្ឋាភិបាល និងបានរៀបចំសិក្ខាសាលាសម្រាប់សមាជិកសភា ដោយផ្អែកលើការសេចក្តីសង្កេតចុងក្រោយរបស់ CERD។ "សកម្មភាពទាំងនេះ អនុញ្ញាតឲ្យយើងពង្រឹងជំនាញតស៊ូមតិរបស់យើងទាំងនៅថ្នាក់អ.ស.ប និងនៅថ្នាក់ជាតិ។ សកម្មភាពនេះបានពង្រឹងផងដែរនូវទំនាក់ទំនងសហប្រតិបត្តិការរបស់យើង"។ សមាជិកម្នាក់របស់ ERD Net បាននិយាយបន្តទៀតថា "បទពិសោធន៍នេះ បានអនុញ្ញាតផងដែរឲ្យយើងកំណត់យកប្រព័ន្ធផ្សព្វផ្សាយជាផ្នែកមួយទៀត ដែលយើងចង់ឲ្យរិតតែសកម្មថែមទៀត។ ការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយបន្ថែមទៀត អំពីរបៀបដែលយន្តការអន្តរជាតិពិនិត្យលើស្ថានភាពសិទ្ធិមនុស្សនៅប្រទេសជប៉ុន នឹងផ្តល់ជាប្រយោជន៍ពិតប្រាកដ។"

## ៤.៨. ការធ្វើការជាដៃគូ

ការធ្វើការជាមួយដៃគូ ក្នុងការតាមដាន និងការអនុវត្តសិទ្ធិមនុស្ស អាចមានតម្លៃជាយុទ្ធសាស្រ្ត។

បទពិសោធន៍ពីអតីតកាលបានបង្ហាញថា ការចូលរួមនៅក្នុងដំណើរការសិទ្ធិមនុស្ស អ.ស.ប អាចបើកឱកាសសម្រាប់ការបង្កើតភាពជាដៃគូថ្មី និងសហប្រតិបត្តិការក្នុងចំណោម CSAs។ ការចាប់យកឱកាសទាំងនេះ និងការទាញយកប្រយោជន៍ពីភាពជាដៃគូទាំងនេះ អាចផ្តល់លទ្ធផលច្រើន។ នៅពេលបង្កើតភាពជាដៃគូ ភាពចម្រុះនៃដៃគូ គឺសំខាន់ជាសារវន្ត ដើម្បីធានាថា គ្រប់ទស្សនវិស័យទាំងអស់ ត្រូវបានយកមកពិនិត្យពិចារណា។

ការធ្វើការជាមួយដៃគូ អាចកើតមាននៅកម្រិតជាច្រើន ៖ ដៃគូខ្លះអាចមានគោលដៅដូចគ្នា ខ្លះអាចមានធនធាន ជំនាញជាក់លាក់ ឬបណ្តាញទំនាក់ទំនងទូលំទូលាយ ខ្លះទៀតគឺជាអ្នកកាន់ករណីយកិច្ចសំខាន់ ឬអាចធ្វើការបញ្ចុះបញ្ចូលពួកគេបាន។

ការកំណត់តួអង្គសំខាន់ៗ និងវិភាគទានអ្វីខ្លះដែលពួកគេអាចផ្តល់ រួមទាំងហានិភ័យ និងការគំរាមកំហែង គឺជាមូលដ្ឋានសម្រាប់រៀបចំបង្កើតយុទ្ធសាស្រ្តមួយ ព្រមទាំងកំណត់អំពីតួនាទីឲ្យបានច្បាស់។ នៅក្នុងបញ្ជីទូលំទូលាយមួយ CSAs មានបទពិសោធន៍តាមទម្រង់ផ្សេងៗក្នុងការធ្វើការជាដៃគូ និងកិច្ចសហប្រតិបត្តិការជាមួយ៖

- CSAs នៅកម្រិតផ្សេងៗគ្នា និងក្នុងវិស័យតាមប្រធានបទផ្សេងៗគ្នា - ចាប់ពីអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍ រហូតដល់ CSAs នៅថ្នាក់ជាតិ និងអន្តរជាតិ
- ម្ចាស់ជំនួយ និងសហគមន៍ការទូត
- ប្រព័ន្ធផ្សព្វផ្សាយ
- សហជីព និងសមាគមវិជ្ជាជីវៈផ្សេងៗ
- បណ្តាញតាមប្រធានបទ

- រចនាសម្ព័ន្ធរដ្ឋ រាប់ទាំងសភា និងគណៈកម្មការពាក់ព័ន្ធនានា របស់សភា
- ស្ថាប័នសិទ្ធិមនុស្សជាតិ
- អង្គការអន្តរជាតិនិងតំបន់ រាប់ទាំងអង្គការ អ.ស.ប និងការិយាល័យ OHCHR នៅតាមបណ្តាប្រទេស ឬតំបន់
- គ្រឹះស្ថានអប់រំ និង
- យន្តការសិទ្ធិមនុស្ស។

## ការគៀងគរដៃគូ ដើម្បីការពារ និងលើកស្ទួយសិទ្ធិកុមារនៅប្រទេសនេប៉ាល់

នៅប្រទេសនេប៉ាល់ អង្គការសង្គ្រោះកុមារ (អង្គការ Save the Children) បានបណ្តុះបណ្តាល CSAs ចំនួន ១៣៨ នាក់ អំពី UPR។ អង្គការនេះបានគាំទ្រដល់ការបញ្ជូនរបាយការណ៍របស់ភាគីពាក់ព័ន្ធ និងបានសម្របសម្រួលការតស៊ូមតិនៅថ្នាក់ជាតិនិងអន្តរជាតិ។ ជាលទ្ធផលឯកសារលទ្ធផលរបស់ UPR មាន ៣៤ អនុសាសន៍ស្តីពីសិទ្ធិកុមារ រាប់ទាំងអនុសាសន៍ចំនួន ៣១ ត្រូវបានរដ្ឋាភិបាលនេប៉ាល់ទទួលយក។

អង្គការ Save the Children បានកសាងយុទ្ធសាស្ត្រតាមដាន UPR របស់ខ្លួន ជុំវិញការគៀងគរភាគីពាក់ព័ន្ធជាតិ រាប់ទាំងបណ្តាញសង្គមស៊ីវិល គណៈកម្មការសិទ្ធិមនុស្សជាតិ ស្ថានទូត និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីពង្រឹងភាពជាម្ចាស់ថ្នាក់ជាតិនៃដំណើរការ UPR និងពង្រឹងការចូលរួម និងគណនេយ្យភាព។

UPR មានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការប្រមូលគៀងគរ CSAs ទាំងឡាយនៅនេប៉ាល់ ជុំវិញរបៀបវារៈរួម ដើម្បីធ្វើសកម្មភាព។ ការដាក់បញ្ចូលគ្នានូវកិច្ចប្រជុំតស៊ូមតិទ្វេភាគីនិងរួមគ្នាថ្នាក់ខ្ពស់ជាមួយមន្ត្រីរដ្ឋាភិបាល និងស្ថានទូតនានា ហើយការលើកកម្ពស់ការយល់ដឹង តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ក៏ត្រូវបានប្រើផងដែរ រាប់ទាំងការធ្វើបទសម្ភាសន៍តាមទូរទស្សន៍ និងអត្ថបទសារព័ត៌មានស្តីពី UPR។ ការផ្សារភ្ជាប់ UPR ទៅនឹងព្រឹត្តិការជាក់លាក់មួយចំនួន ទាក់ទងនឹងកុមារ ដូចជា ទិវាសិទ្ធិកុមារ មានប្រសិទ្ធភាពជាពិសេស ក្នុងការទាញការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយ។

អង្គការ Save the Children ដោយសហការជាមួយសម្ព័ន្ធភាពសិទ្ធិកុមារជាតិ (NCRC) មានតួនាទីយ៉ាងសំខាន់ក្នុងការលើកទឹកចិត្តដល់គណៈកម្មការសិទ្ធិមនុស្សជាតិ (NHRC) ដើម្បីបញ្ចូលការតាមឃ្លាំមើល និងការតាមដានការអនុវត្តអនុសាសន៍ UPR នៅក្នុងអាណត្តិរបស់ខ្លួន។ NHRC មានតួនាទីសំខាន់មួយក្នុងការធានាឲ្យមានព័ត៌មាន ដែលអាចជឿទុកចិត្តបាន និងអាចយកជាការបានអំពីស្ថានភាពនៃការអនុវត្ត។

ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងតាមដានដែលមានការសម្របសម្រួលត្រឹមត្រូវ អនុសាសន៍ UPR លេខ 108.4 ដែលអំពាវនាវឲ្យមាន "ការអនុវត្តច្បាប់ស្តីពីច្បាប់គោលនយោបាយកុមារដែលបានរង់ចាំជាយូរមកហើយ រាប់ទាំងច្បាប់សិទ្ធិកុមារ បទបញ្ញាស្តីពីការអប់រំ គោលនយោបាយការពារកុមារ និងបទដ្ឋានអប្បបរមាសម្រាប់ផ្ទះថែទាំកុមារ" ត្រូវបានអនុវត្តជាអន្លើៗ។ ទាំងគោលនយោបាយកុមារជាតិ និងបទដ្ឋានទូលំទូលាយសម្រាប់ផ្ទះថែទាំកុមារ ត្រូវបានអនុម័តក្នុងឆ្នាំ២០១២។ គណៈរដ្ឋមន្ត្រីបានអនុម័តច្បាប់សិទ្ធិកុមារផងដែរ។

ការកំណត់ផែនទីការងារជាមួយដៃគូអាចបង្ហាញជារូបភាពបាន។ឧទាហរណ៍បទពិសោធន៍នៅប្រទេសនេប៉ាល់ដូចបានរៀបរាប់ខាងលើ អាចបង្ហាញឲ្យឃើញជាក្រាភិចខាងក្រោមនេះ។

## ការតៀងគរដៃគូធ្វើការលើសិទ្ធិកុមារនៅប្រទេសនេប៉ាល់



## ៤.៩. ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង

ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីការរកឃើញ និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស គឺជាមធ្យោបាយដ៏សំខាន់ក្នុងការលើកកម្ពស់ការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ។

ក្នុងករណីជាច្រើន ការអនុវត្តអាចធ្វើទៅបាន ពីព្រោះម្ចាស់សិទ្ធិកាន់តែច្រើនឡើងដឹង និងទាមទារសិទ្ធិដែលពួកគេត្រូវទទួលបាន ឬដោយសារតែអាជ្ញាធរពាក់ព័ន្ធដឹងពីវិធានការអ្វីខ្លះដែលគេរំពឹងថា ពួកគេត្រូវអនុវត្តដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្ស។ ការបិទភ្ជិត ឬការកាត់បន្ថយគម្លាតចំណេះដឹងអំពីសិទ្ធិមនុស្ស តាមរយៈការលើកកម្ពស់ការយល់ដឹង និងការផ្សព្វផ្សាយព័ត៌មានសិទ្ធិមនុស្ស គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាព ដើម្បីពង្រឹងការអនុវត្ត។

ចាប់ពីការបកប្រែទៅជាភាសាជាតិផ្សេងៗ រហូតដល់ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗ CSAs គឺពោរពេញទៅដោយធនធាន និងគំនិតច្នៃប្រឌិតក្នុងការផ្សព្វផ្សាយការរកឃើញ និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស។ ការធ្វើឲ្យអត្ថបទឯកសារ និងព័ត៌មានបានទៅដល់ជនដែលមានពិការភាព ជានិច្ចជាកាល គួរត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសម្រាប់ធ្វើការផ្សព្វផ្សាយ។

### ការប្រើប្រាស់ "ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន" ដើម្បីផ្សព្វផ្សាយអនុសាសន៍របស់អនុគណៈកម្មាធិការបង្ការទារុណកម្ម នៅប្រទេសប្រេស៊ីល

នៅក្នុងដំណើរទស្សនកិច្ចលើកដំបូងរបស់ខ្លួនក្នុងឆ្នាំ២០១១អនុគណៈកម្មាធិការស្តីពីបង្ការទារុណកម្ម (SPT) បានពិនិត្យស្ថានភាពទារុណកម្ម និងការប្រព្រឹត្តឃោឃៅអមនុស្សធម៌នៅតាមកន្លែងឃុំឃាំងផ្សេងៗរបស់ប្រទេសនេះ។ បន្ទាប់មកSPTបានរៀបចំរបាយការណ៍មួយដាក់ជូនរដ្ឋាភិបាលប្រេស៊ីល ដោយមានអនុសាសន៍ទាក់ទងនឹងការប្រព្រឹត្តអំពើទារុណកម្មក្នុងប្រទេសនេះ។ យោងតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (OPCAT) របាយការណ៍នេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ តែករណីណាដែលរដ្ឋាភិបាលសម្រេចឲ្យធ្វើដូច្នោះប៉ុណ្ណោះ។ ទោះបីជាមានការស្នើសុំពីសង្គមស៊ីវិលក្តី របាយការណ៍នេះនៅតែជាសម្ងាត់ដដែល ។

ក្នុងខែឧសភា ឆ្នាំ២០១២ ប្រេស៊ីលបានអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានសាធារណៈ។ នៅថ្ងៃដែលច្បាប់នេះ ចូលជាធរមាន អង្គការ Conectas Direitos Humanos (Conectas) បានដាក់សំណើមួយសុំឲ្យរដ្ឋាភិបាលប្រេស៊ីលផ្សព្វផ្សាយរបាយការណ៍របស់SPT ជាសា-

ធារណៈ និងអាចយកប្រើប្រាស់បាន។ ក្នុងកាលបរិច្ឆេទកំណត់ដោយច្បាប់នេះ រដ្ឋាភិបាលប្រេស៊ីល បានឆ្លើយតប ហើយក៏បោះពុម្ពផ្សាយរបាយការណ៍និងអនុសាសន៍នានា រាប់ទាំងមានការបកប្រែជាភាសាព័រទុយហ្គាល់ផងដែរ នៅលើវេបសាយរបស់ក្រសួងសិទ្ធិមនុស្ស។ អង្គការ Conectas បានចាត់ទុកថាវាជាការសំខាន់ណាស់ដែលរបាយការណ៍របស់SPT ត្រូវធ្វើការផ្សព្វផ្សាយសាធារណៈជាភាសាជាតិ។ ប្រសិនជាគ្មានរបាយការណ៍នេះទេ តួអង្គសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀតនឹងមិនអាចឃ្លាំមើលការអនុវត្តអនុសាសន៍របស់SPT បានឡើយ។ អង្គការ Conectas បានបញ្ជាក់ថា "នេះជាជំហានជាមូលដ្ឋានគ្រឹះមួយ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីស្ថានភាពធ្ងន់ធ្ងរទាក់ទងនឹងការប្រព្រឹត្តអំពើទារុណកម្មនៅក្នុងប្រទេសនេះ។ ដោយយល់ឃើញថា ការបន្តមានអំពើទារុណកម្មនៅក្នុងប្រទេសប្រេស៊ីលគឺជាផលវិបាក ដោយផ្ទាល់មួយនៃកង្វះគោលនយោបាយបង្ការទារុណប្រកបដោយប្រសិទ្ធភាព ហើយជាពិសេស កង្វះការទទួលខុសត្រូវសម្រាប់ជនប្រព្រឹត្តល្មើសច្បាប់ស្តីពីសិទ្ធិក្នុងការទទួលបានព័ត៌មាន គឺជាមធ្យោបាយមួយមានប្រសិទ្ធភាព ដើម្បីធានាថាការវាយតម្លៃរបស់ SPT ត្រូវបានផ្សព្វផ្សាយ ហើយឥឡូវនេះអាចត្រូវបានគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីប្រយុទ្ធប្រឆាំងទារុណកម្ម"

## ការផ្សាយតាមវេបសាយអំពីសម័យ ប្រជុំរបស់គណៈកម្មាធិការប្រឆាំងទារុណកម្មនៅប្រទេសអៀរឡង់ដ៍

ក្នុងឆ្នាំ២០១១ ក្រុមប្រឹក្សាអៀរឡង់ដ៍សម្រាប់សេរីភាពពលរដ្ឋ (ICCL) និងគណៈកម្មាធិការកំណែទម្រង់ព្រហ្មទណ្ឌអៀរឡង់ដ៍ (Irish Penal Reform Trust (IPRT)) បានរៀបចំរបាយការណ៍ស្រមោលរួមគ្នាមួយ សម្រាប់ការបង្ហាញមុខជាលើកដំបូងរបស់ប្រទេសអៀរឡង់ដ៍នៅចំពោះមុខគណៈកម្មាធិ ការប្រឆាំងទារុណកម្មអ.ស.ប (CAT)។ ជាមួយក្រុមប្រឹក្សាស្តារលទ្ធភាពពលកម្មអន្តរជាតិសម្រាប់ជនរងគ្រោះដោយទារុណកម្ម (IRCTV) ICCL និង IPRT បានរៀបចំការផ្សាយបន្តផ្ទាល់តាមវេបសាយលើកដំបូងអំពីសម័យប្រជុំCAT ដែលត្រូវបានបញ្ចាំងដោយCSAs និងស្ថាប័នច្បាប់មួយចំនួននៅក្នុងប្រទេសអៀរឡង់ដ៍។

តំណាងICCL បានមានប្រសាសន៍ថា "យើងបានផ្សព្វផ្សាយរបាយការណ៍ស្រមោល និងអនុសាសន៍ របស់CAT យ៉ាងទូលំទូលាយ និងបានទទួលព័ត៌មានដែលបានផ្សាយតាមកាសែត និងតាមវិទ្យុធំៗ ទាំងអស់។ កម្មវិធីកិច្ចការសាធារណៈក្នុងម៉ោងសំខាន់ (prime time public affairs) បានបង្ហាញរាយការណ៍តាមខ្សែវីដេអូរបស់អៀរឡង់ដ៍នៅលើវេបសាយរបស់យើង។នេះគឺជាលើកដំបូងហើយ ដែលសាធារណជនអៀរឡង់ដ៍បានឃើញស្ថាប័នសន្ធិសញ្ញា អ.ស.ប មួយនេះ កំពុងធ្វើការជាក់ស្តែង"។

ការបង្ហាញមុខរបស់ប្រទេសអៀរឡង់ដ៍នៅចំពោះមុខCAT និងអនុសាសន៍ដែលបានផ្តល់ បានរួមចំណែកដល់ការផ្លាស់ប្តូរជាបន្តបន្ទាប់នៅប្រទេសអៀរឡង់ដ៍។ កំណែទម្រង់ពន្ធនាគារមានលក្ខណៈនយោបាយកាន់តែខ្ពស់ ហើយក្រុមពិនិត្យយុទ្ធសាស្ត្រព្រហ្មទណ្ឌមួយត្រូវបានបង្កើតឡើង។[9] គណៈកម្មាធិការនេះបានស្នើឲ្យមានការតាមដានការអនុវត្តអនុសាសន៍ជាក់លាក់ចំនួន៤ ក្នុងរយៈពេល១២ខែ រាប់ទាំងបរាជ័យរបស់រដ្ឋក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនូវការឃុំឃាំងស្រ្តីនៅកន្លែងបោកសម្លៀកបំពាក់ឈ្មោះម៉ាដាលែន(Magdalene Laundries)។ ក្នុងខែកុម្ភៈ ឆ្នាំ ២០១៣ មានរបាយការណ៍ផ្លូវការមួយពាក់ព័ន្ធនឹងរដ្ឋនៅកន្លែងបោកសម្លៀកបំពាក់ឈ្មោះម៉ាដាលែន ត្រូវបានចេញផ្សាយ។[10] តាំងពីពេលនោះមក រដ្ឋបានចេញលិខិតសុំទោសជាផ្លូវការមួយដល់ស្រ្តីMagdalene ហើយបាននិងកំពុងរៀបចំគម្រោងដំណោះស្រាយសំណងដល់ស្រ្តីទាំងនោះ។

## ការផ្សាយតាមវេបសាយ និងវីដេអូ

សម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងរបស់យន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ ត្រូវបានផ្សាយបន្តផ្ទាល់តាមវេបសាយ និងត្រូវបានរក្សាទុកជាឯកសារដោយទូរទស្សន៍វេបសាយអ.ស.ប (UN web TV)[11]។ សង្គមស៊ីវិលអាចថតវីដេអូ និងផ្សាយតាមវេបសាយអំពីសម័យប្រជុំរបស់ស្ថាប័នសន្ធិសញ្ញាផ្សេងៗបាន។ ក្រុមអង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅទីក្រុងហ្សឺណែវមួយក្រុម ធ្វើការសម្របសម្រួលការផ្សាយតាមវេបសាយនៃសម័យប្រជុំទាំងអស់របស់ស្ថាប័នសន្ធិសញ្ញា។ www.treatybodywebcast.org. វីដេអូជាច្រើនដែលផលិតដោយការិយាល័យ OHCHR មាននៅលើវេបសាយរបស់ការិយាល័យ OHCHR និងប្រព័ន្ធផ្សព្វផ្សាយសង្គម។[12]

---

9 កោះប្រជុំដោយរដ្ឋមន្រ្តីក្រសួងយុត្តិធម៌ សមភាព និងការពារជាតិ ក្រុមពិនិត្យយុទ្ធសាស្រ្តព្រហ្មទណ្ឌ មានសមាសភាពអ្នកជំនាញចំនួន១២ រូប ដែលតំណាងឲ្យតុលាការ នគរបាល សេវាគ្រប់គ្រងការព្យួរទោសមន្រ្តីពន្ធនាគារ។ ក្រុមនេះផ្តល់អនុសាសន៍ស្តីពីការពង្រឹងប្រព័ន្ធព្រហ្មទណ្ឌមួយដែលមានគោលការណ៍ច្បាស់លាស់និងប្រកបដោយចីរភាព រាប់ទាំងអំពីកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសអៀរឡង់ដ៍។ សម្រាប់ព័ត៌មានបន្ថែមសូមមើល www.justice.ie

10 ចូលមើលរបាយការណ៍តាមវេបសាយ www.justice.ie

11 មាននៅលើវេបសាយ http://webtv.un.org/

12 ចូលមើលព័ត៌មានអំពីការិយាល័យ OHCHR តាមប្រព័ន្ធផ្សព្វផ្សាយសង្គម www.ohchr.org

## ៤.១០. ការតស៊ូមតិ

ការតស៊ូមតិសិទ្ធិមនុស្ស អាចត្រូវបានកំណត់និយមន័យថា ជាការប្រាស្រ័យទាក់ទងគ្នា សំដៅពង្រឹងការអនុវត្តសិទ្ធិមនុស្ស។ សារតស៊ូមតិប្រកបដោយប្រសិទ្ធភាពផ្តល់ព័ត៌មានអំពីស្ថានភាពសិទ្ធិមនុស្ស និងកង្វល់ក្នុងគោលបំណងបញ្ចុះបញ្ចូលអ្នកដទៃទៀតចាត់វិធានការ។ លក្ខណៈពិសេសនៃសារតស៊ូមតិសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាពគឺ៖

▶ផ្អែកលើអង្គហេតុ និងតួលេខដែលបានផ្ទៀងផ្ទាត់

▶បង្ហាញឧទាហរណ៍អំពីជីវិតពិត និងអំពីមនុស្ស

▶សាមញ្ញ និងជាក់លាក់

▶ប្រើប្រាស់ភាសាសមស្រប (ដោយប្រើភាសាសិទ្ធិមនុស្ស ជាជាងវោហារសាស្រ្តនយោបាយ ជៀសវាងភាសាបំពាន)

▶ត្រូវបានបញ្ជូនដោយអ្នកនាំសារដែលអាចជឿទុកចិត្តបាន

▶មានការអំពាវនាវឲ្យចាត់វិធានការច្បាស់លាស់

▶ត្រូវបានសម្របតម្រូវទៅតាមក្រុមគោលដៅ

▶រំពឹងថានឹងមានទទ្បីករណ៍ជំទាស់ ការរកឃើញ និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សបំពេញលក្ខណៈពិសេសជាច្រើនក្នុងចំណោមលក្ខណៈពិសេសទាំងនេះ។ CSAs កំណត់ និងផ្តល់អាទិភាពដល់ការរកឃើញ និងអនុសាសន៍ ដើម្បីធ្វើឲ្យការតស៊ូមតិរបស់ពួកគេកាន់តែមានប្រសិទ្ធភាពថែមទៀត។

## ការតស៊ូមតិ ការលើកកម្ពស់ការយល់ដឹង និងការតាមឃ្លាំមើល ការចូលរួមរបស់ជនពិការក្នុងការបោះឆ្នោតនៅប្រទេសទុយនីស៊ី

សេចក្តីសង្កេតចុងក្រោយរបស់CRPD ឆ្នាំ២០១១ ស្តីពីប្រទេសទុយនីស៊ី(Tunisia) មានបញ្ចូលអនុសាសន៍ជាច្រើនស្តីពីកំណែទម្រង់ប្រជាធិបតេយ្យរបស់ប្រទេសនេះ និងមានគោលបំណងធានាថា ជនពិការត្រូវបានដាក់បញ្ចូលក្នុងដំណើរការតាក់តែងរដ្ឋធម្មនុញ្ញថ្មី ហើយថាពួកគេអាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីបោះឆ្នោត និងចូលរួមក្នុងជីវភាពសាធារណៈដោយស្មើភាពដូចអ្នកដទៃទៀតដែរ។

អង្គការទុយនេស៊ីសម្រាប់ការលើកកម្ពស់សិទ្ធិជនពិការ (Organisation tunisienne de d"fense des droits des personnes handicap"es- OTDDPH) គឺជាអង្គការជនពិការមួយដែលត្រូវបានបង្កើតឡើងបន្ទាប់ពីមានបដិវត្តន៍ បានធ្វើសិក្ខាសាលាជាច្រើន ដើម្បីលើកកម្ពស់ការយល់ដឹងនៅតាមតំបន់ផ្សេងៗ សំដៅលើកទឹកចិត្តជនពិកាឲ្យចូលរួមក្នុងការបោះឆ្នោតនៅថ្ងៃខាងមុខ។ សមាជិកជាច្រើននៃអង្គការនេះ បានធ្វើជាអ្នកសង្កេតការណ៍បោះឆ្នោតផ្លូវការ ដែលបានអនុញ្ញាតឲ្យ OTDDPH សង្កេតការណ៍ដោយផ្ទាល់នៅតាមស្ថានីយបោះឆ្នោតជាង១០០ នៅក្នុងប្រទេសនេះ ក្នុងគោលបំណងវាយតម្លៃអំពីការគោរពបទដ្ឋានស្តីពីលទ្ធភាពអាចទទួលបាន ក៏ដូចជាធ្វើការវាស់វែងអំពីការចូលរួមបោះឆ្នោតពីសំណាក់ជនពិការនៅក្នុងការបោះឆ្នោត។

បន្ទាប់ពីការបោះឆ្នោតសភាធម្មនុញ្ញ ដែលមានភារកិច្ចតាក់តែងរដ្ឋធម្មនុញ្ញថ្មីរបស់ទុយនីស៊ី OTDDPH បាននិងកំពុងអនុវត្តសកម្មភាពផ្សេងៗ ដើម្បីតស៊ូមតិជាមួយសភា ធម្មនុញ្ញដើម្បីធានាឲ្យមានការដាក់បញ្ចូលសិទ្ធិជនពិការទៅក្នុងរដ្ឋធម្មនុញ្ញ។ ដោយផ្អែកលើការតស៊ូមតិអំពីCRPD និងអនុសាសន៍របស់គណៈកម្មាធិការ CRPD OTDDPH បានថ្លែងការណ៍ក្នុងសម័យប្រជុំរបស់គណៈកម្មាធិការសភា បានចូលរួមជាមួយសមាជិកគណៈកម្មាធិការនីមួយៗ និងបានតាក់តែងបទប្បញ្ញត្តិដែលអាចដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ។

## ការតស៊ូមតិដើម្បីឲ្យតុលាការឯករាជ្យនៅហ្គាតេមេឡា (Guatemala)

អ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពរបស់ចៅក្រម និងមេធាវីបានធ្វើទស្សនកិច្ចនៅហ្គាតេមេឡា (Guatemala) នៅក្នុងអំឡុងពេលបោះឆ្នោតជ្រើសតាំងចៅក្រមសម្រាប់តុលាការកំពូល។ នៅក្នុងអំឡុងពេលដំណើរការបោះឆ្នោតជ្រើសតាំងព្រះរាជអាជ្ញា បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងចៅក្រម និងជាផ្នែកមួយនៃការងារតស៊ូមតិរបស់ពួកគេ សង្គមស៊ីវិលបាននិយាយយោងយ៉ាងច្រើនដល់របាយការណ៍របស់អ្នករាយការណ៍ពិសេស ជាពិសេស ទាក់ទងនឹងលក្ខខណ្ឌតម្រូវ

ដើម្បីឲ្យមានឯករាជ្យភាព តម្លាភាព និងឧត្តមភាពវិជ្ជាជីវៈ។ ការិយាល័យ OHCHR ប្រចាំប្រទេស Guatemala បានរួមចំណែកផ្តល់កម្រងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធរួមទាំងអនុសាសន៍របស់អ្នករាយការណ៍ពិសេសផងដែរ។ CSAs បានប្រើកម្រងឯកសារនេះដើម្បីពង្រឹងការតស៊ូមតិរបស់ពួកគេជាមួយគណៈកម្មការស្នើ ឈ្មោះ ដើម្បីឲ្យពួកគេផ្តល់អនុសាសន៍អំពីបេក្ខជនដែលមានសមត្ថភាពបំផុតសម្រាប់មុខតំណែងព្រះរាជអាជ្ញា។ CSAs បានប្រើអនុសាសន៍ទាំងនេះផងដែរ នៅក្នុងសេចក្តីថ្លែងការណ៍សាធារណៈដែលស្វែងរកការកែប្រែបញ្ញត្តិមួយចំនួនក្នុងច្បាប់ និងជំរុញឲ្យមានគណ-នេយ្យភាពកាន់តែច្រើនឡើងថែមទៀតពីអាជ្ញាធរចំពោះឯករាជ្យភាពតុលាការ ។

## ៤.១១. ការកសាង និងការពង្រឹងសមត្ថភាព

ការរកឃើញនិងអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស អាចចង្អុលពីកង្វះខាតសមត្ថភាពជាច្រើនក្នុងជួរអាជ្ញាធររដ្ឋ ឬតួអង្គសង្គមស៊ីវិល ដែលកម្រិតសមត្ថភាពរបស់ពួកគេក្នុងការអនុវត្តសិទ្ធិមនុស្ស។ ជួនកាល អនុសាសន៍មិនត្រឹមតែកំណត់ពីកង្វះខាតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកទឹកចិត្តដល់សកម្មភាពកសាងសមត្ថភាព ដើម្បីដោះស្រាយកង្វះខាតទាំងនោះផងដែរ។ ក្នុងករណីខ្លះ CSAs អាចមានលទ្ធភាពបិទផ្ទិត ឬកាត់បន្ថយគម្លាតបែបនេះ ហើយអង្គការជាច្រើនមានបទពិសោធន៍ និងជំនាញបច្ចេកទេសក្នុងការបណ្តុះបណ្តាលសិទ្ធិមនុស្សសម្រាប់ទាំងCSAs និងអាជ្ញាធររដ្ឋ។

អនុសាសន៍អាចឆ្លុះបញ្ចាំងពីកង្វះខាតដែលកំពុងតែត្រូវបានយកចិត្តទុកដាក់រួច ហើយតាមរយៈសកម្មភាពកសាងសមត្ថភាពដែលអនុវត្តដោយ CSAs។ នៅក្នុងករណីទាំងនេះអនុសាសន៍ពង្រឹងសារៈសំខាន់នៃសកម្មភាពរបស់សង្គមស៊ីវិល និងតួនាទីរបស់ពួកគេនៅក្នុងការកសាងសមត្ថភាព។ ក្នុងករណីផ្សេងទៀត អនុសាសន៍អាចចង្អុលពីកង្វះខាតដែលមិនត្រូវបានដោះស្រាយដោយកម្មវិធីដែលមានស្រាប់។ សង្គមស៊ីវិលដែលបានចូលរួមក្នុងសកម្មភាពតាមដាន និងវាយតម្លៃ ពីលទ្ធភាពជោគជ័យនៃសកម្មភាពកសាងសមត្ថភាពបន្ថែមទៀតដោយៈ

- វាយតម្លៃថា តើ CSAs មានលទ្ធភាពអនុវត្តសកម្មភាពកសាងសមត្ថភាពឬទេ ទាក់ទងនឹងជំនាញបច្ចេកទេសដែលត្រូវការ ធនធានដែលមាន និងផលប៉ះពាល់ដែលរំពឹងទុក។ ការវិភាគអំពីថាតើសកម្មភាពកសាងសមត្ថភាពថ្មីនឹងកើតឡើងព្រមពេលជាមួយគ្នានឹងអាទិភាព និងផែនការការងាររបស់ CSAs ដែលបង្កើតបានជាផ្នែកមួយនៃការវាយតម្លៃនេះ
- វាយតម្លៃពីតម្រូវការរបស់ស្ថាប័ន និងអង្គការដែលជាគោលដៅ រួមទាំងឆន្ទៈរបស់ពួកគេក្នុងការដោះស្រាយបញ្ហាកង្វះសមត្ថភាព សំដៅពង្រឹងការអនុវត្តសិទ្ធិមនុស្ស និង

- វិភាគការបំពេញបន្ថែមជាមួយកម្មវិធីកសាងសមត្ថភាពដទៃទៀត តម្លៃបន្ថែមនៃសកម្មភាពថ្មី និងឥទ្ធិពល និងនិរន្តរភាពនៃកម្មវិធីទាំងនោះ។

បទពិសោធន៍បានបង្ហាញថា អាជ្ញាធររដ្ឋ ក៏ដូចជា CSAs ជារឿយៗ បើកចំហដល់កម្មវិធីកសាងសមត្ថភាព ប៉ុន្តែនេះមិនមែនសុទ្ធតែបានលទ្ធផលតាមការរំពឹងទុកដោយស្វ័យប្រវត្តិនោះទេ។ បរាជ័យគឺអាចដោយសារតែឆន្ទៈក្នុងការផ្លាស់ប្តូរនៅមានកម្រិត ការផ្លាស់ប្តូរដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងចំណោមអ្នកទទួលផល ព្រំដែនកំហិតនៃសកម្មភាពកសាងសមត្ថភាព (ឧទាហរណ៍ ភាពគ្មាននិរន្តរភាព គោលដៅមិនច្បាស់លាស់ អ្នកទទួលផលមានកម្រិត ចំណេះដឹងខុសគ្នាខ្លាំង) ឬមានការគួបផ្សំគ្នានៃកត្តាទាំងអស់នេះ។ ហានិភ័យទាំងនេះនឹងត្រូវបានធ្វើការ វាយតម្លៃយ៉ាងប្រុងប្រយ័ត្ន ក្នុងការរៀបចំតាក់តែងកម្មវិធីកសាងសមត្ថភាព និងវាស់វែងពីផលប៉ះពាល់ នៅពេលវាយតម្លៃលទ្ធផល។[13]

## ការបញ្ជ្រាប និងការសាងសមត្ថភាពដល់កម្លាំងសន្តិសុខ ដើម្បីប្រយុទ្ធនឹងអំពើហិង្សាផ្លូវភេទនៅកូឌីវ័រ (C'te d"Ivoire)

ដោយអនុវត្តតាម UPR របស់ C"te dIvoire ក្នុង ឆ្នាំ២០០៩ អង្គការមិនមែនរដ្ឋាភិបាល SOS Exclusion បានប្រើអនុសាសន៍ទាំងនេះដើម្បីបង្កើតផែនការសកម្មភាពមួយ ដោយផ្តោតសំខាន់លើការកសាងសមត្ថភាពខាងសិទ្ធិមនុស្សសម្រាប់នគរបាល និងកងទ័ព។ ប្រធានអង្គការនេះបានពន្យល់ថា "យើងបានរៀបចំសិក្ខាសាលាពីរលើកស្តីពីអនុសាសន៍ UPR ទាក់ទងនឹងសិទ្ធិស្ត្រី" ។ "នេះជាឱកាសមួយ ដើម្បីវាយតម្លៃស្ថានភាពនៃការអនុវត្តអនុសាសន៍ទាំងនោះជាមួយតួអង្គសំខាន់ៗមួយចំនួន ដូចជាក្រសួងសាមគ្គីភាព គ្រួសារ ស្ត្រី និងកុមារ ក្រសួងយុត្តិធម៌ និងអង្គការសហប្រជាជាតិដើម្បីស្ត្រី(UN Women)"។ បន្ទាប់មក មានយុទ្ធនាការគៀងគរសង្គមប្រឆាំងនឹងអំពើហិង្សាផ្លូវភេទ ដែលជាអនុសាសន៍មួយរបស់ UPR។ "យុទ្ធនាការនេះបានផ្តល់ឲ្យយើងនូវឱកាស ដើម្បីប្រមូលផ្តុំតួអង្គសង្គមស៊ីវិល មេដឹកនាំសាសនា ក្រសួង សាមគ្គីភាព និងក្រសួងយុត្តិធម៌ក៏ដូចជាសហគមន៍ដែលជាកន្លែងកំពុងរៀបចំយុទ្ធនាការនេះ"។

[13] សម្រាប់ការណែនាំស្តីពីការវាយតម្លៃការបណ្តុះបណ្តាលសិទ្ធិមនុស្ស សូមមើលការវាយតម្លៃសកម្មភាពបណ្តុះបណ្តាលសិទ្ធិមនុស្ស (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ HR/P/PT/18).

## ៤.១២. ការបញ្ចូលទស្សនទាន យេនឌ័រទៅក្នុងសកម្មភាពតាមដាន

សំណួរទាំងឡាយខាងក្រោមនេះ អាចជួយដាក់បញ្ចូលយេនឌ័រ នៅពេលកំណត់អាទិភាពដល់សកម្មភាពតាមដានបន្ត៖

▶ តើអនុសាសន៍ជាអាទិភាព និងសកម្មភាពតាមដាន ដែលពាក់ព័ន្ធ ប៉ះពាល់ដល់ស្ត្រីភាគច្រើន និង/ឬបុរសដែរឬទេ?

▶ តើទស្សនទានយេនឌ័រត្រូវបានដាក់បញ្ចូលក្នុងអន្តរាគមន៍ជាអាទិភាពដូចម្តេច? តាមរយៈសកម្មភាពជាក់លាក់ខាងយេនឌ័រ និង/ឬតាមរយៈការបញ្ជ្រាបយេនឌ័រ?

▶ តើម្ចាស់សិទ្ធិខ្លះ ទទួលរងការរើសអើងជាច្រើនប្រភេទ ដែរឬទេ? តើសកម្មភាពតាមដាននឹងជួយដោះស្រាយស្ថានភាពរបស់ពួកគេបានដែរឬទេ?

▶ តើសកម្មភាពដែលបានគ្រោងសំដៅផ្តល់អំណាចឲ្យម្ចាស់សិទ្ធិនិងប្រយុទ្ធប្រឆាំងការរើសអើង និងវិសមភាពយេនឌ័រ ដែរឬទេ?

▶ តើមានការពិគ្រោះយោបល់ជាមួយម្ចាស់សិទ្ធិផ្សេងៗ ដើម្បី កំណត់អាទិភាពអន្តរាគមន៍ឬទេ? នៅពេលអនុវត្តសកម្មភាពតាមដាន ៖

▶ ប្រមូល និងរាយការណ៍ទិន្នន័យដែលបំបែកតាមភេទ និងធាតុផ្សំផ្សេងៗទៀតនៃភាពចម្រុះ ដូចជា អាយុ ជាតិពិន្ទុ ពិការភាព ស្ថានភាព សេដ្ឋកិច្ចសង្គម ។ល។

▶ នៅពេលគ្មានព័ត៌មានដែលជាក់លាក់ចំពោះយេនឌ័រ ត្រូវបញ្ជាក់ពីកង្វះខាតនៅក្នុងការរាយការណ៍។

▶ នៅពេលរៀបចំព្រឹត្តិការណ៍ ការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាព៖ ត្រូវធានាតុល្យភាពយេនឌ័រនៅក្នុងការចូលរួមនិងគ្រូបង្គោលឬធនធានមនុស្សបរិយាកាសវេទយិតភាពយេនឌ័រ និង (ទីកន្លែង ក្របខណ្ឌពេលវេលា) ខ្លឹមសារ និងវិធីសាស្ត្រវេទយិតភាពយេនឌ័រ;

▶ ធ្វើការវិភាគយេនឌ័រលក្ខណៈជាប្រព័ន្ធ;

▶ ធ្វើការជាមួយដៃគូវេទយិតភាពយេនឌ័រ;

▶ ក្នុងការតស៊ូមតិ និងសកម្មភាពលើកកម្ពស់ការយល់ដឹង៖ រាប់បញ្ចូលសារស្តីពីសមភាពយេនឌ័រ និងប្រើប្រាស់ភាសា និងរូបភាពវេទយិតភាពយេនឌ័រ។

## ៤.១៣. ការឆ្លុះបញ្ចាំងពីការរួមបញ្ចូល ភាពចម្រុះ និងលទ្ធភាពអាចទទួលបាន

នៅពេលធ្វើផែនការ និងអនុវត្តសកម្មភាពតាមដានៈ

- ត្រូវដាក់បញ្ចូលភាគីពាក់ព័ន្ធចម្រុះ
- ធានាថា ភាពចម្រុះនៃទស្សនវិស័យត្រូវបានគេស្តាប់ និងបានឆ្លុះបញ្ចាំងនៅក្នុងសកម្មភាពតាមដាន
- ពិចារណាលទ្ធភាពអាចទទួលបាន សម្រាប់ការចូលរួមរបស់មនុស្សដែលមានសាវតាផ្សេងៗគ្នា រាប់ទាំងក្រុមជនភាគតិច និងជនពិការ និងចាត់វិធានការរៀបចំឯកសារ និងធនធានផ្សេងៗសម្រាប់ ជនពិការ។

## ៤.១៤. ការប្រើប្រាស់អនុសាសន៍នៅក្នុងចំណាត់ការរបស់តុលាការ និងបណ្តឹងវិវាទ

CSAs ជាច្រើនគាំទ្របុគ្គលនិងក្រុមទាំងឡាយ ដែលទាមទារសិទ្ធិរបស់ពួកគេ តាមរយៈយន្តការតុលាការ ឬយន្តការដែលមានមុខងារជាតុលាការនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ នេះអាចរួមបញ្ចូលជំនួយផ្នែកច្បាប់សម្រាប់ដើមបណ្តឹង ទស្សនៈរបស់អ្នកច្បាប់ ការកសាងសមត្ថភាពចៅក្រមព្រះរាជអាជ្ញា មេធាវី និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ ដើម្បីអនុវត្តច្បាប់សិទ្ធិមនុស្ស ឬជម្រុញ លើកទឹកចិត្តឲ្យប្រើប្រាស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយសកម្មជន និងតុលាការ។

ការប្រើប្រាស់ និងការជម្រុញលើកទឹកចិត្តឲ្យប្រើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងដំណើរការក្តីនៅតុលាការនៅថ្នាក់ជាតិនិងតំបន់អាចពង្រឹងយុត្តិសាស្ត្រសិទ្ធិមនុស្ស។ ការបកស្រាយបទប្បញ្ញត្តិសន្ធិសញ្ញាដែលមាននៅក្នុងសេចក្តីអធិប្បាយទូទៅរបស់ស្ថាប័នសន្ធិសញ្ញា ជាឧទាហរណ៍អាចផ្តល់ជាពន្លឺអំពីអ្វីដែលជាសិទ្ធិជាក់លាក់មួយ ហើយអាចត្រូវបានតុលាការជាតិធ្វើការពិចារណាក្នុងការសម្រេចលើករណីផ្សេងៗ។ ស្រដៀងគ្នានេះដែរ ការនិយាយយោងទៅអនុសាសន៍ជាក់លាក់របស់យន្តការសិទ្ធិមនុស្សអាចជួយពង្រឹងការទាមទាររបស់ម្ចាស់សិទ្ធិ។

## ការទាមទារសិទ្ធិទទួលបានឱសថគ្មានយីហោ ប្រទេសកេនយ៉ា

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ សាលក្រមដ៏លេចធ្លោមួយរបស់តុលាការជាន់ខ្ពស់កេនយ៉ា បានសម្រេចថា ផ្នែកមួយចំនួននៃច្បាប់ប្រឆាំងផលិតផលក្លែងក្លាយ ឆ្នាំ ២០០៨ មិនអនុវត្តចំពោះឱសថគ្មានយីហោនោះទេ ដូច្នេះ វាផ្តល់ការការពារដល់ការទទួលបានការព្យាបាលដែលមានតម្លៃសមស្រប។ សំណុំរឿងនេះ បានធ្វើឡើងដោយមនុស្សបីនាក់ដែលមានផ្ទុកមេរោគអេដស៍។ KELIN ជាអង្គការសិទ្ធិមនុស្សមួយ ដែលធ្វើការដើម្បីការពារនិងលើកកម្ពស់សិទ្ធិមនុស្សពាក់ព័ន្ធនឹងមេរោគអេដស៍នៅអាហ្វ្រិកខាងកើត បានផ្តល់ការគាំទ្រផ្នែកស្រាវជ្រាវដល់ក្រុមប្រឹក្សាអ្នកបញ្ជូនញត្តិ (lead counsel of the petitioners)។ បន្តតាំងពីឆ្នាំ២០០៩ មក សំណុំរឿងនេះបានលើកយកទឡ្ហីករតទល់នឹងទិដ្ឋភាពផ្លូវច្បាប់ប្រឆាំងផលិតផលក្លែងក្លាយឆ្នាំ២០០៨ ដែលគំរាមកំហែងដល់ការនាំចូលឱសថគ្មានយីហោ រួមទាំងឱសថពន្យាជីវិត (ARVs) សម្រាប់អ្នកផ្ទុកមេរោគអេដស៍។ អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសុខភាព បានធ្វើសារណាការពារ (an amicus brief) ដែលត្រូវបានគេដកស្រង់នៅក្នុងសាលក្រមផងដែរ។

នៅក្នុងសាលក្រមរបស់លោកស្រី លោកស្រីចៅក្រម ងូជី (Ngugi) បានសម្រេចថាកម្មសិទ្ធិបញ្ញាមិនគួរមានអានុភាពលុបចោលសិទ្ធិរស់រានមានជីវិត សិទ្ធិសុខភាព និងសិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរជាមនុស្ស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់កេនយ៉ាឡើយ។ ដូច្នេះ ម្ចាស់ប្រកាសនីយបត្រតក្កកម្ម នឹងមិនអាចប្រើច្បាប់នេះ ដើម្បីរារាំងដល់ការនាំចូលឱសថគ្មានយីហោ ដូចដែលអ្នកបញ្ជូនញត្តិមានការភ័យខ្លាចឡើយ។[14]

## ៤.១៥. ការចែករំលែកលទ្ធផលនៃសកម្មភាពតាមដាន និងការអនុវត្តល្អៗ

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងយន្តការពាក់ព័ន្ធអាចត្រូវបានគេយល់ឃើញថាស្ថិតនៅឆ្ងាយពីស្ថានភាពពិតរបស់ម្ចាស់សិទ្ធិ។ តើអនុសាសន៍របស់អ្នកជំនាញឯករាជ្យនៅទីក្រុងហ្សឺណែវ មានឥទ្ធិពលទៅលើជីវិតរស់នៅរបស់ពលរដ្ឋធម្មតា ឬទេ? តើអនុសាសន៍ទាំងនេះអាចមានឥទ្ធិពលវិជ្ជមានទៅលើឥរិយាបថរបស់អ្នកកាន់កាតព្វកិច្ចដែលអាចមិនស្គាល់ស្ថាប័ន សន្ធិសញ្ញា ឬមិនដឹងអំពីការងាររបស់អ្នករាយការណ៍ពិសេស ឬទេ? ប៉ុន្តែការផ្លាស់ប្តូរអាចកើតមាន និងពិតជាអាចកើតមានក្នុងករណីជាច្រើន ដោយសារតែការងារតាមដានរបស់សង្គមស៊ីវិល។

[14] សូមមើលសាលក្រម៖ http://bit.ly/L1cEu5 (ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣)

ការចងក្រងឯកសារ ការចែករំលែក និងការផ្សព្វផ្សាយលទ្ធផលនៃសកម្មភាពតាមដាន និងការអនុវត្តល្អ ជំរុញលើកទឹកចិត្តអ្នកដទៃទៀតឲ្យចូលរួម ចម្លង និងអនុវត្តតាមបទពិសោធន៍ស្របតាមបរិបទ និងអាទិភាពផ្ទាល់របស់ពួកគេ។ ព័ត៌មានត្រឡប់ស្តីពីឥទ្ធិពលរបស់យន្តការសិទ្ធិមនុស្សក៏ត្រូវបានផ្តល់តម្លៃខ្ពស់ផងដែរ ដោយអ្នកជំនាញដែលបម្រើការឲ្យយន្តការទាំងនេះ។

**ការចែករំលែកធនធាន និងការអនុវត្តទាក់ទងនឹងការដាក់បណ្តឹងករណីសិទ្ធិមនុស្សក្នុងកិច្ចគាំពារសុខភាពអ្នកជំងឺនៅអឺរ៉ុបខាងកើត និងអាស៊ីកណ្តាល**

សិទ្ធិមនុស្សក្នុងគម្រោងកិច្ចគាំពារសុខភាពអ្នកជំងឺ បង្កើតមគ្គុទ្ទេសក៍ អ្នកប្រកបវិជ្ជាជីវៈប្រចាំប្រទេសសម្រាប់មេធាវី ដែលចាប់អារម្មណ៍ក្នុងការដាក់បណ្តឹងករណីសិទ្ធិមនុស្ស ក្នុងនាមអ្នកជំងឺ។ មគ្គុទ្ទេសក៍នេះមានលក្ខណៈជាក់ស្តែង ដោយគ្របដណ្តប់ទាំងលើបណ្តឹងវិវាទក្នុងប្រព័ន្ធតុលាការ និងទាំងលើយន្តការក្រៅប្រព័ន្ធតុលាការ ដូចជា មន្ត្រីការិយាល័យប្រជាពលរដ្ឋ និងស្ថាប័នចេញអាជ្ញាប័ណ្ណវេជ្ជសាស្ត្រ និងការពិនិត្យមើលសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកជំងឺ និងអ្នកផ្តល់សេវា នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ រួមទាំងការត្រួតពិនិត្យពីយុត្តិសាស្ត្ររបស់ស្ថាប័នសន្ធិសញ្ញា និងការងាររបស់នីតិវិធីពិសេស។

គម្រោងនេះក៏មានសហគមន៍ប្រកបវិជ្ជាជីវៈមួយ (community of practice) ផងដែរ ដែលជាទីកន្លែងគេហទំព័រ ដើម្បីចែករំលែកអត្ថបទឯកសារ និងធនធានផ្សេងៗ។ សហគមន៍ប្រកបវិជ្ជាជីវៈនេះ មានបីផ្នែកធំៗ គឺៈ ការបង្រៀនច្បាប់និងសុខភាព ការបណ្តុះបណ្តាលសិទ្ធិមនុស្សក្នុងការថែទាំអ្នកជំងឺ និងឧបករណ៍ប្រព័ន្ធផ្សព្វផ្សាយ។[15]

## ៤.១៦. ការចូលរួមជាមួយនីតិវិធីតាមដាន និងការអនុវត្ត ដែលមានស្រាប់របស់យន្តការសិទ្ធិមនុស្ស

នីតិវិធីតាមដាន និងការអនុវត្ត ដែលដឹកនាំដោយយន្តការសិទ្ធិមនុស្ស ពឹងផ្អែកលើកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានា ក៏ដូចជា ការចូលរួមរបស់ CSO។ ផ្នែកនៃមគ្គុទ្ទេសក៍ខាងក្រោមនេះ រៀបរាប់អំពីនីតិវិធី និងការអនុវត្តការតាមដានដែលមានស្រាប់។

[15] មាននៅលើវេបសាយ http://health-rights.org/

# ៥. នីតិវិធីតាមដាន និងការអនុវត្តរបស់យន្តការសិទ្ធិមនុស្ស

ការប៉ាន់ប្រមាណការផ្លាស់ប្តូរដែលធ្វើតាមអនុសាសន៍សិទ្ធិមនុស្ស ការសិក្សាអំពីអ្វីដែលបានកើតឡើងបន្ទាប់ពីយន្តការសិទ្ធិមនុស្សបានពិនិត្យប្រទេសណាមួយ ក្រោមនីតិវិធីរបស់ខ្លួន ការស្វែងយល់អំពីផលប៉ះពាល់លើមូលដ្ឋាន នៃស្ថាបត្យកម្មសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គឺជាចំណាប់អារម្មណ៍ និងគោលដៅស្នូលមួយរបស់យន្តការសិទ្ធិមនុស្ស។ ចាប់តាំងពីការចាប់បដិសន្ធិមក យន្តការទាំងអស់បានដឹងថា អត្ថន័យរបស់ពួកគេគឺស្ថិតនៅលើការផ្លាស់ប្តូរជាវិជ្ជមានដែលពួកគេអាចបង្កើតឡើង ឬជំរុញឲ្យមាន។ ភស្តុតាងនៃការផ្លាស់ប្តូរជាវិជ្ជមាន គឺជាភស្តុតាងនៃប្រសិទ្ធភាពរបស់ពួកគេ។ "ការស្វែងរកភស្តុតាង" នេះ បាននាំមកនូវការបង្កើតឲ្យមានទម្រង់ផ្សេងៗនៃការតាមដាន ដែលយន្តការនីមួយៗបានបង្កើតឡើង។ ការតាមដានខ្លះ ត្រូវបានរៀបចំជាផ្លូវការតាមនីតិវិធីដែលមាន ដូចជានីតិវិធីតាមដានសេចក្តីសង្កេតចុងក្រោយរបស់ស្ថាប័នសន្ធិសញ្ញាផ្សេងៗ។ ការតាមដានខ្លះទៀត គឺជាការអនុវត្តដែលមានជាទៀងទាត់ ដូចជារបាយការណ៍តាមដានស្តីពីទស្សនកិច្ចទៅកាន់ប្រទេស ដែលបង្កើតឡើងដោយអ្នករាយការណ៍ពិសេសមួយចំនួន។ នៅក្នុងករណីខ្លះទៀត ការតាមដានអាចជាគំនិតផ្តួចផ្តើមចំពោះកិច្ចមួយ ឧទាហរណ៍សិក្ខាសាលាថ្នាក់តំបន់ដើម្បីចែករំលែកបទពិសោធន៍នៅក្នុងការអនុវត្តអនុសាសន៍សិទ្ធិមនុស្ស ។ ផ្នែកទាំងខាងក្រោមនេះ រៀបរាប់អំពីវិធីទាំងនេះកាន់តែលម្អិតថែមទៀត។

## ៥.១. ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

### *នីតិវិធីតាមដានសេចក្តីសង្កេតចុងក្រោយ*

ស្ថាប័នសន្ធិសញ្ញា បានរៀបចំឲ្យមាននីតិវិធីដើម្បីជួយរដ្ឋភាគីអនុវត្តអនុសាសន៍ ដែលមាននៅក្នុងសេចក្តីសង្កេតចុងក្រោយ ឬសេចក្តីសម្រេចលើករណីបណ្តឹងផ្សេងៗដែលបញ្ជូនមកក្រោមនីតិវិធីបណ្តឹងលក្ខណៈជាបុគ្គល។ ស្ថាប័នសន្ធិសញ្ញាទាំងអស់តម្រូវឲ្យរដ្ឋទាំងឡាយលើកអំពីការតាមដាននៅក្នុងរបាយការណ៍តាមកាលកំណត់របស់ខ្លួនស្តីពីការអនុវត្ត។ គណៈកម្មាធិការប្រឆាំងទារុណកម្ម (CAT) គណៈកម្មាធិការបំបាត់ការរើសអើងពូជ សាសន៍ (CERD) គណៈកម្មាធិការសិទ្ធិមនុស្ស (គណៈកម្មាធិការស.ម) គណៈកម្មាធិការលុបការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) និងគណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ (CED) បានអនុម័តនីតិវិធីតាមដានផ្លូវការ។ នៅក្នុងសេចក្តីសង្កេតចុងក្រោយរបស់ពួកគេ ស្ថាប័នសន្ធិសញ្ញាទាំងប្រាំនេះស្នើសុំឲ្យរដ្ឋទាំងឡាយរាយការណ៍ត្រឡប់មកវិញក្នុងអំឡុងពេលមួយឆ្នាំ (ពីរឆ្នាំក្នុងករណី CEDAW) អំពីវិធានការដែលបានចាត់ឆ្លើយតបទៅនឹងអនុសាសន៍ជាក់លាក់ ឬ "កង្វល់ជាអាទិភាព" ដែលអាច

អនុវត្តបានឆាប់រហ័ស។ គណៈកម្មាធិការទាំងនេះ តែងតាំងអ្នករាយការណ៍ ឬអ្នកសម្របសម្រួលមួយរូបដើម្បីធ្វើការតាមដាន ដែលទទួលខុសត្រូវវាយតម្លៃរបាយការណ៍តាមដានដែលរដ្ឋភាគីបានដាក់បញ្ជូនមក និងដាក់របាយការណ៍ទាំងនេះជូនគណៈកម្មាធិការ។ សមាជិកមួយចំនួននៃស្ថាប័នសន្ធិសញ្ញា បានបំពេញទស្សនកិច្ចទៅកាន់រដ្ឋភាគីតាមការអញ្ជើញរបស់រដ្ឋ ដើម្បីតាមដានរបាយការណ៍ និងការអនុវត្តសេចក្តីសង្កេតចុងក្រោយ។ ចំណែកឯគណៈកម្មាធិការសិទ្ធិមនុស្សវិញ នៅពេលបានទទួលរបាយការណ៍តាមដានពីភាគីរដ្ឋមួយ អ្នករាយការណ៍ពិសេសទទួលបន្ទុកកិច្ចការតាមដាន រៀបចំរបាយការណ៍វឌ្ឍនភាពមួយនៅសម័យប្រជុំនីមួយៗ ដែលដាក់បញ្ចូលសេចក្តីសង្ខេបនៃរបាយការណ៍ តាមដានរបស់រដ្ឋភាគី និងព័ត៌មានពី CSOs និងពីប្រភពដទៃទៀត ក៏ដូចជាការវាយតម្លៃ របស់គណៈកម្មាធិការផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យវាយតម្លៃតាមដានរបស់គណៈកម្មាធិការ (សូមមើលតារាងខាងក្រោម)។ គណៈកម្មាធិការនេះ ជូនដំណឹងបន្ថែមដល់រដ្ឋភាគីអំពីការសម្រេចលើរបាយការណ៍តាមដាន។ ប្រសិនបើរដ្ឋភាគីមួយមិនសហការជាមួយនីតិវិធីតាមដាន ឬអនុម័តវិធានការដែលគណៈកម្មាធិការមិនពេញចិត្ត អ្នករាយការណ៍អាចស្នើសុំឲ្យមានជំនួបប្រជុំមួយជាមួយតំណាងមួយរូបនៃរដ្ឋភាគីនោះ។

## លក្ខណៈវិនិច្ឆ័យវាយតម្លៃការតាមដានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស

ការឆ្លើយតប/ចំណាត់ការពេញចិត្ត

A ការឆ្លើយតបពេញចិត្តភាគច្រើន

### ការឆ្លើយតប/ចំណាត់ការពេញចិត្តដោយអន្លើ

B1 វិធានការជាក់លាក់ត្រូវបានចាត់ឡើង ប៉ុន្តែត្រូវការព័ត៌មានបន្ថែម

B2 វិធានការដំបូងត្រូវបានចាត់ឡើង ប៉ុន្តែត្រូវការព័ត៌មានបន្ថែម

### ការឆ្លើយតប/ចំណាត់ការ មិនពេញចិត្ត

C1 ការឆ្លើយតបត្រូវបានទទួល ប៉ុន្តែវិធានការដែលបានចាត់ឡើង មិនអនុវត្តអនុសាសន៍

C2 ការឆ្លើយតបត្រូវបានទទួល ប៉ុន្តែមិនពាក់ព័ន្ធនឹងអនុសាសន៍

### គ្មានកិច្ចសហការជាមួយគណៈកម្មាធិការ

D1 មិនមានការឆ្លើយតបត្រូវបានទទួលតាមកាលបរិច្ឆេទកំណត់ ឬមិនមានការឆ្លើយតបទៅនឹងសំណួរជាក់លាក់ណាមួយនៅក្នុងរបាយការណ៍

D2 មិនមានការឆ្លើយតបត្រូវបានទទួល បន្ទាប់ពីធ្វើការរំលឹក

### វិធានការដែលចាត់ឡើង គឺផ្ទុយពីអនុសាសន៍របស់គណៈកម្មាធិការ

E ការឆ្លើយតបបង្ហាញថា វិធានការដែលបានចាត់ឡើង គឺផ្ទុយពីអនុសាសន៍របស់គណៈកម្មាធិការ

## *តើសង្គមស៊ីវិលអាចចូលរួមបានដូចម្ដេច ?*

ស្រដៀងគ្នានឹងរបាយការណ៍ "ស្រមោល" ឬ "ជំនួស" ដែលបានដាក់ជូនសម្រាប់ធ្វើការពិចារណាដល់របាយការណ៍ និងបញ្ជីបញ្ហារបស់ភាគីរដ្ឋដែរ CSAs អាចបញ្ជូនព័ត៌មានក្នុងក្របខណ្ឌនៃនីតិវិធីតាមដាន។ ក្នុងករណីនេះ ឯកសារដែលបញ្ជូនគួរផ្ដោតជាក់លាក់ទៅលើអនុសាសន៍ដែលបានកំណត់នៅក្នុងសេចក្ដីសង្កេតចុងក្រោយសម្រាប់នីតិវិធីតាមដាន និងមានព័ត៌មានច្បាស់លាស់[16] អំពីវិធានការដែលអាជ្ញាធរបានចាត់ឡើង និងវាយតម្លៃអំពីប្រសិទ្ធភាពនៃវិធានការទាំងនោះ។ ការខកខានណាមួយក្នុងការចាត់វិធានការចាំបាច់ ដើម្បីអនុវត្តអនុសាសន៍ទាំងនេះ ក៏អាចលើកឡើងផងដែរ។ CSAs អាចផ្ដល់យោបល់អំពីការឆ្លើយតបដែលរដ្ឋបានផ្ដល់។ ការដាក់របាយការណ៍របស់ CSA ជូននីតិវិធីតាមដាន ត្រូវអនុវត្តតាមវិធានដូចគ្នាស្ដីពីការដាក់របាយការណ៍ដែលបានផ្ដល់ សម្រាប់ពិចារណាទៅលើរបាយការណ៍ និងបញ្ជីបញ្ហារបស់រដ្ឋភាគី ហើយត្រូវបានចាត់ទុកថា ជាឯកសារសាធារណៈ និងមាននៅលើវេបសាយរបស់ OHCHR ឬជាឯកសារសម្ងាត់ ប្រសិនបើមានការស្នើសុំពីអង្គការដែលបានដាក់ជូននោះ។

### ការប្រើប្រាស់សេចក្ដីសង្កេតចុងក្រោយរបស់ CRC នៅថ្នាក់ជាតិ

ដើម្បីលើកកម្ពស់វិធីសាស្ត្រលក្ខណៈជាវដ្ដ(វិលជុំ) ក្នុងការចូលរួមក្នុងដំណើរការរាយការណ៍របស់គណៈកម្មាធិការសិទ្ធិកុមារ(CRC) និងដើម្បីលើកទឹកចិត្តសង្គមស៊ីវិលប្រើអនុសាសន៍របស់ CRC ឲ្យបានពេញលេញនៅក្នុងការងារតស៊ូមតិរបស់ខ្លួន អង្គការ Child Rights Connect បានចងក្រងករណីសិក្សាមួយចំនួនស្ដីពីសកម្មភាពតាមដានដែលធ្វើឡើងដោយ CSAs និងស្ថាប័នសិទ្ធិមនុស្សជាតិ។[17]

សមាជិកស្ថាប័នសន្ធិសញ្ញាក៏អាចចូលរួមផងដែរ នៅក្នុងសិក្ខាសាលាថ្នាក់តំបន់ អនុតំបន់ ឬថ្នាក់ជាតិ ស្ដីពីការអនុវត្តដែលរៀបចំឡើងដោយសង្គមស៊ីវិល ទីភ្នាក់ងារ អ.ស.ប និងការិយាល័យ OHCHR ឬរដ្ឋាភិបាល។ ការចូលរួមរបស់សង្គមស៊ីវិលក្នុងសិក្ខាសាលាទាំងនេះ ត្រូវបានជម្រុញលើកទឹកចិត្ត។

---

[16] គណៈកម្មាធិការ ស៊ី ដ ស្នើថា របាយការណ៍ដាក់បញ្ជូនមិនត្រូវឲ្យលើសចំនួនអតិបរមា ៣.៥០០ ពាក្យឡើង។

[17] មាននៅលើវេបសាយ www.childrightsnet.org/NGOGroup/CRC/FollowUp/

## ទស្សនកិច្ចតាមដានរបស់អនុគណៈកម្មាធិការបង្ការទារុណកម្ម

អនុគណៈកម្មាធិការបង្ការទារុណកម្ម (SPT) ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧ ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម បំពេញទស្សនកិច្ចស្វែងរកការពិតទៅកាន់កន្លែងឃុំឃាំងផ្សេងៗ និងកន្លែងដទៃទៀតដែលមានការដកហូតសិទ្ធិសេរីភាពនៅក្នុងទឹកដីនៃរដ្ឋភាគី រួមទាំងនៅប៉ុស្តិ៍នគរបាល ពន្ធនាគារ ស្ថាប័នគាំពារសង្គម និងស្ថាប័នគាំពារសុខភាពផ្លូវចិត្ត ។ នៅពេលបញ្ចប់ដំណើរទស្សនកិច្ចទៅកាន់ប្រទេស អនុគណៈកម្មាធិការនេះបញ្ជូនអនុសាសន៍ និងការរកឃើញរបស់ខ្លួនទៅកាន់រដ្ឋភាគី តាមរយៈរបាយការណ៍សម្ងាត់។

ប្រសិនជា SPT យល់ថា សមស្រប ខ្លួនអាចស្នើសុំធ្វើទស្សនកិច្ចតាមដានរយៈពេលខ្លីមួយបន្ទាប់ពីទស្សនកិច្ចទៀងទាត់នោះ។ នៅក្នុងខែកញ្ញា ឆ្នាំ២០១០ SPT បានធ្វើទស្សនកិច្ចតាមដានលើកដំបូងរបស់ខ្លួនទៅកាន់ប្រទេសអ៊ុយរ៉ាហ្គាយ ដែលក្នុងនោះសង្គមស៊ីវិលក៏បានចូលរួមដែរ។

## *ការតាមដានសេចក្តីសម្រេចស្តីពីបណ្តឹងលក្ខណៈជាបុគ្គល*

ក្រោមកាលៈទេសៈមួយចំនួនស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ក៏អាចពិចារណាទៅលើបណ្តឹង ឬការទំនាក់ទំនងជាលក្ខណៈបុគ្គលផងដែរ។[18] ក្រោមនីតិវិធីនេះ បុគ្គលណាដែលអះអាងថាសិទ្ធិរបស់ខ្លួនក្រោមសន្ធិសញ្ញាជាក់លាក់ណាមួយ ត្រូវបានគេរំលោភ អាចដាក់ពាក្យបណ្តឹងមកស្ថាប័នសន្ធិសញ្ញាប្រឆាំងនឹងរដ្ឋមួយដែលជាភាគីនៃលិខិតូបករណ៍នេះ និងដែលបានទទួលស្គាល់សមត្ថកិច្ចរបស់ស្ថាប័នសន្ធិសញ្ញាដើម្បីពិចារណាលើពាក្យបណ្តឹងពីបុគ្គល។ ជាដំបូង ពាក្យបណ្តឹងនឹងត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខខណ្ឌនៃការទទួលយកមកពិនិត្យពិចារណា។ ប្រសិនបើអាចទទួលយកបានពាក្យបណ្តឹងនោះនឹងត្រូវបានពិចារណាទៅលើអង្គសេចក្តីរបស់វា ហើយស្ថាប័នសន្ធិសញ្ញាចេញសេចក្តីសម្រេចមួយអំពីថា តើពិតជាមានការរំលោភទៅលើបទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញាបានកើតឡើងដែរឬទេ។ ប្រសិនបើស្ថាប័នសន្ធិសញ្ញាសម្រេចថា អ្នកដាក់ពាក្យប្តឹងគឺជាជនរងគ្រោះដោយអំពើរំលោភណាមួយស្ថាប័ននេះ តម្រូវឲ្យរដ្ឋផ្តល់ព័ត៌មានជាធម្មតាក្នុងអំឡុងពេលប្រាំមួយខែ អំពីវិធានការដែលរដ្ឋបានចាត់ឡើង ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នសន្ធិសញ្ញា។ បន្ទាប់មកការឆ្លើយតបរបស់រដ្ឋ នឹងត្រូវបានបញ្ជូនទៅអ្នកដាក់ពាក្យបណ្តឹង ដែលគាត់អាចផ្តល់សេចក្តីសង្កេតអំពីការឆ្លើយតបរបស់រដ្ឋ។

---

[18] គិតត្រឹមខែកក្កដា ឆ្នាំ២០១៣ នីតិវិធីនេះមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាប្រឆាំងទារុណកម្ម អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ កតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ នីតិវិធីនេះ នឹងចូលជាធរមានសម្រាប់អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ និងសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ នៅពេលរដ្ឋភាគីចំនួន ១០ បានធ្វើសេចក្តីប្រកាសចាំបាច់ក្រោមមាត្រា៧៧ នៃអតីតពិធីសារបន្ថែម ហើយបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមចុងក្រោយបំផុតនៃអនុសញ្ញានេះ។

ស្ថាប័នសន្ធិសញ្ញាខ្លះ ជាពិសេស គណៈកម្មាធិការសិទ្ធិមនុស្ស CAT CERD និង CEDAW បានចាប់ផ្តើមអនុវត្តនីតិវិធី ដើម្បីឃ្លាំមើលការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការ។ នីតិវិធីបែបនេះ មាននៅក្នុងការតែងតាំងអ្នករាយការណ៍មួយរូប ដែលមានភារកិច្ចតាមដានការអនុវត្តសេចក្តីសម្រេច។ នីតិវិធីទាំងនេះ ត្រូវបានតែងតាំងសម្រាប់រយៈពេលមួយ ឬ ក្នុងករណី CEDAW ដើម្បីតាមដានករណីជាក់លាក់មួយចំនួន។ នៅពេលមានការឆ្លើយតបរបស់រដ្ឋទៅលើវិធានការដែលបានចាត់ឡើងដើម្បីអនុវត្តសេចក្តីសម្រេច មិនពេញចិត្ត ឬមិនបានកើតឡើង អ្នករាយការណ៍អាចធ្វើការពិគ្រោះយោបល់ជាមួយអ្នកតំណាងការទូតរបស់រដ្ឋភាគី ជាធម្មតា អ្នកការទូតនៃបេសកកម្មអចិន្ត្រៃយ៍នៅក្នុងក្រុងហ្សឺណែវ ឬញូវយ៉ក។

## *តើសង្គមស៊ីវិលអាចចូលរួមដោយវិធីណា?*

ក្នុងករណី CSAs ពាក់ព័ន្ធក្នុងបណ្តឹងបុគ្គល (ឧទា. ពីព្រោះពួកគេបានជួយម្ចាស់បណ្តឹងក្នុងការដាក់ញត្តិ) ពួកគេអាចផ្តល់ព័ត៌មានអំពីថាតើសេចក្តីសម្រេចនោះ ត្រូវបានគេអនុវត្តយ៉ាងដូចម្តេច?

### វាយតម្លៃការអនុវត្តសេចក្តីសម្រេចសិទ្ធិមនុស្ស

នៅក្នុងឆ្នាំ២០១០ អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សង្គមចំហ (Open Society Justice Initiative) បានបោះពុម្ពផ្សាយរបាយការណ៍ "ពីសាលក្រមទៅយុត្តិធម៌" (From judgment to justice)-អនុវត្តសេចក្តីសម្រេចសិទ្ធិមនុស្សអន្តរជាតិ និងតំបន់ ដែលពិនិត្យមើលបញ្ហាប្រឈមក្នុងការការអនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ និងតំបន់ ជាអាទិ ស្ថាប័នសន្ធិសញ្ញា អ.ស.ប ប្រព័ន្ធអាហ្វ្រិក អឺរ៉ុប និងអន្តរអាមេរិក។ របាយការណ៍នេះ ពិចារណាថា ទោះបីជាមានសមិទ្ធផលកាលពី២៥ឆ្នាំកន្លងទៅក្តី ប្រព័ន្ធទាំងអស់នេះ ជួបប្រទះឧបសគ្គក្នុងការប្រែក្លាយសាលក្រមរបស់ពួកគេឲ្យទៅជាការផ្លាស់ប្តូរជាក់ស្តែងនៅហ្នឹងកន្លែង។ នៅក្នុងករណីជាច្រើន សេចក្តីសម្រេចធំៗមិនទាន់បានផ្តល់នូវកំណែទម្រង់ប្រកបដោយអត្ថន័យនៅឡើយទេ។

នៅពេលវិភាគលើការអនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នសន្ធិសញ្ញា របាយការណ៍បានរកឃើញថា "ជាទូទៅ ការអនុវត្តដោយជោគជ័យបានកើតឡើងក្នុងករណីទាំងឡាយដែលមានចរិតនយោបាយខ្ពស់និងករណីទាំងឡាយដែលត្រូវបានប្តឹងប្រឆាំងនឹងរដ្ឋដែលមានប្រពៃណីនីតិរដ្ឋស្មុគស្មាញ"។ ប្រសិនបើមានការអនុវត្តកើតមានឡើងជាញឹកញាប់ គឺដោយសារតែសង្គមស៊ីវិលខ្លាំងដែលមានសមត្ថភាពបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងតាមដានរបស់គណៈកម្មាធិការ និងដោយសារតែមានការប្រើសម្ពាធផ្សេងទៀតនៅក្នុងស្រុក។

## ៥.២. ក្រុមប្រឹក្សាសិទ្ធិមនុស្ស

### *ការតាមដានអំពីការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស*

សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៦០/២៥១ ដែលបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្ស (ហៅកាត់ថា ក្រុមប្រឹក្សា) បានសម្រេចថា វិធីសាស្រ្តនៃការងាររបស់ក្រុមប្រឹក្សាតម្រូវឲ្យមានការពិភាក្សាតាមដានទៅលើអនុសាសន៍ និងការអនុវត្តអនុសាសន៍។

ក្រុមប្រឹក្សាតាមដានបញ្ហាសិទ្ធិមនុស្សដែលខ្លួនបានពិភាក្សាតាមរយៈ៖

- លើកអំណះអំណាងជាក់លាក់ដើម្បីតាមដាននៅក្នុងសេចក្តីសម្រេចចិត្ត និងការសម្រេចដែលក្រុមប្រឹក្សាបានអនុម័ត។ ជាធម្មតា សេចក្តីសម្រេចចិត្ត (Resolutions) មានបទបញ្ញត្តិដែលចែងថា ក្រុមប្រឹក្សា "នៅតែយកចិត្តទុកដាក់លើបញ្ហានេះ" ។ មានន័យថា ប្រធានបទនេះនឹងនៅតែជាប្រធានបទមួយ ដែលជាកម្មវត្ថុនៃការពិភាក្សាក្នុងក្រុមប្រឹក្សានាសម័យប្រជុំថ្ងៃខាងមុខ។

- រៀបចំកិច្ចប្រជុំរបស់ខ្លួននៅក្នុងសម័យប្រជុំទៀងទាត់ និងសម័យប្រជុំពិសេសផ្អែកតាមចំណុចនៃរបៀបវារៈដែលត្រូវបានលើកឡើងដដែលៗ។ ច្បាស់ណាស់ នេះគឺជាករណីនៃសម័យប្រជុំទៀងទាត់ ទោះបីជាសម័យប្រជុំពិសេស ក៏អាចត្រូវបានគេរៀបចំឡើងផងដែរដើម្បីពិភាក្សាអំពីប្រធានបទដូចគ្នា ឬស្រដៀងគ្នាក៏ដោយ (ឧទា. សម័យប្រជុំពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅសាធារណរដ្ឋអារ៉ាប់ស៊ីរី (Syrian Arab Republic) ក្នុងឆ្នាំ២០១១ និង ២០១២)។

- ប្រគល់ភារកិច្ចឲ្យយន្តការរបស់ខ្លួន រួមទាំងនីតិវិធីពិសេស ឬអង្គភាពចំណុះ ឬការិយាល័យ OHCHR ដើម្បីត្រូវចាត់វិធានការមួយចំនួនជាក់លាក់ ហើយរាយការណ៍ត្រឡប់ទៅក្រុមប្រឹក្សាវិញ ក្នុងសម័យប្រជុំមួយនៅថ្ងៃខាងមុខ។ ក្រុមប្រឹក្សានេះ អាចសម្រេចបង្កើតផងដែរនូវយន្តការចំពោះកិច្ចមួយ (ad hoc mechanism) ដូចជាគណៈកម្មការស៊ើបអង្កេត ឬបេសកកម្មស្វែងរកការពិតដែលមានអាណត្តិស៊ើបអង្កេតការរំលោភសិទ្ធិមនុស្សនិងដាក់របាយការណ៍អំពីការរកឃើញជូនក្រុមប្រឹក្សាពិនិត្យពិចារណា។ កិច្ចការដទៃទៀត ដែលជាធម្មតា ដោយក្រុមប្រឹក្សាជាអ្នកប្រគល់ឲ្យរួមមានការធ្វើឲ្យសម្រេចបាននូវការសិក្សាស្រាវជ្រាវ ឬការរៀបចំកិច្ចប្រជុំអ្នកជំនាញ ឬគណៈវាគ្មិន។

### *តើសង្គមស៊ីវិល អាចចូលរួមដោយវិធីណា?*

នីតិវិធីតាមដានដែលបានរៀបរាប់ខាងលើ គឺជាវិធីសាស្ត្រស្តង់ដាការងាររបស់ក្រុមប្រឹក្សា។ ដូច្នេះ នីតិវិធីសម្រាប់ការចូលរួមរបស់សង្គមស៊ីវិល គឺដូចគ្នា ហើយត្រូវរាប់បញ្ចូលនូវលទ្ធភាពសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ទទួលបានឋានៈចូលរួមពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា

សេដ្ឋកិច្ចសង្គម (ECOSOC) ធ្វើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ព្រមទាំងរៀបចំព្រឹត្តិការណ៍ស្របគ្នា។ អង្គការមិនមែនរដ្ឋាភិបាលដែលមិនធ្វើដំណើរទៅទីក្រុងហ្សឺណែវ ដើម្បីចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អាចធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់តាមរយៈសារវីដេអូសម្រាប់ចំណុចខ្លះនៃរបៀបវារៈ។ ដើម្បីទទួលបានការណែនាំបន្ថែម សូមមើលកូនសៀវភៅព័ត៌មានរបស់ការិយាល័យOHCHR សម្រាប់សង្គមស៊ីវិល - អំពីការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងអំពីមគ្គុទ្ទេសក៍អនុវត្តជាក់ស្តែងរបស់ការិយាល័យ OHCHR សម្រាប់សង្គមស៊ីវិលស្តីពីក្រុមប្រឹក្សាសិទ្ធិមនុស្ស[19] ក៏ដូចជាគេហទំព័ររបស់ការិយាល័យ OHCHR។[20]

បន្ថែមពីលើសេចក្តីថ្លែងការណ៍លាយលក្ខណ៍អក្សរ និងផ្ទាត់មាត់ និងព្រឹត្តិការណ៍ស្របគ្នា វាគឺជាការប្រតិបត្តិស្តង់ដាមួយដែលត្រូវអញ្ជើញសង្គមស៊ីវិល ដើម្បីចូលរួមចំណែកដល់ការសិក្សាស្រាវជ្រាវនិងចូលរួមក្នុងកិច្ចប្រជុំអ្នកជំនាញ និងគណៈវាគ្មិនដែលក្រុមប្រឹក្សាបានផ្តល់អាណត្តិការងារ។ បន្ថែមពីលើនេះ អង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការចំហ ដែលធ្វើឡើងក្នុងពេលដំណាលគ្នានឹងក្រុមប្រឹក្សា ដើម្បីពិភាក្សាខ្លឹមសារនៃសេចក្តីព្រាងសេចក្តីសម្រេចចិត្ត។

ជាចុងក្រោយ សេចក្តីសម្រេចចិត្ត និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រដ្ឋក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។ ជាថ្មីម្តងទៀត សង្គមស៊ីវិលអាចរៀបចំផ្តល់អាទិភាព និងចាត់វិធានការដើម្បីជំរុញការអនុវត្តការប្តេជ្ញាចិត្តសិទ្ធិមនុស្សដែលមានចែងនៅក្នុងសេចក្តីសម្រេចចិត្ត និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដែលពួកគេមានចំណាប់អារម្មណ៍។

## *គណៈកម្មការ យន្តការ និងអាណត្តិក្រោមឱវាទ*

អនុសាសន៍មួយចំនួនធំ ត្រូវបានចេញដោយគណៈកម្មការនិងយន្តការ ក្រោមឱវាទរបស់ក្រុមប្រឹក្សារួមមាន៖

- ការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (សូមមើលផ្នែកទី ៥.៤ នៃមគ្គុទ្ទេសក៍)
- គណៈកម្មាធិការប្រឹក្សាយោបល់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស
- នីតិវិធីបណ្តឹង
- នីតិវិធីពិសេស (សូមមើលផ្នែកទី ៥.៣. នៃមគ្គុទ្ទេសក៍)
- វេទិកាសង្គម;

[19] មាននៅលើវេបសាយ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

[20] មាននៅលើវេបសាយ www.ohchr.org/EN/HRBodies/HRC/Pages/NgoParticipation.aspx

- វេទិកាស្តីពីបញ្ហាក្រុមភាគតិច
- យន្តការអ្នកជំនាញស្តីពីសិទ្ធិជនជាតិដើមភាគតិច និង
- វេទិកាស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។

សម្រាប់ការណែនាំស្តីពីការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងគណៈកម្មការទាំងនេះ សូមមើលកូនសៀវភៅព័ត៌មានរបស់ OHCHR សម្រាប់សង្គមស៊ីវិល - អំពីការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ មគ្គុទ្ទេសក៍ជាក់ស្តែងសម្រាប់សង្គមស៊ីវិលស្តីពីក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមគ្គុទ្ទេសក៍ជាក់ស្តែងស្តីពីវេទិកាសង្គម។[21]

## ៥.៣. នីតិវិធីពិសេស

### *ទស្សនកិច្ចតាមដានទៅកាន់ប្រទេស*

អ្នកកាន់អាណត្តិនីតិវិធីពិសេស ទាមទារឲ្យមានការអញ្ជើញពីរដ្ឋាភិបាលដើម្បីធ្វើទស្សនកិច្ចទៅកាន់ប្រទេស។ នីតិវិធីពិសេស ធ្វើការតាមដានសំណើសុំទស្សនកិច្ចរបស់ពួកគេតាមរយៈ៖

- ផ្សព្វផ្សាយសំណើសុំទស្សនកិច្ចរបស់ពួកគេជាសាធារណៈនៅក្នុងរបាយការណ៍ នៅលើគេហទំព័ររបស់ពួកគេ ក្នុងអំឡុងពេលព្រឹត្តិការណ៍សាធារណៈ និងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។
- ជួបប្រជុំជាមួយតំណាងការទូតនៃបណ្តាប្រទេសសាមី
- ធ្វើទស្សនកិច្ចការងារទៅកាន់ប្រទេស ឬតំបន់ណាមួយ ដែលអាចត្រួសត្រាយផ្លូវទៅរកការអញ្ជើញជាផ្លូវការមួយ (ឧទា. ធ្វើការចុះទស្សនកិច្ចជាលក្ខណៈសិក្សាអប់រំ) និង
- សរសេរលិខិតរំលឹកជាផ្លូវការអំពីសំណើរបស់ពួកគេ និងផ្សព្វផ្សាយជាសាធារណៈ។

នៅពេលទស្សនកិច្ចមួយបានកើតឡើង នីតិវិធីពិសេសបានរៀបចំការអនុវត្តការងារតាមដានជាក់ស្តែងមួយចំនួន។ ការអនុវត្តការងារតាមដានជាក់ស្តែងទាំងនោះរួមមាន៖

**១.ទស្សនកិច្ចតាមដានទៅកាន់ប្រទេស៖** អ្នកកាន់អាណត្តិមួយចំនួនធ្វើទស្សនកិច្ចតាមដានបន្តពីបេសកកម្មលើកមុនមកទៅកាន់ប្រទេស។ ទស្សនកិច្ចទាំងនេះធ្វើឡើងក្នុងគោលដៅវាយតម្លៃឲ្យបានហ្មត់ចត់អំពីវឌ្ឍនភាពនិងឧបសគ្គដើម្បីវាស់វែងប្រៀបធៀបគ្នានឹងអ្វីដែលបានរកឃើញ និងអនុសាសន៍ពីទស្សនកិច្ចលើកមុន។ ទស្សនកិច្ចតាមដាន គឺជាការអនុវត្តជាក់ស្តែងល្អមួយ ប៉ុន្តែទស្សនកិច្ចបែបនេះមានតែពីរបីប៉ុណ្ណោះក្នុងចំណោមទស្សនកិច្ចចំនួន ៤០-៥០ ដង ក្នុងមួយឆ្នាំទៅកាន់ប្រទេស ដែលធ្វើឡើងដោយនីតិវិធីពិសេស ជាទស្សនកិច្ចតាមដាន ដោយសារតែខ្វះខាតធនធាន។

[21]មាននៅលើវេបសាយ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

## ឧទាហរណ៍អំពីទស្សនកិច្ចតាមដានទៅកាន់ប្រទេស

អ្នករាយការណ៍ពិសេស ស្តីពីការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ

➔ 2012: ហ្គាតេម៉ាឡា ( Guatemala ) ( A/HRC/22/54/Add.1 )

អ្នករាយការណ៍ពិសេសស្តីពីទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប

➔ 2012: អ៊ុយរ៉ាហ្គាយ ( Uruguay ) ( A/HRC/22/53/Add.3 )

អ្នករាយការណ៍ពិសេសស្តីពីទម្រង់សហសម័យនៃការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ ការស្អប់ជនបរទេស និងការមិនអត់ឱនពាក់ព័ន្ធដទៃទៀត

➔ 2011: ហុងហ្គារី ( Hungary ) ( A/HRC/20/33/Add.1 )

អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាប្រឆាំងស្ត្រីភេទ មូលហេតុ និងផលវិបាករបស់វា

➔ 2011: សហរដ្ឋអាមេរិក ( A/HRC/17/26/Add.5 )

➔ 2010: អែលសាវ៉ាឌ័រ ( El Salvador ) ( A/HRC/17/26/Add.2 ) និង Algeria ( A/HRC/17/26/Add.3 )

អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ខណៈពេលប្រយុទ្ធប្រឆាំងភេរវកម្ម

➔ 2011: ទុយនេស៊ី ( Tunisia ) ( A/HRC/16/51/Add.2 )

**២.របាយការណ៍តាមដាន៖** នីតិវិធីពិសេសមួយចំនួន បោះពុម្ពផ្សាយរបាយការណ៍តាមដានដោយផ្អែកលើព័ត៌មានដែលរដ្ឋាភិបាល ស្ថាប័នជាតិសិទ្ធិមនុស្ស និងសង្គមស៊ីវិលផ្តល់ឲ្យ។ ការអនុវត្តជាក់ស្តែងគួរឲ្យចាប់អារម្មណ៍នៃរបាយ ការណ៍តាមដានចំពោះទស្សនកិច្ចក្នុងប្រទេស ត្រូវបានបង្កើតឡើងដោយក្រុមការងារទទួល បន្ទុកការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្តអ្នករាយការណ៍ពិសេសស្តីពីទារុណកម្ម អ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ក្រៅច្បាប់ភ្លាមៗ ឬដោយបំពាន អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្ស និងភាពក្រីក្របំផុត និងអ្នករាយការណ៍ ពិសេសស្តីពីសេរីភាពខាងសាសនា ឬជំនឿ។

## របាយការណ៍តាមដានរបស់ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយ ដោយបង្ខំ និងដោយមិនស្ម័គ្រចិត្ត

ក្នុងឆ្នាំ២០១០ ក្រុមការងារតាមដានការបាត់ខ្លួនដោយបង្ខំ និងដោយមិនស្ម័គ្រចិត្ត បានអនុម័តទម្រង់មួយសម្រាប់របាយការណ៍តាមដានរបស់ខ្លួន បានរៀបចំកិច្ចប្រជុំតុមូលដែលឆ្លុះបញ្ចាំងពីអនុសាសន៍របស់ក្រុមការងារ សេចក្តីបរិយាយខ្លីមួយអំពីស្ថានភាពនៅពេលបានធ្វើទស្សនកិច្ចទៅកាន់ប្រទេស និងទិដ្ឋភាពរួមនៃវិធានការដែលបានចាត់ឡើងផ្អែកលើព័ត៌មានដែលក្រុមការងារប្រមូលបានទាំងពីប្រភពរដ្ឋាភិបាល និងពីប្រភពមិនមែនរដ្ឋាភិបាល។ ចាប់ពីពេលនោះមក ក្រុមការងារបានចេញរបាយការណ៍តាមដានស្តីពីវឌ្ឍនភាព និងឧបសគ្គក្នុងស្ថានភាពនៃការបាត់ខ្លួនដោយបង្ខំ បន្ទាប់ពីទស្សនកិច្ចទៅកាន់ប្រទេសកូឡុំប៊ី អែលសាវ៉ាឌ័រ ហ្គាតេម៉ាឡា ហុងឌូរ៉ាស ម៉ូរ៉ុកកូ និងនេប៉ាល់។

## តារាងតាមដានរបស់អ្នករាយការណ៍ពិសេសស្តីពីសេរីភាព ខាងសាសនា ឬជំនឿ

អ្នករាយការណ៍ពិសេសស្តីពីសេរីភាពខាងសាសនា ឬជំនឿ បញ្ជូនលិខិតតាមដានបន្ទាប់ពីបានទស្សនកិច្ចទៅកាន់ប្រទេស ដើម្បីទទួលព័ត៌មានបច្ចុប្បន្នភាពអំពីការអនុវត្តអនុសាសន៍នៅថ្នាក់ជាតិ។ តារាងតាមដានស្តីពីបណ្តាប្រទេសដែលបានបំពេញទស្សនកិច្ចចាប់ពីឆ្នាំ ២០០៥ មានសេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្សេងៗ ពីរបាយការណ៍ទស្សនកិច្ចទៅកាន់ប្រទេស និងព័ត៌មានតាមដានពីឯកសារពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ រួមទាំងពីយន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ នីតិវិធីពិសេស និងស្ថាប័នសន្ធិសញ្ញា។[22]

**៣. ព្រឹត្តិការណ៍តាមដាន៖** ទោះជាធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់នីតិវិធី រដ្ឋាភិបាល ស្ថាប័នជាតិសិទ្ធិមនុស្ស សង្គមស៊ីវិល ឬការិយាល័យ OHCHR ក្តី ក៏ព្រឹត្តិការណ៍តាមដានថ្នាក់ជាតិ ថ្នាក់តំបន់ ឬអន្តរជាតិ អាចមានសារៈប្រយោជន៍ក្នុងការវាយតម្លៃពីវឌ្ឍនភាព និងចែករំលែកបទពិសោធន៍ និងបញ្ហាប្រឈមក្នុងការអនុវត្តអនុសាសន៍ដែលបានមកពីទស្សនកិច្ចទៅកាន់ប្រទេសដែរ។ ព្រឹត្តិការណ៍បែបនេះអាចកើតឡើងក្នុងទម្រង់ជាកិច្ចពិភាក្សាតុមូល កិច្ចប្រជុំអ្នកជំនាញ ឬសន្និសីទ។

[22] មាននៅលើវេបសាយ www.ohchr.org/EN/Issues/FreedomReligion/Pages/Visits.aspx

## សិក្ខាសាលាស្តីពីទាសភាពនៅក្នុងប្រទេសម៉ូរីតានី (Mauritania)

ក្នុងខែមករា ឆ្នាំ២០១៣ អ្នករាយការណ៍ពិសេសស្តីពីទម្រង់សហសម័យនៃទាសភាព បានចូលរួមក្នុងសិក្ខាសាលាតាមដានស្តីពីការអនុវត្តអនុសាសន៍ដែលលោកស្រីបានធ្វើឡើង បន្ទាប់ពីទស្សនកិច្ចរបស់លោកស្រីទៅកាន់ប្រទេសម៉ូរីតានី។ មន្ត្រីរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (CSOs) ដែលចូលរួមក្នុងសិក្ខាសាលានោះ បានបង្កើតផែនទីបង្ហាញផ្លូវមួយសម្រាប់អនុវត្តអនុសាសន៍ដែលអ្នករាយការណ៍ពិសេសបានធ្វើឡើង។ ការិយាល័យOHCHR នៅក្នុងប្រទេសម៉ូរីតានី បានធ្វើការជាមួយអង្គការសង្គមស៊ីវិល( CSOs) ដើម្បីលើកទឹកចិត្តរដ្ឋាភិបាលឲ្យអនុម័ត និងអនុវត្តជាផ្លូវការតាមផែនទីបង្ហាញផ្លូវនេះ។

## ការផ្សព្វផ្សាយការរកឃើញអំពីស្ថានភាពរបស់ជនជាតិដើមភាគតិច ក្នុងប្រទេសឈីលី និងអាហ្សង់ទីន

ក្នុងខែមករា ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច បានធ្វើសន្និសីទវីដេអូមួយទាក់ទងនឹងសិទ្ធិជនជាតិដើមភាគតិចនៅប្រទេសឈីលី។ សន្និសីទវីដេអូនេះ ត្រូវបានផ្សាយក្នុងពេលដំណាលគ្នានៅទីក្រុងចំនួនប្រាំនៃប្រទេសឈីលី ដោយមានការគាំទ្រពីអង្គការសង្គមស៊ីវិល (CSAs) និងការិយាល័យថ្នាក់តំបន់របស់ OHCHR ប្រចាំអាមេរិកខាងត្បូង។ នៅក្នុងបទបង្ហាញរបស់លោក អ្នករាយការណ៍ពិសេសបានពន្យល់ពីសេចក្តីសន្និដ្ឋាន និងការរកឃើញរបស់គាត់ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ប្រចាំប្រទេសគាត់។

ក្នុងឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានលើកសារជាថ្មីអំពីបទពិសោធន៍នៅប្រទេសអាហ្សង់ទីន ដែលនៅទីនោះ សន្និសីទវីដេអូត្រូវបានរៀបចំឡើងដោយក្រុមអ.ស.បប្រចាំប្រទេស។

### *តើសង្គមស៊ីវិលអាចចូលរួមដោយវិធីណា?*

- ស្នើសុំឲ្យមានទស្សនកិច្ច
  - ស្នើដល់អ្នកកាន់អាណត្តិថា ពួកគេស្នើសុំធ្វើទស្សនកិច្ចមកកាន់ប្រទេសរបស់ខ្លួន និង ផ្តល់ព័ត៌មានច្បាស់លាស់ ដើម្បីអះអាងហេតុផលដល់ទស្សនកិច្ចនោះ
  - ដឹងអំពីសំណើសុំធ្វើទស្សនកិច្ចដែលមិនទាន់មានការឆ្លើយតប តាមរយៈអ៊ីម៉ែលបច្ចុប្បន្ន ភាពសង្គមស៊ីវិលរបស់ការិយាល័យ OHCHR
  - តស៊ូមតិជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត

(ឧទា. សមាជិកសភា បេសកកម្មការទូត) ដើម្បីទទួលយកសំណើសុំធ្វើទស្សនកិច្ច

- ចូលរួមក្នុងការរៀបចំ និងការធ្វើឲ្យសម្រេចបាននូវទស្សនកិច្ចតាមដាន
- ចូលរួមចំណែកផ្តល់ព័ត៌មានសំរាប់របាយការណ៍តាមដាន
- នៅពេលអាចធ្វើទៅបាន ស្នើសុំចូលរួម និងជួយរៀបចំព្រឹត្តិការណ៍តាមដាននានា។

## *ការតាមដានលិខិត*

របាយការណ៍ទំនាក់ទំនងរួមគ្នា ត្រូវបានបញ្ជូនដោយនីតិវិធីពិសេសទាំងអស់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនាសម័យប្រជុំទៀងទាត់នីមួយៗ។ របាយការណ៍ទំនាក់ទំនងរួមគ្នា ត្រូវបានចេញបីដងក្នុងមួយឆ្នាំ ដែលមានបញ្ចូលនូវសេចក្តីសង្ខេបអំពីការអះអាងផ្សេងៗ ដែលបានបញ្ជូនទៅរដ្ឋនីមួយៗ ឬអង្គភាពដទៃទៀត។ អត្ថបទនៃលិខិតដែលបញ្ជូន និងការឆ្លើយតបរបស់រដ្ឋាភិបាលនានាអាចចូលមើលតាមរយៈតំណភ្ជាប់(hyperlinks)។ នីតិវិធីពិសេស អាចទទួលពិចារណាព័ត៌មានបន្ថែមលើករណីណាមួយ ដែលបានបញ្ជូនតាមរយៈលិខិតមួយ។ តាមធម្មតា ព័ត៌មានបន្ថែម ត្រូវបានផ្តល់ដោយប្រភពដដែលដែលបានដាក់ជូនព័ត៌មានបឋម។ ក្នុងឆ្នាំ២០១២ នីតិវិធីពិសេសបានទទួលព័ត៌មានបន្ថែមតាមរយៈលិខិតមាន ២១% នៃករណីទាំងអស់។

នីតិវិធីពិសេស អាចបញ្ជូនលិខិតតាមដាន នៅពេលការវិវត្តន៍តម្រូវឲ្យមានកិច្ចអន្តរាគមន៍មួយថ្មី។ លិខិតតាមដានជាច្រើន គឺផ្អែកលើព័ត៌មានបន្ថែមដែលបានដាក់បញ្ជូន។ ក្នុងឆ្នាំ២០១២ ក្នុងចំណោមលិខិតទាំងអស់ មាន ៣១% គឺជាលិខិតតាមដាន។

ការតាមដានលិខិត កើតមានផងដែរ នៅក្នុងអំឡុងពេលធ្វើទស្សនកិច្ចទៅកាន់ប្រទេស ក៏ដូចជាតាមរយៈកិច្ចពិគ្រោះយោបល់ការទូតជាមួយតំណាងរដ្ឋសាមី។ នៅក្នុងករណីជានិម្មិតរូបខ្លះ នីតិវិធីពិសេសអាចចេញសេចក្តីប្រកាសព័ត៌មាន។

ការតាមដានលិខិត អាចសម្រេចបានបន្ថែមទៀត តាមរយៈសេចក្តីសង្កេតនៅក្នុងរបាយការណ៍ ប្រចាំឆ្នាំរបស់អ្នកកាន់អាណត្តិ។ សេចក្តីសង្កេតទាក់ទងជាពិសេសទៅនឹងនិន្នាការ និងលំនាំនៃការរំលោភសិទ្ធិមនុស្សក្នុងប្រទេសនៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ក៏ដូចជាទាក់ទងនឹងករណីបុគ្គលមួយចំនួនផងដែរ។

### **របាយការណ៍សង្កេតការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិ សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងក្នុងការបង្កើតសមាគម**

ចាប់តាំងពីចាប់ផ្តើមអាណត្តិរបស់លោកក្នុងឆ្នាំ២០១០ អ្នករាយការណ៍ពិសេសបានចេញរបាយការណ៍សង្កេតការណ៍ចំនួនពីរ ក្នុងនោះលោកបានបញ្ជាក់ឡើងវិញពីកង្វល់លើករណីជាក់លាក់មួយចំនួនអំពីការរំលោភសិទ្ធិមនុស្ស ជាពិសេសចំពោះការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងលិខិតទាក់ទង។

## មូលដ្ឋានទិន្នន័យរបស់ក្រុមការងារទទួលបន្ទុកការឃុំខ្លួនដោយបំពាន

មូលដ្ឋានទិន្នន័យរបស់ក្រុមការងារទទួលបន្ទុកការឃុំខ្លួនដោយបំពាន ដែលបានប្រកាសបើកជាផ្លូវការក្នុងឆ្នាំ២០១១ គឺជាឧបករណ៍ស្រាវជ្រាវជាក់ស្តែងមួយ ដើម្បីស្វែងរកមតិយោបល់ដែលក្រុមការងារបានអនុម័តតាំងពីឆ្នាំ១៩៩១។ មូលដ្ឋានទិន្នន័យនេះសម្រួលដល់ការវិភាគមតិយោបល់ទាំងគុណភាព ទាំងបរិមាណ ហើយអាចជួយជនរងគ្រោះដោយការឃុំខ្លួនដោយបំពាន អ្នកវិជ្ជាជីវៈ និងអ្នកដទៃទៀតក្នុងការដាក់បញ្ជូនករណីអះអាងពីឃុំខ្លួនដោយបំពានទៅក្រុមការងារនេះ។[23]

## ការតាមដានករណីនៃការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត

ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត ខិតខំបង្កើតបណ្តាញទំនាក់ទំនងមួយរវាងក្រុមគ្រួសារ និងរដ្ឋាភិបាលពាក់ព័ន្ធ។ ព័ត៌មានបន្ថែមសំខាន់ៗដែលប្រភពផ្សេងៗបានបញ្ជូនស្តីពីករណីនៅមិនទាន់បានដោះស្រាយត្រូវបានបញ្ជូនទៅរដ្ឋាភិបាលពាក់ព័ន្ធ។ ព័ត៌មានដែលរដ្ឋាភិបាលពាក់ព័ន្ធបានផ្តល់អំពីករណីមួយចំនួនជាក់លាក់ ត្រូវបានបញ្ជូនបន្តទៅប្រភពផ្សេងៗ។ ក្រុមការងារបញ្ជូនបន្តនូវការឆ្លើយតបរបស់រដ្ឋផ្សេងៗអំពីជោគវាសនា ឬទីកន្លែងរបស់ជន ដែលបាត់ខ្លួនទៅដល់ប្រភពនិងស្នើសុំឲ្យប្រភពផ្តល់ការសង្កេត ឬព័ត៌មានលម្អិតបន្ថែម។ ប្រសិនជាប្រភពមិនឆ្លើយតបវិញក្នុងអំឡុងពេល៦ខែ ឬប្រសិនជាប្រភពជំទាស់នឹងព័ត៌មានរបស់រដ្ឋាភិបាល ផ្អែកលើមូលដ្ឋានដែលក្រុមការងារយល់ថាមិនសមហេតុផល ករណីនោះត្រូវចាត់ទុកថាត្រូវបានបំភ្លឺ។ ករណីទាំងនោះនៅតែបើកចំហរហូតដល់មានការបំភ្លឺការផ្អាក ឬមានការសម្រេចណាមួយឲ្យបិទករណីនោះ។ ក្រុមការងាររក្រើនរំលឹកដល់រាល់រដ្ឋាភិបាលពាក់ព័ន្ធ មួយដងក្នុងមួយឆ្នាំអំពីករណីដែលមិនទាន់បានបំភ្លឺ និងបីដងក្នុងមួយឆ្នាំអំពីករណីអំពីរាល់ចំណាត់វិធានការបន្ទាន់ដែលបានបញ្ជូនចាប់តាំងពីសម័យប្រជុំលើកមុន។ តាមដែលអាចធ្វើទៅបាន និងតាមការស្នើសុំក្រុមការងារផ្តល់ឲ្យរដ្ឋាភិបាលពាក់ព័ន្ធ ឬប្រភពនូវព័ត៌មានបច្ចុប្បន្នភាពអំពីករណីមួយចំនួនជាក់លាក់ ។[24]

### *តើសង្គមស៊ីវិលអាចចូលរួមដោយវិធីណា ?*

▶ ពិនិត្យមើលរបាយការណ៍ទំនាក់ទំនងជាប្រចាំ ដើម្បីដឹងអំពីការទំនាក់ទំនង ដែលបានបញ្ជូន ស្តីពីស្ថានភាព និងករណីកង្វល់

[23] មាននៅលើវេបសាយ www.unwgaddatabase.org/un/

[24] សម្រាប់ព័ត៌មានបន្ថែម សូមមើលវិធីសាស្ត្រធ្វើការងារ ដែលបានពិនិត្យឡើងវិញ របស់ក្រុមការងារ ( A/HRC/10/9, Annex 1 ).

- ផ្សព្វផ្សាយរបាយការណ៍ឲ្យបានទូលំទូលាយនៅក្នុងបណ្តាញថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីប្រមូលព័ត៌មានបន្ថែមអំពីករណី
- បញ្ជូនព័ត៌មានបច្ចុប្បន្នភាពអំពីការវិវឌ្ឍជាវិជ្ជមាន ឬអវិជ្ជមានទាក់ទងទៅនឹងការទំនាក់ទំនងលើកមុន
- ពិនិត្យមើលការឆ្លើយតបរបស់រដ្ឋាភិបាល និងបញ្ជូនមតិយោបល់ពាក់ព័ន្ធទៅនីតិវិធីពិសេស
- ទំនាក់ទំនងជាប្រចាំជាមួយអ្នកកាន់អាណត្តិនីតិវិធីពិសេសតាមរយៈក្រុមគាំទ្រ OHCHR របស់ពួកគេ និង
- ប្រើអាសយដ្ឋានអ៊ីមែល urgent-action@ohchr.org ឬអាសយដ្ឋានអ៊ីមែលទូទៅរបស់នីតិវិធីពិសេស ដែលពាក់ព័ន្ធ។ សូមចូលមើលព័ត៌មានរបស់នីតិវិធី ពិសេសតាមគេហទំព័រៈ

http://goo.gl/5qoNL

## ការទំនាក់ទំនង និងការតាមដានការទំនាក់ទំនងតាមតំបន់ក្នុងឆ្នាំ២០១២



## *ការតាមដានរបាយការណ៍តាមវិស័យ*

តាមការអនុវត្តជាស្តង់ដា នីតិវិធីពិសេសរៀបចំ ឬចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗ ដើម្បីបង្ហាញ ឬពិភាក្សារបាយការណ៍តាមវិស័យប្រចាំឆ្នាំរបស់ខ្លួនជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ឬមហាសន្និបាត។ ទាំងនេះអាចជាព្រឹត្តិការណ៍ស្របគ្នាក្នុងអំឡុងពេលនៃសម័យប្រជុំរបស់ក្រុមប្រឹក្សា ឬសន្និសីទ ឬសិក្ខាសាលាដទៃទៀត។ ជាទូទៅផងដែរ ដែលត្រូវចេញផ្សាយសេចក្តីប្រកាសព័ត៌មាន ឬអត្ថបទ គេហទំព័រ(web stories) និងធ្វើសន្និសីទសារព័ត៌មានស្តីពីប្រធានបទនៃរបាយការណ៍ផងដែរ។ ទិវាអន្តរជាតិតាមវិស័យ អាចជាឱកាសក្នុងការទាញការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយទៅលើបញ្ហាសិទ្ធិមនុស្ស ដែលបានលើកឡើងក្នុងរបាយការណ៍តាមវិស័យ។

### ឧបករណ៍តាមអ៊ីនធឺណិត៖ របាយការណ៍សង្ខេបស្តីពីសេរីភាពខាងសាសនា ឬជំនឿ និងគំនិតផ្តួចផ្តើមប្រឆាំងទារុណកម្ម

### របាយការណ៍សង្ខេបស្តីពីសេរីភាពខាងសាសនា ឬជំនឿ

ឆ្នាំ២០១១ បានប្រារព្ធខួបលើកទី២៥ នៃការបង្កើតអាណត្តិអ្នករាយការណ៍ ពិសេសស្តីពីសេរីភាពខាងសាសនា ឬជំនឿ។ នៅក្នុងឱកាសនេះ របាយការណ៍សង្ខេបស្តីពីសេរីភាពខាងសាសនាឬជំនឿត្រូវបានប្រកាសបើកជាផ្លូវការនូវការរកឃើញនិងអនុសាសន៍ផ្សេងៗរបស់អ្នកកាន់អាណត្តិចំនួន៤រូប ដែលបានបម្រើការងារតាំងពីឆ្នាំ១៩៨៦។ របាយការណ៍សង្ខេបនេះ ដែលត្រូវបានបង្កើតឡើងជាឧបករណ៍មួយសម្រាប់ការតស៊ូមតិ ការអប់រំ និងការស្រាវជ្រាវរបាយការណ៍សង្ខេបនេះមានបញ្ចូលសម្រង់របាយការណ៍នៃអាណត្តិពីឆ្នាំ១៩៨៦ ដល់ ២០១១ ដែលបានចាត់ថ្នាក់ទៅតាមវិស័យ។[25]

### គំនិតផ្តួចផ្តើមប្រឆាំងទារុណកម្ម

នៅក្នុងឆ្នាំ២០១៣អ្នករាយការណ៍ពិសេសស្តីពីទារុណកម្មបានប្រកាសបើកវេទិកាអនឡាញមួយដែលមានព័ត៌មានអំពីសកម្មភាពតាមដាន រាប់បញ្ចូលទាំងរបាយការណ៍តាមវិស័យ ប្រទេស និងការរកឃើញផ្សេងៗ បន្ថែមពីលើសេចក្តីប្រកាសព័ត៌មាន កិច្ចសម្ភាសន៍ សន្និសីទ សវនាការបទវិចារណកថា និងការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ទាក់ទងនឹងការតាមដានអំពីទស្សនកិច្ចទៅកាន់ប្រទេស និងរបាយការណ៍តាមវិស័យ។[26]

---

[25] មាននៅលើវេបសាយ www.ohchr.org/EN/Issues/FreedomReligion/Pages/Standards.aspx

[26] មាននៅលើវេបសាយ http://antitorture.org

## *តើសង្គមស៊ីវិលអាចចូលរួមតាមវិធីណា ?*

▶ រៀបចំ[27] ឬចូលរួមក្នុងព្រឹត្តិការណ៍ស្របគ្នាក្នុងអំឡុងពេលនៃសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្ស អំពីប្រធានបទនៃរបាយការណ៍តាមវិស័យ។

▶ និយាយយោងដល់ការរកឃើញ និងអនុសាសន៍នៃរបាយការណ៍តាមវិស័យ ដើម្បីពង្រឹងសកម្មភាពរបស់តួអង្គសង្គម ស៊ីវិល(CSAs) (ឧទា. ការតស៊ូមតិ ការកសាងសមត្ថភាព ការផ្សព្វផ្សាយ ការតាមឃ្លាំមើល)

## ៥.៤. ការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់

ជុំដំបូងនៃការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ ត្រូវបានបញ្ចប់កាលពីខែតុលា ឆ្នាំ២០១១ នៅពេលរដ្ឋជាសមាជិក អ.ស.ប ទាំងអស់ ទទួលបានការពិនិត្យរបាយការណ៍។ ក្នុងអំឡុងពេលពិនិត្យរបាយការណ៍ជុំទីពីរ និងជុំបន្ទាប់គេរំពឹងថារដ្ឋភាគីទាំងឡាយនឹងផ្តល់ព័ត៌មានអំពីវិធានការដែលបានចាត់ ដើម្បីអនុវត្តអនុសាសន៍ទាំងឡាយដែលបានមកពីការពិនិត្យជុំទីមួយ ក៏ដូចជាការវិវត្តន៍ដទៃទៀត។ បន្ថែមពីលើនេះ ព័ត៌មានបច្ចុប្បន្នភាពទៀងទាត់ អាចត្រូវបានផ្តល់ជូននៅអំឡុងសម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្រោមចំណុចរបៀបវារៈទី៦ ស្តីពីការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (UPR)។ ទាំងរដ្ឋ ទាំងអង្គការ មិនមែនរដ្ឋាភិបាល អាចផ្តល់ព័ត៌មានបច្ចុប្បន្នភាពតាមរយៈរបាយការណ៍បណ្តោះអាសន្ន សេចក្តីថ្លែងការណ៍ផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ។

### **ការរាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអំពីការអនុវត្តរបាយការណ៍**

### ជាសកលតាមកាលកំណត់ (UPR) នៅប្រទេសកូឡុំប៊ី (Colombia)

គណៈកម្មការអ្នកច្បាប់របស់ប្រទេសកូឡុំប៊ី ផ្តល់ព័ត៌មានបច្ចុប្បន្នភាពយ៉ាងទៀងទាត់ ដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងអំឡុងពេលកិច្ចពិភាក្សាដេញដោលទូទៅក្រោមចំណុច ទី៦នៃរបៀបវារៈ ដែលបានរៀបចំសម្រាប់ UPR។ តាមរយៈការផ្តល់ព័ត៌មាន បច្ចុប្បន្នភាពទាំងនេះ គណៈកម្មការកូឡុំប៊ី ផ្តល់ព័ត៌មានអំពីវឌ្ឍនភាពដែលរដ្ឋាភិបាលកូឡុំប៊ីបានធ្វើដើម្បីការអនុវត្តអនុសាសន៍ UPR។

[27] ការរៀបចំព្រឹត្តិការណ៍ស្របគ្នា ត្រូវបានកម្រិតកំណត់សម្រាប់ NGOs ដែលមានឋានៈពិគ្រោះយោបល់ជាមួយ ECOSOC។

## តើសង្គមស៊ីវិលអាចចូលរួមដោយវិធីណា?

▶ នៅពេលបញ្ជូនព័ត៌មានដើម្បីឲ្យគេដាក់បញ្ចូលក្នុងសេចក្តីសង្ខេបនៃរបាយការណ៍របស់ភាគីពាក់ព័ន្ធ ការសំខាន់ត្រូវដាក់បញ្ចូលការវិភាគថាតើរដ្ឋភាគីបាន ឬមិនបានអនុវត្តអនុសាសន៍ជុំទីមួយយ៉ាងដូចម្តេច?

▶ តួអង្គសង្គមស៊ីវិល(CSAs) អាចផ្តល់ព័ត៌មានទៅរដ្ឋពិនិត្យរបាយការណ៍ ជាពិសេសរដ្ឋដែលបានរៀបចំអនុសាសន៍ នៅអំឡុងពេលនៃការពិនិត្យរបាយការណ៍លើកទីមួយ អំពីការវិភាគរបស់ខ្លួនលើវឌ្ឍនភាពរបស់រដ្ឋក្នុងការអនុវត្តអនុសាសន៍។

▶ អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ (NGOs) ដែលមានឋានៈពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ECOSOC) អាចប្រើប្រាស់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ និងផ្ទាល់ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្រោមចំណុចទី៦ នៃរបៀបវារៈ ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៅក្នុងការអនុវត្តអនុសាសន៍ UPR របស់រដ្ឋ។

សម្រាប់ការណែនាំអំពីការចូលរួមរបស់សង្គមស៊ីវិលក្នុងស្ថាប័នទាំងនេះ សូមមើលកូនសៀវភៅព័ត៌មានរបស់ការិយាល័យOHCHR សម្រាប់សង្គមស៊ីវិល - ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងមគ្គុទ្ទេសក៍ជាក់ស្តែងស្តីពីយន្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់។[28]

## ឧបករណ៍តាមដានការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (UPR)

អង្គការមិនមែនរដ្ឋាភិបាល UPR-Info បានបង្កើតឧបករណ៍ ដើម្បីសម្រួល លើកស្ទួយ និងឃ្លាំមើលការអនុវត្តអនុសាសន៍ UPR។ ជាពិសេស៖

➔ កម្មវិធីតាមដានដែលពិនិត្យមើលការអនុវត្តអនុសាសន៍ពីរឆ្នាំបន្ទាប់ពីជុំទីមួយ (ការវាយតម្លៃលើការអនុវត្តពាក់កណ្តាលអាណត្តិ) និងប្រៀបធៀបអនុសាសន៍ និងការសន្យាជុំទីមួយ ជាមួយព័ត៌មានរបស់រដ្ឋស្តីពីការអនុវត្ត ដែលបានផ្តល់ក្នុងរបាយការណ៍ជាតិរបស់ពួកគេ សម្រាប់ជុំទីពីរនៃ UPR។

➔ ការសិក្សាអំពីផ្លូវឆ្ពោះទៅរកការអនុវត្ត ដែលវិភាគព័ត៌មាន និងទិន្នន័យដែលបានចងក្រងតាមរយៈកម្មវិធីតាមដានដែលពិនិត្យមើលការអនុវត្តអនុសាសន៍ចំនួន ៣.២៩៤ ក្នុងចំណោមអនុសាសន៍ ៦.៥៤២ ដែលបានផ្តល់ដល់ប្រទេសចំនួន ៦៦។

➔ ឧបករណ៍តាមដានសម្រាប់សង្គមស៊ីវិល ដែលបង្ហាញពីសកម្មភាពចំនួនប្រាំ ដែលបាន

[28] មាននៅលើវេបសាយ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

ស្នើឲ្យមានៈ ១. ផ្សព្វផ្សាយអនុសាសន៍UPR និងការសន្យា ជាសាធារណៈ ២. រៀបចំផែនការអនុវត្ត ៣. ចូលរួមក្នុងកិច្ចសន្ទនាជាមួយរដ្ឋភាគីដែលត្រូវបានពិនិត្យ ដើម្បីចូលរួមអនុវត្ត ៤. ឃ្លាំមើលការអនុវត្ត និង ៥. រាយការណ៍អំពីការអនុវត្ត។[29]

អង្គការអន្តរជាតិដែលប្រើភាសាបារាំង ( Organisation internationale de la Francophonie) បានបោះពុម្ពផ្សាយមគ្គុទ្ទេសក៍ជាក់ស្តែងមួយស្តីពីការអនុវត្តអនុសាសន៍ UPR និងការសន្យា។មគ្គុទ្ទេសក៍នេះដែលផ្តោតជាសំខាន់ទៅលើរដ្ឋផ្សេងៗមគ្គុទេសក៍នេះមាន ទំនាក់ទំនងផងដែរ ដល់ភាគីពាក់ព័ន្ធដទៃទៀត រាប់ទាំងតួអង្គសង្គមស៊ីវិល (CSAs) ក្នុងសមត្ថភាពរបស់ពួកគេជាដៃគូរដ្ឋ ក្នុងការតាមដាននិងការអនុវត្ត។ មគ្គុទ្ទេសក៍នេះស្នើឲ្យធ្វើការអនុវត្តតាមរយៈផែនការអនុវត្តន៍មួយ ដែលមាន ១០ ជំហាន គឺ

១. ប្រមូលព័ត៌មានពាក់ព័ន្ធ
២. រៀបចំជាចង្កោមទៅតាមប្រធានបទ
៣. កំណត់សកម្មភាព និងលទ្ធផលរំពឹងទុកពីអនុសាសន៍ផ្សេងៗ
៤. កំណត់វិធានការអនុវត្តន៍
៥. ប្រកាន់យកអភិក្រមសមាហរណកម្មមួយសម្រាប់វិស័យនីមួយៗ
៦. បែងចែកការទទួលខុសត្រូវសម្រាប់អនុវត្តនៅថ្នាក់រដ្ឋ
៧. កំណត់ដៃគូអនុវត្តន៍នៅថ្នាក់ជាតិ
៨. កំណត់ក្របខណ្ឌពេលវេលាសម្រាប់ការអនុវត្ត។
៩. កំណត់តម្រូវការកសាងសមត្ថភាព និងជំនួយបច្ចេកទេស និងដៃគូអនុវត្តន៍នៅថ្នាក់អន្តរជាតិ។
១០. បង្កើតយុទ្ធសាស្ត្រតាមដាន និងវាយតម្លៃមួយសម្រាប់ការអនុវត្ត។[30]

[29] មាននៅលើវេបសាយ www.upr-info.org/followup/

[30] មាននៅលើវេបសាយ www.francophonie.org

## ៥.៥. អភិក្រមរួម

ក្នុងផ្នែកនេះ នីតិវិធីតាមដាន និងការអនុវត្តជាក់ស្តែង ដែលយន្តការផ្សេងៗបានផ្តើតឡើង ត្រូវបានធ្វើបទបង្ហាញដោយឡែកៗពីគ្នាដោយសារថានីតិវិធីនិងការអនុវត្តជាក់ស្តែងមានលក្ខណៈពិសេសខុសៗគ្នា ទោះបីជាមានភាពស្រដៀងគ្នាក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ការសំខាន់គឺត្រូវបញ្ជាក់ជាថ្មីថា ការតាមដាននឹងកាន់តែមានប្រសិទ្ធភាពថែមទៀត ប្រសិនជាធ្វើក្នុងលក្ខណៈរួមបញ្ចូលគ្នា ដែលក្នុងនោះ អនុសាសន៍របស់យន្តការសិទ្ធិមនុស្សផ្សេងៗ ជួយពង្រឹងឲ្យគ្នាទៅវិញទៅមក និងជួយបង្កើនសក្តានុពលឆ្ពោះទៅរកការអនុវត្តជាក់ស្តែង។ សូមមើលផ្នែកទី៣ នៃមគ្គុទ្ទេសក៍នេះ។

## ៥.៦. ការសងសឹក

ការសងសឹកទៅលើបុគ្គល និងក្រុមដែលស្វែងរកកិច្ចសហការ ឬបានសហការជាមួយ អ.ស.ប អ្នកតំណាងនិងយន្តការរបស់ខ្លួន ក្នុងវិស័យសិទ្ធិមនុស្ស គឺជាការរំលោភសិទ្ធិមនុស្ស។ ការសងសឹកអាចកើតឡើងផងដែរ នៅពេលសង្គមស៊ីវិលស្វែងរកកិច្ចសហការជាមួយយន្តការសិទ្ធិមនុស្សអ.ស.ប ក្នុងក្របខណ្ឌនៃសកម្មភាពតាមដាន។

សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ១២/២ បានកំណត់ភារកិច្ចឲ្យអគ្គលេខាធិការដាក់របាយការណ៍ប្រចាំឆ្នាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលមានបញ្ចូលកម្រង និងការវិភាគករណីអះអាងថា មានការសងសឹកទៅលើបុគ្គលដែលសហការជាមួយយន្តការសិទ្ធិមនុស្ស អ.ស.ប ក៏ដូចជាអនុសាសន៍អំពីរបៀប ដោះស្រាយបញ្ហានៃការបំភិតបំភ័យ និងការសងសឹក។[31]

បន្ថែមពីលើករណីសងសឹកទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សា នីតិវិធីពិសេស និងស្ថាប័នសន្ធិសញ្ញា រួមទាំងនីតិវិធីតាមដាន និងការអនុត្តន៍ជាក់ស្តែងរបស់ពួកគេ របាយការណ៍នេះអាចបញ្ចូលការសងសឹក ទាក់ទងនឹងកិច្ចសហការជាមួយការិយាល័យOHCHR វត្តមាននិងទីប្រឹក្សាសិទ្ធិមនុស្ស នៅតាមប្រទេសរបស់ខ្លួន ក្រុម អ.ស.ប ប្រចាំប្រទេស ក្រុមសិទ្ធិមនុស្សនៃបេសកកម្មរក្សាសន្តិភាព ។ល។ ព័ត៌មានអំពីការតាមដានលើករណីដែលមានក្នុងរបាយការណ៍លើកមុនៗ ក៏មានភាពពាក់ព័ន្ធ និងដែលបានលើកទឹកចិត្តផងដែរ។

ការសងសឹកអាចកើតមានទៅលើបុគ្គលដែល៖

- ស្វែងរកកិច្ចសហការ ឬបានសហការជាមួយអ.ស.ប អ្នកតំណាងនិងយន្តការរបស់ខ្លួន ក្នុងវិស័យសិទ្ធិមនុស្ស ឬដែលបានផ្តល់សក្ខីកម្ម ឬព័ត៌មានដល់ពួកគេ

[31] សម្រាប់របាយការណ៍ឆ្នាំ២០១២ និងឆ្នាំ២០១១ សូមមើល A/HRC/21/18 និង A/HRC/18/19.

▶ ប្រើប្រាស់ ឬបានប្រើប្រាស់នីតិវិធីពិសេសដែលបានបង្កើតក្រោមការជួយឧបត្ថម្ភរបស់ អ.ស.ប ដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និង/ឬបានផ្តល់ជំនួយផ្នែកច្បាប់ ឬ ជំនួយដទៃទៀតដល់ពួកគេ សម្រាប់គោលបំណងនេះ។

▶ ដាក់ឬបានដាក់បណ្តឹងឧបាស្រ័យស្របតាមនីតិវិធីដែលបានបង្កើតដោយលិខិតូបករណ៍សិទ្ធិមនុស្ស និង/ឬបានផ្តល់ជំនួយផ្នែកច្បាប់ ឬ ជំនួយដទៃទៀតដល់ពួកគេ សម្រាប់គោលបំណងនេះ

▶ គឺជាសាច់ញាតិរបស់ជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្ស ឬរបស់អ្នកដែលបានផ្តល់ជំនួយផ្នែកច្បាប់ ឬជំនួយដទៃទៀតដល់ជនរងគ្រោះ។

ការផ្សព្វផ្សាយករណីសងសឹកតាមរយៈរបាយការណ៍របស់អគ្គលេខាធិការ អាចនាំមកនូវការការពារកាន់តែប្រសើរថែមទៀត។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យនៃការលាតត្រដាងព័ត៌មានជាសាធារណៈ ក៏ត្រូវតែបានធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្នផងដែរ។ សម្រាប់ហេតុផលនេះ របាយការណ៍ដាក់បញ្ចូលតែករណីណាដែលបុគ្គលពាក់ព័ន្ធ បានផ្តល់ការយល់ព្រមឲ្យបោះពុម្ពផ្សាយករណីរបស់ខ្លួនប៉ុណ្ណោះ។

ដើម្បីបញ្ជូនព័ត៌មានអំពីការសងសឹក សូមទាក់ទង៖

reprisals@ohchr.org

# ៦. ស្វែងយល់បន្ថែម

- វេបសាយរបស់ការិយាល័យ OHCHR៖

www.ohchr.org

- ឧបករណ៍របស់ការិយាល័យOHCHR សម្រាប់សង្គមស៊ីវិលមាននៅទីនេះ៖

www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

មានជាភាសាផ្លូវការទាំង ៦ របស់ អ.ស.ប

- លិបិក្រមសិទ្ធិមនុស្សសកល៖

http://uhri.ohchr.org/

- សេវាអន្តរជាតិសម្រាប់សិទ្ធិមនុស្ស និងមជ្ឈមណ្ឌលច្បាប់សិទ្ធិមនុស្ស ការអនុវត្តក្នុងស្រុកនៃអនុសាសន៍សិទ្ធិមនុស្ស អ.ស.ប - មគ្គុទេសក៍សម្រាប់អ្នកការពារសិទ្ធិមនុស្ស និងអ្នកតស៊ូមតិ ដើម្បីសិទ្ធិមនុស្សដែលមាននៅទីនេះ៖

www.ishr.ch

- ឧបករណ៍តាមដានព័ត៌មាន UPR មាននៅទីនេះ៖

www.upr-info.org/followup

- បណ្តាប្រទេសប្រើភាសាបារាំង មគ្គុទេសក៍អនុវត្តជាក់ស្តែងស្តីពីការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ មាននៅទីនេះ៖

www.francophonie.org

- ចាប់ពីការវិនិច្ឆ័យដល់យុត្តិធម៌ - ការអនុវត្តសេចក្តីសម្រេចសិទ្ធិមនុស្ស អន្តរជាតិ និងតំបន់ ឆ្នាំ២០១០ និងចាប់ពីសិទ្ធិដល់ការដោះស្រាយសំណង៖ វចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ សម្រាប់ការអនុវត្តសេចក្តីសម្រេច សិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០១៣ មាននៅទីនេះ៖

www.opensocietyfoundations.org

- វេបខាស្ទីញ
    - ទូរទស្សន៍វេបសាយ អ.ស.ប៖

http://webtv.un.org

    - សម័យប្រជុំរបស់ស្ថាប័នសន្ធិសញ្ញា

www.treatybodywebcast.org

- មគ្គុទេសក៍សម្រាប់អ្នកវិជ្ជាជីវៈស្តីពីសិទ្ធិមនុស្សក្នុងកិច្ចគាំពារសុខភាពអ្នកជម្ងឺ៖

http://health-rights.org/

- ករណីសិក្សាស្តីពីសកម្មភាពតាមដានសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ៖

www.childrightsnet.org/NGOGroup/CRC/FollowUp/

- មូលដ្ឋានទិន្នន័យរបស់ក្រុមការងារទទួលបន្ទុកការឃុំខ្លួនដោយបំពាន៖

www.unwgaddatabase.org/un/

- របាយការណ៍ស្តីពីសេរីភាពខាងសាសនា ឬជំនឿ៖

www.ohchr.org/EN/Issues/FreedomReligion/Pages/Standards.aspx

អង្គការមិនមែនរដ្ឋាភិបាលខ្លះ ធ្វើការយ៉ាងជិតស្និទ្ធជាមួយយន្តការសិទ្ធិមនុស្សជាក់លាក់។ ពួកគេជួយសម្របសម្រួល និងគាំទ្រការចូលរួមរបស់តួអង្គសង្គមស៊ីវិលជាមួយយន្តការទាំងនោះ ហើយអាចផ្តល់ការណែនាំ និងការគាំទ្រ។ អង្គការមួយចំនួនក្នុងចំណោមអង្គការទាំងនេះ មាន៖

- មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មជ្ឈមណ្ឌល CCPR) សម្រាប់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)
- បណ្តាញសិទ្ធិកុមារសម្រាប់អនុសញ្ញាសិទ្ធិកុមារ (CRC)
- សម្ព័ន្ធជនពិការអន្តរជាតិ (IDA) សម្រាប់អនុសញ្ញាសិទ្ធិជនពិការ
- ចលនាអន្តរជាតិប្រឆាំងរាល់ទម្រង់នៃការរើសអើងនិងជាតិសាសន៍និយម (IMADR) សម្រាប់អនុសញ្ញាប្រឆាំងរាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD)
- វេទិកាអន្តរជាតិស្តីពីអនុសញ្ញាពលករទេសន្តរប្រវេសន៍ (IPMWC) សម្រាប់អនុសញ្ញាពលករទេសន្តរប្រវេសន៍ (CMW)
- ក្រុមប្រឹក្សាស្តារនីតិសម្បទាអន្តរជាតិ សម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្ម (IRCT) សម្រាប់អនុសញ្ញាប្រឆាំងទារុណកម្ម (CAT)
- សកម្មភាពឃ្លាំមើលសិទ្ធិស្ត្រីអន្តរជាតិ (IWRAW) អាស៊ីប៉ាស៊ីហ្វិកសម្រាប់អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)
- ព័ត៌មាន UPR សម្រាប់ UPR

# ៧. សូមទំនាក់ទំនងមកយើង

អាចទាក់ទងផ្នែកសង្គមស៊ីវិលរបស់ការិយាល័យOHCHR បានតាមរយៈ៖

civilsociety@ohchr.org

ទូរស័ព្ទលេខ៖ +៤១(០) ២២ ៩១៧ ៩៦៥៦

កូនសៀវភៅសិទ្ធិមនុស្សរបស់ការិយាល័យOHCHRនិងមគ្គុទេសក៍អនុវត្តជាក់ស្តែងសម្រាប់សង្គមស៊ីវិលអាចរកបានតាមអនឡាញជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រ៉ុស្ស៊ី និងអេស្ប៉ាញ នៅលើវេបសាយ៖ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

ប្រព័ន្ធផ្សាយព័ត៌មានតាមអ៊ីមែលរបស់សង្គមស៊ីវិល ផ្តល់ព័ត៌មានបច្ចុប្បន្នភាព និង ការណែនាំអំពីរាល់អាណត្តិសិទ្ធិមនុស្សនិងយន្តការក៏ដូចជាព័ត៌មាន និងកាលបរិច្ឆេទផុតកំណត់នៃការដាក់ពាក្យសុំថវិកា ហិរញ្ញប្បទាន និងអាហារូបករណ៍។ ដើម្បីជាវ សូមចូលទៅកាន់គេហទំព័ររបស់សង្គមស៊ីវិល ឬ

http://goo.gl/O8snt

*អបអរសាទរខួបទី២០ នៃការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស*

*"សង្គមស៊ីវិលបានវិវត្តន៍និងបានពង្រីកខ្លួន ដោយបច្ចុប្បន្ននេះ មានអង្គការសិទ្ធិមនុស្សជាតិ និងអ្នកការពារសិទ្ធិមនុស្សដ៏សកម្មច្រើនជាងកាលពី២០ឆ្នាំមុន។ អង្គការនិង បុគ្គលទាំងនេះ បានលះបង់ គ្រប់បែបយ៉ាង ដើម្បីបុព្វហេតុសិទ្ធិមនុស្ស៖ ពួកគេគឺជាអ្នកជម្រុញឲ្យមានការផ្លាស់ប្តូរ ជាអ្នកដែលរាយការណ៍ឲ្យដឹងអំពីការរំលោភបំពាន ច្បាប់ខ្សោយ និងអំណាចផ្តាច់ការលោក់មុខនានា។ មគ្គុទ្ទេសក៍ជាក់ស្តែងនេះ គឺជាការអបអរសាទរ ខួបលើកទី២០ របស់ការិយាល័យ OHCHR និងគឺជាកាដូជូនតួអង្គសង្គមស៊ីវិលដែល ធ្វើការដើម្បីសិទ្ធិមនុស្សនៅជុំវិញពិភពលោក"។*

ណាវី ភីឡៃ ( Navi Pillay )
ឧត្តមស្នងការសិទ្ធិមនុស្ស
អង្គការសហប្រជាជាតិ

ខែតុលា ឆ្នាំ២០១៣

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

20 YEARS WORKING FOR YOUR RIGHTS
1993 WORLD CONFERENCE ON HUMAN RIGHTS